ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ច្បាប់ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម និងអនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍
- «អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលសិស្សមកពីអនុវិទ្យាល័យអូរស្វាយ មកទស្សនកិច្ចសិក្សា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា លេខ៣០២ ខែកុម្ភៈ ឆ្នាំ២០២៥

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

### សំបុត្រ

◆ ច្បាប់ស្ដីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម និងអនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍..................... ១

### ផ្នែកឯកសារ

◆ កសាងកម្លាំងក្បត់បដិវត្តន៍នៅមន្ទីរពេទ្យ ....... ៥

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ សហភាពសហព័ន្ធយុវជនកម្ពុជាមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្ដុលជ្សារ ................. ១១

◆ «អគារមរតកសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេចម៉ែ (បុរីអូរស្មាយ-សែនជ័យ)»........................ ១៦

◆ ប្រវត្តិភូមិកំពែបុ ភូមិកុំភ័យ.................... ១៩

◆ បណ្ដាំចុងក្រោយរបស់បងប្រុស ..............២២

◆ រឿងរ៉ាវរបស់គ្រួសារ ឈឹម ហ៊ីន អំឡុងពេលខ្មែរក្រហមជម្លៀសទៅកាន់ខេត្តពោធិ៍សាត់ ..... ២៥

◆ ណិប ផល៖ ខ្ញុំពិការដៃ ដោយសារតែផ្ទុះ ...... ៣០

◆ គ្រួសារខ្ញុំចូលបម្រើបដិវត្តន៍ ប៉ុន្ដែបដិវត្តន៍.... ៣៣

◆ មាស ផ្កា ៖ ជនពិការត្រូវស្រវាចាប់ឈើច្រត់.. ៣៧

◆ ស្រី ហួន ៖ ពេទ្យឯកទេសជំងឺគ្រុនចាញ់....... ៤០

◆ ឪពុកខ្ញុំបានបង្រៀនកូនចៅឱ្យដាំដើមគ ...... ៤២

◆ ឡុង សៀង ៖ កងឡើងត្នោតនៅទួលព្រីង... ៤៥

◆ អ៊ុន អៀង ៖ ខ្មែរក្រហមមានកម្លាំង........... ៤៨

◆ ព្រះពុទ្ធសាសនាសម្ភារនិយមបដិច្ចសមុប្បាទ.. ៥០



នួន ជា និងគណៈប្រតិភូបរទេស។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

### ផ្នែកវេទិកាពិភាក្សាសាធារណៈ

◆ វេទិកាពិភាក្សាប្រវត្តិសាស្ត្រ ស្ដីអំពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង ......................... ៥៤

◆ ប្រវត្តិសាស្ត្រ និងសារសំខាន់នៃការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម....................... ៥៧

### ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ ទូច វ៉ាន់ ៖ នៅតែមានសង្ឃឹមថាកូនប្រុសនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ........... ៦៤

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឱ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, ដេង ពង្សរ៉ាស៊ី, ឈុំ រ៉ា, វី ស៊ីថា, ស្រេង លីដា, ឡុង ដានី, ស្រ៊ាង លីហ៊ួរ, សួត វិចិត្រ, សុខម៉េង, លី សុខឃាង, ព្រុំ ផល្លា, ថុន ស្រីពេជ្រ និង ភា រស្មី
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លឹម អ៊ុកឹង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ច្បាប់ស្តីពីការប្រឆាំងការមិនទទួលស្គាល់

## ឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម និងអនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍ ៖ រយៈពេលពាក់កណ្តាលសតវត្សរ៍ បន្ទាប់ពីខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសាឆ្នាំ១៩៧៥

ឆាំង យុ



*រូបពីឆ្វេងទៅស្តាំ៖ ប៉ុល ពត (លេខាបក្សកុម្មុយនីស្តកម្ពុជា និងជានាយករដ្ឋមន្ត្រីកម្ពុជាប្រជាធិបតេយ្យ), នួន ជា (អនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាតំណាងប្រជាជនកម្ពុជា), អៀង សារី (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស), សុន សេន (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ) និង វន វ៉េត (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច)។ រូបទីពីរខាងស្តាំ នៅជួរមុខ៖ កុយ ធួន រដ្ឋមន្ត្រីពាណិជ្ជកម្ម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំសូមផ្ញើលិខិតនេះជូនទៅកាន់និពន្ធនាយកនៃសារព័ត៌មានទាំងអស់រួមទាំង ទស្សនាវដ្តីការទូតក្នុងគោលបំណងចែករំលែក អំពីការយល់ឃើញរបស់ខ្ញុំចំពោះច្បាប់ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម។ ថ្វីត្បិតតែមានសេចក្តីព្រួយបារម្ភពីសាធារណជនក្នុងកម្រិតមួយពាក់ព័ន្ធជាមួយនឹងកត្តានយោបាយនៃច្បាប់នេះយ៉ាងណាក្តី ខ្ញុំសូមសម្តែងមតិយល់ឃើញផ្ទាល់ខ្លួនថា ច្បាប់នេះគឺពិតជាចាំបាច់ណាស់សម្រាប់មនុស្សដែលកើតក្រោយសម័យខ្មែរក្រហម ក្នុងការរក្សាស្ថិរភាព និងសម្រេចបានការអភិវឌ្ឍន៍ឆ្ពោះទៅមុខបន្ថែមទៀត។ ទោះបីជាយ៉ាងណាក្តី ខណៈដែលច្បាប់នេះមានភាពចាំបាច់ ច្បាប់នេះគឺពុំទាន់គ្រប់គ្រាន់នៅឡើយទេ ក្នុងការសម្រេចបានជោគជ័យលើការងារ ដែលមានវិសាលភាពធំជាងនេះក្នុងការលើកកម្ពស់ការសះស្បើយ




ការអប់រំ និងវឌ្ឍនភាពនាពេលអនាគតរបស់កម្ពុជា។

កម្ពុជាត្រូវការច្បាប់មួយទៀត ដែលចែងថា ការបង្រៀន និង/ឬការបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមជាកាតព្វកិច្ចចាំបាច់ ដើម្បីធានាថាប្រវត្តិសាស្ត្រនៃរយៈកាលដ៏សោកសង្រេងនេះ នឹងមិនត្រូវបានបំភ្លេចចោល។ ច្បាប់ដែលដាក់ពិរុទ្ធទៅលើជនណាដែលមិនទទួលស្គាល់ ឬមាក់ងាយឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម គឺពិតជាឧបករណ៍ដ៏សំខាន់មួយក្នុងការទប់ស្កាត់ ការមិនទទួលស្គាល់ឬការមាក់ងាយចំពោះប្រវត្តិសាស្ត្រនេះ ក៏ប៉ុន្តែច្បាប់នេះអាចដោះស្រាយបញ្ហាបានត្រឹមតែមួយផ្នែកប៉ុណ្ណោះ។ ច្បាប់ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម ពុំអាចដោះស្រាយដើមចមរុញច្រានឱ្យកើតមានរបបប្រល័យពូជសាសន៍គ្រប់ទម្រង់ទេ ដែលនោះគឺ «ការមិនអើពើ»។

ការមិនអើពើ គឺជាឫសគល់នៃភាពមិនខ្វាយខ្វល់, ភាពមិនអត់ឱន និងជាលទ្ធផលឈានទៅកាន់ភាពជ្រុលនិយមហិង្សា ហើយបើគ្មានការអប់រំ អតីតកាលរបស់កម្ពុជា ប្រាកដជាបន្តលងបន្លាចអនាគតរបស់ខ្លួន។ ការមិនអើពើមិនអាច ( និងមិនគួរ ) ចាត់

*រូបថតថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥៖ សិស្សរៀននៅថ្នាក់ទី៤ដល់ថ្នាក់ទី៧ សាលាបឋមសិក្សាព្រៃវែងក្រុង និងវិទ្យាល័យព្រះអង្គឌួង ឈរថតនៅពីមុខផ្ទាំងពិព័រណ៍អចិន្ត្រៃយ៍ បង្ហាញពីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យក្នុងសម្លៀកបំពាក់ខ្មៅ។ សិស្សទាំងអស់បានមកកាន់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដោយខ្លួនឯង ក្នុងគោលបំណងសិក្សាឈ្វេងយល់ពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ តាមរយៈការទស្សនាផ្ទាំងពិព័រណ៍រូបថតកម្រៗ និងស្តាប់ការពន្យល់ណែនាំពីបុគ្គលិកមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង ពីព្រឹត្តិការណ៍សំខាន់ៗកើតឡើងក្នុងរបបខ្មែរក្រហម។ រូបជួរមុខពីឆ្វេងទៅស្តាំ៖ ប្រណី មេត្តា, សុភ័ក្រ ឌ៉ាដា, ណារិន ដា៉រាសី, ណារិន ចរណៃ, ស្រ៊ុន សុនីដា, លាប សុខហេង។ រូបជួរក្រោយពីឆ្វេងទៅស្តាំ៖ ថុន ស្រីពេជ្រ បុគ្គលិកមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង និង រ៉េន។ មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងសមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដែលមាននៅក្នុងផ្ទាំងពិព័រណ៍រូបថតនេះ, រូបពីឆ្វេងទៅស្តាំ៖ ប៉ុល ពត (លេខាបក្ស កុម្មុយនីស្តកម្ពុជា និងជានាយករដ្ឋមន្ត្រីកម្ពុជាប្រជាធិបតេយ្យ, នួន ជា (អនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាតំណាងប្រជាជនកម្ពុជា), អៀងសារី (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស), សុន សេន (ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកការពារជាតិ) និង វន វ៉ែត (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច)។ រូបទីពីរខាងស្តាំនៅជួរមុខ៖ កុយ ធួន រដ្ឋមន្ត្រីពាណិជ្ជកម្ម។ អ្នកដទៃទៀតនៅក្នុងរូបថត គឺជាកងការពារខ្មែរក្រហម ដែលមិនស្គាល់អត្តសញ្ញាណ។ ផ្ទាំងពិព័រណ៍រូបថតនេះ ដាក់តាំងបង្ហាញនៅទីតាំងមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង និង១៧ ខេត្តដទៃទៀត។ ( បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា )*

ចូលជាបទឧក្រិដ្ឋនោះទេ ក៏ប៉ុន្តែបញ្ហានេះអាចដោះស្រាយបានតាមរយៈការអប់រំ។

មានហេតុផលស្របច្បាប់ជាច្រើន បង្ហាញថា វត្តមាននៃច្បាប់ដែលតម្រូវឱ្យមានការបង្រៀន និង/ឬ ការបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម គឺមិនចាំបាច់ទេ ដោយហេតុផលចម្បងនោះគឺ ការអប់រំមិនគួរណាត្រូវការច្បាប់ដើម្បីអនុវត្តទេ។ ការលើកឡើងនេះមិនត្រឹមត្រូវឡើយ ដោយសារការពិតថា ប្រសិនបើការមិនទទួលស្គាល់ឬការមាក់ងាយលើប្រវត្តិសាស្ត្រនេះ ប្រព្រឹត្តទៅដោយចំហ ទាមទារឱ្យមានការចាត់វិធានការជាការអនុម័តច្បាប់ព្រហ្មទណ្ឌ នោះការមិនអើពើ អាចបង្កជាផលវិបាកធំធេង និងគ្រោះថ្នាក់ជាងនេះទៅទៀត នៅក្នុងសង្គមទាំងមូល គឺគួរតែទទួលបានការយកចិត្តទុកដាក់ដូចគ្នាដោយអនុម័តចេញជាច្បាប់។

ការអនុម័តច្បាប់មួយ ដែលតម្រូវឱ្យការបង្រៀន និង/ឬ ការបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហមគឺជាកត្តាចាំបាច់ ក្នុងការលើកតម្កើងកម្ពុជាឱ្យនៅលំដាប់ខ្ពស់ជាងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនឬខ្ពស់ជាងប្រទេសអភិវឌ្ឍន៍ទៅទៀត នៅក្នុងការបង្កើតជាបទដ្ឋានផ្លូវការសម្រាប់ការអប់រំដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។ ច្បាប់នេះនឹងអនុញ្ញាតឱ្យកម្ពុជា ដាក់ចេញជាបទដ្ឋានមួយសម្រាប់ប្រទេសនានា ដែលទទួលរងការបំផ្លិចបំផ្លាញពីសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ដែលមិនត្រឹមតែអាចស្តារប្រទេសរបស់ខ្លួនឡើងវិញតែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងដាក់ចេញជាសកម្មភាពរួមគ្នាក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មទាំងនេះនាពេលអនាគតថែមទៀតផង។ ខុសគ្នាពីច្បាប់ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម គឺមិនគួរមានមតិចម្រូងចម្រាស់ ឬទំនាក់ទំនងនឹងនយោបាយឡើយ ក្នុងការអនុម័តច្បាប់ស្តីពីការអប់រំនេះ។ ច្បាប់ស្តីពីការអប់រំនេះ នឹងជាឧទាហរណ៍មួយទៀតសបញ្ជាក់អំពីការប្តេជ្ញាចិត្តយ៉ាងមធ្យ័តរបស់កម្ពុជា ក្នុងការមិនទទួលស្គាល់ការវិលត្រឡប់មកវិញនូវវត្តមានរបស់ខ្មែរក្រហម ឬរបបណាមួយ ដែលប្រហាក់ប្រហែលទៅនឹងរបបប្រល័យពូជសាសន៍នេះដាច់ខាត។

ខ្ញុំសូមចែករំលែកមតិយល់ឃើញរបស់ខ្ញុំស្តីពីប្រធានបទនេះនៅក្នុងវេទិកាសាធារណៈ ពីព្រោះខ្ញុំជឿជាក់ថា ប្រធានបទនេះពិតជាមានសារសំខាន់សម្រាប់សាធារណជន និងជាប្រធានបទមួយដែលសមស្របជាមួយនឹងអត្ថប្រយោជន៍របស់រាជរដ្ឋាភិបាលកម្ពុជា។ ខ្ញុំយល់ថាការអប់រំគឺជាសសរស្តម្ភដ៏សំខាន់មួយនៃកេរដំណែលរបស់កម្ពុជា និងអាជ្ញាធរកម្ពុជាគ្រប់ជាន់ថ្នាក់ដែលមានឥស្សរជនតំណាងដ៏ខ្ពង់ខ្ពស់ គឺ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា គួរតែចាត់វិធានការក្នុងពេលនេះ ដោយសារតែមូលហេតុពីរគឺ ទីមួយ) គឺគ្មានពេលវេលាណាសក្តិសមជាងខណៈពេលនេះទៀតទេសម្រាប់កម្ពុជា។ កម្ពុជាបានបោះជំហានមកយ៉ាងវែងឆ្ងាយក្នុងការកសាងសង្គមជាតិជាថ្មី, ស្តារឡើងវិញនូវសន្តិភាពនិងភាពចម្រុងចម្រើន និងបង្កើតជាឆន្ទៈថ្នាក់ជាតិក្នុងការតតាំងជាមួយនឹងអតីតកាលរបស់ខ្លួនតាមរយៈការអប់រំ។ យើងមិនគួរមើលរំលងឱកាសនេះសម្រាប់កម្ពុជា ក្នុងការពង្រឹងការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការដឹកនាំពិភពលោកលើវិស័យអប់រំដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។

ទីពីរ ច្បាប់នេះនឹងជាការវិនិយោគទៅលើអនាគតរបស់កម្ពុជា និងជាច្រកចេញនៃឱកាសក្នុងការធ្វើឱ្យការវិនិយោគនេះ ស្ថិតនៅមិនសាបសូន្យទៅតាមពេលវេលា។ ខ្ញុំមានជំនឿចិត្តយ៉ាងមុតមាំចំពោះយុវជននិងយុវនារីសព្វថ្ងៃ ក៏ប៉ុន្តែខ្ញុំគិតថាកំហុសដ៏ធ្ងន់ធ្ងរមួយអាចនឹងកើតមាន ប្រសិនបើយើងសន្និដ្ឋានថាមនុស្សជំនាន់ក្រោយៗរបស់កម្ពុជា នឹងមានការយល់ដឹងអំពីសារសំខាន់នៃប្រវត្តិសាស្ត្រនេះ ដូចទៅនឹងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

និងថ្នាក់ដឹកនាំនាពេលបច្ចុប្បន្ន។ ស្ថិតក្នុងគម្លាតរយៈពេលដ៏ឆ្ងាយពីសម័យកាលដ៏ព្រឺព្រួចនេះ មនុស្សជំនាន់ក្រោយៗរបស់កម្ពុជា អាចងាយនឹងមិនចាប់អារម្មណ៍យល់ដឹងអំពីប្រវត្តិសាស្ត្រដ៏ស្មុគស្មាញនេះ ព្រមទាំងអាចនឹងមិនជឿថាព្រឹត្តការណ៍ដ៏សោកសង្រេងនេះ ធ្លាប់កើតមាននាពេលកន្លងមក។ សូម្បីតែសព្វថ្ងៃនេះ ខ្ញុំបានជួបជាមួយយុវជន-យុវនារីមួយចំនួន ដែលបានចោទសួរថាតើប្រវត្តិសាស្ត្រខ្មែរក្រហម និងរបបប្រល័យពូជសាសន៍ត្រូវបានបំផ្លើស ឬប្រតិដ្ឋឡើងបុយ៉ាងណា។ ច្បាប់ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម នឹងការពារអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, មនុស្សជាទីស្រឡាញ់របស់អ្នកទាំងនេះ និងសង្គមជាតិសព្វថ្ងៃ ពីការរំខានផ្លូវចិត្តដែលបង្កឡើងដោយការមិនទទួលស្គាល់ ឬការមាក់ងាយចំពោះប្រវត្តិសាស្ត្រនេះក៏ប៉ុន្តែមានតែច្បាប់តម្រូវឱ្យមានការអប់រំ និងការបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រនេះទេ ដែលអាចទប់ស្កាត់ផលប៉ះពាល់កំបាំងមុខបង្កឡើងដោយការមិនអើពើដែលអាចកើតមាននាពេលអនាគត។



ប្រជាជន ១៧ មេសា ឬប្រជាជនថ្មី រស់នៅតំបន់ជនបទដាច់ស្រយាលក្នុងប្រទេសកម្ពុជា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# កសាងកម្លាំងក្បត់បដិវត្តន៍នៅមន្ទីរពេទ្យព-១៧ តាមរយៈការប្រព្រឹត្តកំហុសឆ្គងសីលធម៌

ផេង ពង្សរ៉ាស៊ី



ក្រុមគ្រូពេទ្យបុរាណក្នុងរបបខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការកសាងកម្លាំងក្បត់បដិវត្តន៍ក្នុងស្រទាប់កម្មាភិបាលខ្មែរក្រហម គឺជារឿងរ៉ាវមួយក្នុងចំណោមរឿងរ៉ាវជាច្រើនដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ ទន្ទឹមនឹងខ្មែរក្រហមមានផែនការច្បាស់លាស់ក្នុងការកម្ទេចសត្រូវវណ្ណៈរបស់ខ្លួនដែលជាទាហាន និងមន្ត្រីរដ្ឋការក្នុងរបបសាធារណរដ្ឋខ្មែរព្រមទាំងជនជាតិអ៊ិស្លាម វៀតណាម និងអនិកជនចិនក្នុងទូទាំងប្រទេស កម្មាភិបាលក្រោមបង្គាប់របស់ខ្លួនមួយចំនួនបាននាំគ្នាប្រឆាំងទៅនឹងអង្គការបដិវត្តន៍ទៅវិញ ហើយហេតុការណ៍នេះបានបន្សល់ទុកជាភស្តុតាងប្រវត្តិសាស្ត្រមិនអាចបំភ្លេចបាន តាមរយៈចម្លើយសារភាពរបស់ជនក្បត់ដែលបង្ហាញពីខ្សែសង្វាក់នៃអំពើក្បត់។

តាំងពីភ្លាមៗក្រោយថ្ងៃរដ្ឋប្រហារឆ្នាំ១៩៧០ ហេតុការណ៍ក្បត់បដិវត្តន៍បានលេចរូបរាងឡើងនៅពាសពេញប្រទេសកម្ពុជា ហើយនៅតែបន្តរហូតដល់ចុងឆ្នាំ១៩៧៨។ សកម្មភាពទាំងនេះ បានបង្ហាញឱ្យឃើញពីការប្រើប្រាស់ឈ្មោះបដិវត្តន៍ មកបិទបាំងសកម្មភាពក្បត់បដិវត្តន៍របស់មនុស្សមួយក្រុម ដែលតស៊ូដើម្បីការផ្លាស់ប្តូររបបសង្គមចេញពីការដឹកនាំ

របស់ខ្មែរក្រហម។ ខ្មែរក្រហម បានចោទប្រកាន់អ្នកទាំងនោះថា ជាក្រុម«ខ្មែរ-ស», «សេ-អ៊ី-អា», «កា-ហ្សេ-បេ»,«ពួកសេរី»,«ខ្មាំងស៊ីរូងផ្ទៃក្នុង», និង«ក្បាលយួនខ្លួនខ្មែរ»... ព្រោះថាអ្នកទាំងនោះបានចូលរួមធ្វើសកម្មភាពបំផ្លិចបំផ្លាញបដិវត្តន៍ និយាយអាក្រក់ពីបដិវត្តន៍ អូសទាញនិងបញ្ចុះបញ្ចូលអ្នកដទៃឱ្យចូលរួមក្បត់បដិវត្តន៍ជាមួយខ្លួន និងបង្កភាពស្មុគស្មាញដល់ការកសាងប្រទេសរបស់ខ្មែរក្រហម។

ក្នុងចំណោមសកម្មភាពក្បត់បដិវត្តន៍ជាច្រើន ដែលខ្មែរក្រហមបានចោទប្រកាន់ ការប្រព្រឹត្តកំហុសឆ្គងសីលធម៌រវាងបុរស និងស្ត្រី ក៏ជាទង្វើក្បត់បដិវត្តន៍ដែរ។ អ្នកដែលប្រព្រឹត្តទង្វើបែបនេះ ភាគច្រើនត្រូវបានសម្លាប់ដោយខ្មែរក្រហម។ ដើម្បីបញ្ចៀសការលួចលាក់នូវការប៉ះពាល់សីលធម៌ជាមួយបុរស និងដើម្បីកុំឱ្យស្ត្រីចំណាយពេលវេលាច្រើនក្នុងការតុបតែងខ្លួន ខ្មែរក្រហមបានកំណត់ឱ្យស្ត្រីកាត់សក់ខ្លីត្រឹម-ក និងមិនអនុញ្ញាតឱ្យប្រើប្រាស់គ្រឿងលម្អ និងក្រេមម្សៅឡើយ។ ទំនាក់ទំនងស្នេហារវាងបុរស និងស្ត្រី ឬសកម្មភាពផ្លូវភេទក្រៅពីការរៀបការដែលអង្គការបានរៀបចំឱ្យ ត្រូវបានហាមឃាត់ជាដាច់ខាត ហើយអ្នកដែលប្រព្រឹត្ត ឬលួចលាក់ស្រឡាញ់គ្នា ឬសាហាយស្មន់ជាមួយគ្នា អ្នកនោះត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តកំហុសឆ្គងសីលធម៌ ឬប៉ះពាល់សីលធម៌ ឬខូចសីលធម៌។ ទោសកំហុសរបៀបនេះ អ្នកប្រព្រឹត្តនឹងត្រូវនាំយកទៅសម្លាប់ចោលដោយគ្មានការលើកលែងឡើយ។ ជាមួយគ្នានេះដែរ ខ្មែរក្រហមមានផែនការបង្កើតមនុស្សដើម្បីបម្រើអង្គការបដិវត្តន៍ទៅថ្ងៃក្រោយ នោះគឺការបង្ខំឱ្យបុរស និងស្ត្រីឱ្យរៀបការជាមួយគ្នា ទាំងដែលអ្នកទាំងពីរនាក់ពុំដែលស្គាល់គ្នា ឬស្រឡាញ់គ្នាពីមុនមកទេ។ មានបុរស និងស្ត្រីមួយចំនួនបានស្លាប់ដោយសារការបង្ខំនេះ ហើយមួយចំនួនទៀតបានបន្សល់ទុកនូវភាពជូរចត់រហូតមកដល់សព្វថ្ងៃ ខណៈដែលអ្នកខ្លះទៀតកំពុងតែរស់នៅជាមួយគ្នា មានទាំងកូន ទាំងចៅ និងចៅទួតនាពេលបច្ចុប្បន្ន។

***តើការបំបែកបំបាក់ ឬការបំបិទសិទ្ធិសេរីភាពខាងមនោសញ្ចេតនាស្នេហារវាងបុរស និងស្ត្រីក្នុងទូទាំងប្រទេស អាចធ្វើឱ្យការដឹកនាំប្រទេសរបស់ខ្មែរក្រហមទទួលបានជោគជ័យដែរឬទេ ខណៈដែលមានការបង្ខិតបង្ខំមនោសញ្ចេតនារបស់បុរស និងស្ត្រីឱ្យស្រឡាញ់គ្នាដោយគ្មានការឯកភាពយល់ព្រម?***

នៅក្នុងសេចក្តីរាយការណ៍សង្ខេបសរសេរដោយដៃរបស់កម្មាភិបាលសួរចម្លើយឈ្មោះ សេង នៃមន្ទីរ ស-២១ ចេញពីចម្លើយសារភាពរបស់ឈ្មោះ សុខ ម៉េត ជាប្រធានក្រុមថត-ឆ្លុះនៅមន្ទីរពេទ្យ ព-១៧ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៨ បានពន្យល់ថា សកម្មភាពក្បត់អង្គការនៅក្នុងមន្ទីរពេទ្យ ព-១៧ គឺធ្វើឡើងដើម្បី៖ ១) កម្ទេចកម្លាំងបដិវត្តន៍តាមរយៈការព្យាបាល និងវះកាត់អ្នកជំងឺ។ ២) បំផ្លិចបំផ្លាញគ្រឿងបរិក្ខាពេទ្យ។ ៣) បង្កួចនយោបាយជាមួយភ្ញៀវចិន និង ៤) កសាងកម្លាំងក្បត់ឱ្យបានកាន់តែច្រើនថែមទៀត។ ដើម្បីឆ្លើយទៅនឹងសំណួរខាងលើ ខ្ញុំសូមលើកយកតែចំណុចមួយក្នុងចំណោមចំណុចទាំងបួនគឺ «ការកសាងកម្លាំងក្បត់បដិវត្តន៍នៅក្នុងមន្ទីរពេទ្យព-១៧» មកបកស្រាយ និងរៀបរាប់ពីដំណើរសាច់រឿងដែលនាំឱ្យការកសាងកម្លាំងក្បត់ក្នុងជួរបដិវត្តន៍របស់ខ្មែរក្រហម មានសន្ទុះកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

ដើម្បីជាអំណះអំណាងក្នុងការបកស្រាយ និងរៀបរាប់ពីមូលហេតុនៃការកើនឡើងចំនួនអ្នកចូលរួមក្បត់អង្គការខ្មែរក្រហមនៅក្នុងមន្ទីរពេទ្យ ព-១៧ ខ្ញុំពិនិត្យមើលឯកសារចម្លើយសារភាពចំនួន៥ឯកសារ ដែលមានតម្កល់នៅក្នុងបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា និងដកស្រង់យកតែចំណុច ឬពាក្យសម្តីរបស់ម្ចាស់ចម្លើយសារភាពដែលពាក់ព័ន្ធនឹងការកសាងកម្លាំងក្បត់បដិវត្តន៍បន្ថែមទៀតនៅក្នុងមន្ទីរពេទ្យ ព-១៧» តាមរយៈការញុះញង់ឱ្យប្រព្រឹត្តកំហុសឆ្គងសីលធម៌មកបង្ហាញ។

តាមរយៈការអានឯកសារចម្លើយសារភាពចំនួន ៥ អត្ថបទនេះ នឹងឆ្លើយសំណួរខាងលើតាមលក្ខណៈនៃការរៀបរាប់ពីសកម្មភាពនៃការប្រព្រឹត្តកំហុស

ឆ្គងសីលធម៌នៅក្នុងមន្ទីរពេទ្យ ដែលសកម្មភាពទាំងអស់នេះ នាំដល់ការបំផ្លិចបំផ្លាញអាយុជីវិតមនុស្ស និងទ្រព្យសម្បត្តិសាធារណៈ។ នេះ គ្រាន់តែជាការចូលរួមមួយផ្នែកទាក់ទងនឹងប្រសិទ្ធិភាពនៃការហាមប្រាមរឿងទំនាក់ទំនងស្នេហារវាងបុរស និងស្ត្រី ដែលមេដឹកនាំខ្មែរក្រហមបានរឹតបន្តឹង ដើម្បីជៀសវាងការរំខានក្នុងការអភិវឌ្ឍន៍ប្រទេសរបស់ខ្លួន។ ឯកសារទាំង៥នេះ បង្ហាញពីមនុស្សមួយក្រុមមានតួនាទីជាកម្មាភិបាលពេទ្យនៅមន្ទីរពេទ្យ១៧មេសា ឬ មន្ទីរពេទ្យ ព-១៧ មានទីតាំងស្ថិតនៅក្នុងទីក្រុងភ្នំពេញ ធ្វើសកម្មភាពអូសទាញកម្លាំងក្បត់បដិវត្តន៍តាមរយៈការប្រព្រឹត្ត និងការបញ្ចុះបញ្ចូលឱ្យប្រព្រឹត្តកំហុសឆ្គងសីលធម៌ ដែលខ្មែរក្រហមបានហាមឃាត់។

មន្ទីរពេទ្យ១៧មេសា ឬ មន្ទីរពេទ្យ ព-១៧ របស់ខ្មែរក្រហម គឺជាមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នាពេលបច្ចុប្បន្ន។ មន្ទីរពេទ្យនេះ បានសាងសង់ឡើងនៅចុងទសវត្សរ៍ឆ្នាំ ១៩៥០ ក្រោមការឧបត្ថម្ភពីរដ្ឋាភិបាលសហភាពសូវៀត និងបានសម្ពោធឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី ២៩ ខែសីហា ឆ្នាំ១៩៦០ ដោយមានឈ្មោះថា មន្ទីរពេទ្យកម្ពុជា-សូវៀត។ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩ មន្ទីរពេទ្យនេះ ត្រូវផ្លាស់ប្តូរឈ្មោះទៅជា «មន្ទីរពេទ្យ១៧ មេសា ឬមន្ទីរ ព-១៧» ដែលមានកម្មាភិបាលគ្រប់គ្រងដំបូងឈ្មោះ សី ហៅ ឡេង សី (ត្រូវអង្គការចាប់ខ្លួននៅឆ្នាំ១៩៧៧)។ ក្រោយរបបខ្មែរក្រហមដួលរលំ មន្ទីរពេទ្យ ព-១៧ បានផ្លាស់ប្តូរឈ្មោះមកមន្ទីរពេទ្យកម្ពុជា-សូវៀតវិញ ហើយមកដល់បច្ចុប្បន្ននេះ ឈ្មោះនេះបានផ្លាស់ប្តូរម្តងទៀតទៅជា «មន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត»។

## ព្រុំ ធី ហៅ ឆេង ជាយុទ្ធនារីចិញ្ចឹមសត្វនៅមន្ទីរពេទ្យ ព-១៧

ចម្លើយសារភាពសរសេរដោយដៃចំនួន២៥ ទំព័រ រៀបរាប់ពីសកម្មភាពក្បត់បដិវត្តន៍របស់ ព្រុំ ធី ហៅ ឆេង តាំងពីពេលដែល ឆេង បានចូលបម្រើបដិវត្តន៍ដំបូងនៅឆ្នាំ១៩៧២ រហូតដល់ថ្ងៃដែលអង្គការចាប់ខ្លួននៅខែកុម្ភៈ ឆ្នាំ១៩៧៨។ ក្នុងរយៈពេលជាង៦ឆ្នាំបន្ទាប់ពីចូលបម្រើបដិវត្តន៍ ឆេង បានបម្រើបដិវត្តន៍ខ្មែរក្រហមបានតែត្រឹមរយៈពេលប៉ុន្មានខែតែប៉ុណ្ណោះ ព្រោះតាំងពី ឆេង បានចាកចេញពីផ្ទះមកធ្វើការនៅក្នុងមន្ទីរតំបន់៤១មក ឆេង បានបម្រើក្នុងចលនាខ្មែរសរហូតដល់ថ្ងៃអង្គការចាប់ខ្លួន។ ឆេង កើតនៅភូមិត្បែង ឃុំសាន់គរ ស្រុកកំពង់ស្វាយ តំបន់៤១ ភូមិភាគឧត្តរចាស់។ ឆេង មានឪពុកម្តាយជាអ្នកប្រកបរបរធ្វើស្រែ។ នៅឆ្នាំ១៩៧០ ភូមិកំណើតរបស់ ឆេង ត្រូវបានគ្រប់គ្រងដោយចលនាតស៊ូបដិវត្តន៍របស់ខ្មែររំដោះ។ នៅឆ្នាំ១៩៧២ ឆេង បានចូលបម្រើបដិវត្តន៍ តាមរយៈប្រធានភូមិត្បែងឈ្មោះ ម៉ែន។ ចូលបដិវត្តន៍ដំបូង ឆេង ស្ថិតក្រោមការគ្រប់គ្រងរបស់ វ៉ង់ និងមានតួនាទីធ្វើស្រែនៅក្នុងឃុំសាន់គរ។ នៅខែមិថុនា ឆ្នាំ១៩៧២ ឆេង បានផ្លាស់ប្តូរការងារមកធ្វើការនៅក្នុងក្រុមកុមារតំបន់៤១វិញ ជាកន្លែងដែល ឆេង ត្រូវបានបញ្ចុះបញ្ចូលឱ្យចូលបម្រើក្នុងក្រុមខ្មែរស។ ឆេង បានជឿលើការអូសទាញរបស់ ផុន ដែលជាសមាជិកក្នុងក្រុមខ្មែរស ព្រោះថា ឆេង ខ្លាចស្លាប់ដោយសារតែការចូលបម្រើបដិវត្តន៍ ដែល ផុន បានលើកឡើងថា ចូលបដិវត្តន៍គឺគ្មានបាយហូប លំបាក ក្រីក្រ និងទីបំផុតគឺស្លាប់ទាំងខ្លួននៅក្មេង។ «ខ្ញុំយល់ព្រមធ្វើខ្មែរស ឱ្យតែជីវិតខ្ញុំរស់» ជាសម្តីរបស់ ព្រុំ ធី ហៅ ឆេង ឆ្លើយតបទៅ ផុន ប្រធានក្រុមដឹកប្រឡាយនៅមន្ទីរតំបន់៤១ ក្នុងពេលដែល ផុន បញ្ចុះបញ្ចូល ឆេង ឱ្យក្បត់បដិវត្តន៍។ ក្រោយថ្ងៃ១៧ មេសា ១៩៧៥ ឆេង ត្រូវអង្គការបញ្ជូនមកធ្វើការនៅក្នុងមន្ទីរសង្គមកិច្ច ហៅ មន្ទីរ ក-២ ក្រុងភ្នំពេញ មានទីតាំងស្ថិតនៅក្បែរពហុកីឡដ្ឋានអូឡាំពិក។ នៅមន្ទីរសង្គមកិច្ច ឆេង បានទទួលបញ្ជាឱ្យបង្កចលាចលជាមួយកម្មាភិបាលមន្ទីររហូតដល់ខែកក្កដា ឆ្នាំដដែល ទើប ឆេង ត្រូវផ្លាស់ចេញពីមន្ទីរសង្គមកិច្ច មកធ្វើការនៅក្នុងមន្ទីរពេទ្យ១៧មេសា ហៅ មន្ទីរ ព-១៧វិញ។ បក្ខពួករបស់ ឆេង ដែលធ្លាប់ធ្វើសកម្មភាពបម្រើក្នុងក្រុមខ្មែរស ត្រូវបានបំបែកឱ្យទៅធ្វើការនៅកន្លែងផ្សេងគ្នា។ យ៉ាង ទៅធ្វើការនៅមន្ទីរពេទ្យ ព-១ ខាងព្យាបាលកុមារ ហើយ

ជន និង ឆុន នៅក្នុងមន្ទីរ ព-២។ ប្រធានមន្ទីរ ព-១៧ ឈ្មោះ សី ដែលមានឈ្មោះពេញ ឡេង សី គឺជាកម្លាំងស្នូលក្នុងចលនាខ្មែរស ហើយក៏ជាអ្នកដែលបានរៀបចំផែនការសម្លាប់អ្នកជំងឺនៅក្នុងមន្ទីរពេទ្យ ព-១៧ អស់ជាច្រើននាក់ដែរ ក្រោមការអនុវត្តបញ្ជាពី ឆេង និងសមាជិកក្នុងមន្ទីរពេទ្យជាច្រើននាក់ទៀត។ បន្ទាប់ពី ឆេង ត្រូវ សី ផ្លាស់ប្តូរឱ្យទៅនៅកន្លែងចិញ្ចឹមសត្វនៅក្នុងមន្ទីរពេទ្យ សី បានបញ្ចុះបញ្ចូល ឆេងឱ្យខូចសីលធម៌ជាមួយយុទ្ធមិត្តអ្នកជំងឺមកសម្រាកក្នុងមន្ទីរពេទ្យ តាមរយៈការធ្វើទំនាក់ទំនងក្នុងពេលចែកបាយអ្នកជំងឺ។ ឆេងបានសារភាពថា ខ្លួនបានខូចសីលធម៌ជាមួយយុទ្ធមិត្តច្រើននាក់ ដើម្បីអូសទាញអ្នកទាំងនោះឱ្យមកបម្រើក្នុងក្រុមខ្មែរសជាមួយខ្លួនវិញ។

## គីម ឆេន ហៅ វ៉ាត ប្រធានផ្នែកនៅពេទ្យ ព-១៧

នៅខែតុលា ឆ្នាំ១៩៧៥ គីម ឆេន ហៅ វ៉ាត ត្រូវសមមិត្តនារី យន ណែនាំឱ្យស្គាល់សមមិត្តនារីម្នាក់ទៀតឈ្មោះ សុន ជាអតីតប្រធានផ្នែកផ្ទះបាយនៅមន្ទីរពេទ្យ ព-១៧ ដែលជាខ្សែក្បត់ជាមួយ យន និងធ្លាប់បានធ្វើសកម្មភាពខូចសីលធម៌ជាមួយអ្នកជំងឺជាយុទ្ធជននៅក្នុងមន្ទីរពេទ្យ។ ការណែនាំឱ្យស្គាល់គ្នានេះ គឺដើម្បីរួមគ្នាប្រព្រឹត្តិកំហុសឆ្គងសីលធម៌នៅក្នុងមន្ទីរពេទ្យជាមួយអ្នកជំងឺឱ្យបានកាន់តែច្រើនឡើងៗ។ យនបាននិយាយដូច្នេះថា ការរួមគ្នាធ្វើសកម្មភាពនេះ គឺធ្វើឡើងក្នុងចេតនាបង្កភាពចលាចលក្នុងមន្ទីរពេទ្យ និងឆ្លៀតឱកាសបំពាក់បំប៉នអ្នកជំងឺនៅក្នុងមន្ទីរពេទ្យឱ្យអស់ជំនឿលើបក្សដឹកនាំ ព្រមទាំងកសាងកម្លាំងក្បត់ឱ្យបានកាន់តែច្រើនឡើងៗ។

ខែមករា ឆ្នាំ១៩៧៨ រឿងរ៉ាវខុសឆ្គងសីលធម៌នៅក្នុងមន្ទីរពេទ្យ ព-១៧ កាន់តែរីករាលដាលឡើង។ យុទ្ធមិត្តនារីពេទ្យជាច្រើននាក់ត្រូវបានបំពាក់បំប៉នឱ្យប្រព្រឹត្តកំហុសឆ្គងសីលធម៌ជាមួយយុទ្ធជនដែលមកព្យាបាលរបួស និងជំងឺនៅក្នុងមន្ទីរពេទ្យនេះ។ ដៃ និង ផេន ជាកម្មាភិបាលទទួលខុសត្រូវមន្ទីរពេទ្យ ព-១៧ បន្ទាប់ពី សី ដែលអង្គការបានចាប់ខ្លួនកាលពីចុងឆ្នាំ១៩៧៧ បានកោះហៅសមមិត្តនារីដែលធ្វើការនៅក្នុងមន្ទីរពេទ្យចំនួន១៧ នាក់ ដែលភាគច្រើនជាប្រធានផ្នែកសំខាន់ៗនៅក្នុងមន្ទីរពេទ្យព-១៧ ឱ្យចូលរួមប្រជុំនៅក្នុងសាលានយោបាយ នៅវេលាយប់ ដើម្បីបំផុសរឿងសីលធម៌ជាមួយយុទ្ធមិត្តដែលជាអ្នកជំងឺ ហើយបង្គាប់ឱ្យចាប់ផ្តើមអនុវត្តភ្លាមបន្ទាប់ពីប្រជុំចប់។ រហូតមកដល់ខែសីហា ឆ្នាំ១៩៧៨ កិច្ចប្រជុំសម្ងាត់ជាច្រើនទៀត ត្រូវបានធ្វើឡើងនៅក្នុងមន្ទីរពេទ្យ ព-១៧ ដើម្បីប្រាប់ពីផែនការបរាជ័យក្នុងការធ្វើរដ្ឋប្រហារទម្លាក់រដ្ឋាភិបាលខ្មែរក្រហម និងឱ្យផ្អាកសកម្មភាពបំផ្លិចបំផ្លាញសម្ភារក្នុងមន្ទីរពេទ្យជាបណ្តោះអាសន្ន។ ប៉ុន្តែកិច្ចប្រជុំទាំងអស់នៅតែបញ្ចុះបញ្ចូលឱ្យនារីពេទ្យទាំងអស់បន្តប្រព្រឹត្តការប៉ះពាល់សីលធម៌ទៀត ដើម្បីអូសទាញកម្លាំងបន្ថែមឱ្យបានកាន់តែច្រើន។ ការរៀបចំផែនការធ្វើរដ្ឋប្រហារផ្តួលរំលំរដ្ឋាភិបាលខ្មែរក្រហម បានកើតឡើងចំនួនពីរដងរួចមកហើយគឺនៅខែមេសា និងខែសីហា ឆ្នាំ១៩៧៨។ នៅដើមខែសីហា ឆ្នាំ១៩៧៨ ដៃ បានកោះហៅសមាជិកក្បត់ទាំងអស់ឱ្យមកចូលរួមប្រជុំនៅអគារបីជាន់ក្នុងបរិវេណមន្ទីរពេទ្យ ដើម្បីរៀបចំផែនការថ្មី និងបញ្ចុះបញ្ចូលសមាជិកទាំងអស់ឱ្យអត់ធ្មត់ចំពោះសភាពការណ៍ចំពោះមុខឱ្យបានល្អ និងប្រយ័ត្នប្រយែងបំផុត។ កិច្ចប្រជុំនេះ ក៏បានលើកឡើងដែរពីការពង្រឹងកម្លាំងបន្ថែម តាមរយៈការអូសទាញកម្លាំងកម្មាភិបាលពេទ្យ និងយុទ្ធមិត្តដែលមកព្យាបាលនៅក្នុងមន្ទីរពេទ្យ។ ដៃ និយាយដូច្នេះថា **«...គឺអូសទាញកម្លាំងមហាជនខាងគេមកខាងយើង លុះត្រាតែមិត្តយើងចុះជាប់ជាមួយមហាជនឱ្យបានជិតស្និទ្ធឱ្យគេស្រឡាញ់យើង និងទាក់ទាញមនោសញ្ចេតនារបស់គេឱ្យមកខាងយើង ឬអូសទាញមនោសញ្ចេតនារបស់គេតាមសម្ភារ នោះប្រាកដជាចូលជាមួយយើងហើយ»។**

## សៅ ម៉ន ហៅ ផេន ប្រធានផ្នែកខាងព្យាបាលជំងឺទូទៅនៅពេទ្យ ព-១៧

នៅចុងឆ្នាំ១៩៧៧ សៅ ម៉ន ហៅ ផេន កំពុងធ្វើការនៅស្រែអំបិលរដ្ឋឯខេត្តកំពត ជាកន្លែងដែល ផេន ត្រូវបានបញ្ចុះបញ្ចូលឱ្យក្បត់បដិវត្តន៍ប្រឆាំងនឹង

ការដឹកនាំថ្នាក់មូលដ្ឋានរបស់ខ្មែរក្រហម។ វ៉ែន និង វ៉ាន់ បានបំផុសបំផុលឱ្យ ផេន និង នារីស្រែអំបិលឯទៀតប្រព្រឹត្តកំហុសឆ្គងសីលធម៌ជាមួយយុទ្ធជនដែលជាកងប្រមូលអំបិល។ ពីខែមីនា ដល់ ខែឧសភា ឆ្នាំ១៩៧៨ អង្គការបានផ្លាស់ប្ដូរ វ៉ែន, ផេន, និង បក្ខពួកមួយចំនួនមាន មុត និង យន ពីការងារនៅស្រែអំបិល ឱ្យមកធ្វើជាកម្មាភិបាលពេទ្យនៅមន្ទីរពេទ្យ ព-១៧ វិញ។ ផេន មានតួនាទីជាប្រធានផ្នែកផ្ទះបាយរួមរបស់អ្នកជំងឺ។ កន្លះខែក្រោយការកាន់កាប់តួនាទីនេះ ផេន បានជួបជាមួយ វ៉ែន ដែលជាសមាជិកក្បត់តាំងពីស្រែអំបិលមក។ វ៉ែនបានប្រាប់ ផេន ថា ភីន ដែលធ្លាប់ប៉ះពាល់សីលធម៌ជាមួយខ្លួនកាលពីនៅស្រែអំបិល បានមកកាន់មន្ទីរពេទ្យ ព-១៧ ហើយខ្លួនបានបន្តប៉ះពាល់សីលធម៌ជាមួយ ភីនបានពីរដងទៀត។ ជំនួបនេះ ទំនងជា វ៉ែន ចង់ឱ្យ ផេន បន្តប្រព្រឹត្តកំហុសសីលធម៌ និងបញ្ចុះបញ្ចូលនារីពេទ្យទាំងអស់ឱ្យចូលរួមក្នុងការប្រព្រឹត្តកំហុសសីលធម៌នៅក្នុងមន្ទីរពេទ្យ។ វ៉ែន ក៏បាននិយាយប្រាប់ ផេង ទៀតថា ប្រធានអនាម័យរួមនៅមន្ទីរពេទ្យ ព-១៧ ឈ្មោះ ធុក ក៏កំពុងតែបានប៉ះពាល់សីលធម៌ជាមួយ វ៉ែម ជាអតីតប្រធានរោងចក្រផលិតថ្នាំជាតិ ផ-៦ និងជាប្រធានមន្ទីរពេទ្យ ព-១៧ តាំងពីខែសីហា ឆ្នាំ១៩៧៨មក។ បន្ទាប់ពីឡើងកាន់កាប់តំណែងជាប្រធានមន្ទីរពេទ្យ ព-១៧ ភ្លាម វ៉ែមបានបើកការប្រជុំមួយនៅអគារបីជាន់ទាំងយប់ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថ្មី ក្នុងការបំផ្លាញបដិវត្តន៍។ វ៉ែម បានទទួលស្គាល់ថា រឿងរ៉ាវកំហុសឆ្គងសីលធម៌នៅក្នុងមន្ទីរពេទ្យ គឺលេចធ្លោខ្លាំងណាស់ ហើយប្រឫកប្របល់ថែមទៀត។ វ៉ែម នៅតែលើកទឹកចិត្តឱ្យកម្លាំងទាំងអស់ ទាំងយុវជននិងនារី ដែលធ្លាប់បានបំពេញការកិច្ចនេះបន្តសកម្មភាពឱ្យកាន់តែខ្លាំងក្លាឡើងថែមទៀត ដើម្បីងាយស្រួលអូសទាញកម្លាំងបង្កប់ស៊ីរូងផ្ទៃក្នុងបក្ស។ វ៉ែម បានផ្ដាំផ្ញើទៅកម្លាំងទាំងអស់ក្នុងផ្នែកសីលធម៌ឱ្យធ្វើកិច្ចការនេះយ៉ាងប្រយ័ត្នប្រយែងជាទីបំផុត និងធ្វើយ៉ាងណាកុំឱ្យមានការថ្លោះធ្លោយ ព្រោះថាមិត្តនារីមួយចំនួនបានប៉ះពាល់សីលធម៌ជាមួយយុទ្ធជនហើយ បែរជាបែកគ្នា និងមិនអាចអូសទាញគេមកចូលក្នុងក្រុមក្បត់បាន។ ផេន បានបញ្ចុះបញ្ចូល ម៉ុង, ចន, និង ខា ឱ្យបង្កចលាចលសីលធម៌ជាមួយនារីពេទ្យនៅក្នុងមន្ទីរពេទ្យ និងជួយបញ្ចុះបញ្ចូលកម្មាភិបាលក្នុងមន្ទីរពេទ្យឯទៀត ឱ្យចូលរួមនៅក្នុងសកម្មភាពនេះ។ នៅក្នុងមន្ទីរពេទ្យ ផេន បានប្រព្រឹត្តកំហុសឆ្គងសីលធម៌ជាមួយនារីពេទ្យជាហូរហែ។ នៅខែកញ្ញា ឆ្នាំ១៩៧៨ ធុក ដែលធ្លាប់បានប្រព្រឹត្តកំហុសសីលធម៌ជាមួយ វ៉ែន បានកោះប្រជុំជាមួយកម្លាំងក្បត់បដិវត្តន៍ទាំងអស់ នៅក្នុងបន្ទប់លេខ១០១ ជាន់ផ្ទាល់ដី នៃមន្ទីរពេទ្យ ព-១៧ ដើម្បីបង្កើនសកម្មភាពអូសទាញកម្លាំងក្បត់ តាមរយៈការធ្វើជាគំរូដល់កម្មាភិបាលក្បត់ឯទៀត ក្នុងការប្រព្រឹត្តកំហុសឆ្គងសីលធម៌។ ធុក បានសង្កត់ធ្ងន់នៅក្នុងអង្គប្រជុំយ៉ាងដូច្នេះថា **«បើកាលណាលើផ្នែកទាក់ទងសីលធម៌នេះវាបានផុលផុសហើយ គឺវា (កម្មាភិបាលបដិវត្តន៍) រំភើប វាភ្លេចអស់ការងារបក្សហើយ ហើយចេះតែបំផុសឱ្យកាន់តែប្រឫកប្របល់ឡើង។ ដូច្នេះ យើងស្រួលអូសទាញកម្លាំងឱ្យមកខាងយើងទៀត។»** ក្រោយកិច្ចប្រជុំ សមាជិកចូលរួមទាំងអស់ រីករាយនឹងអនុវត្តសកម្មភាពប៉ះពាល់សីលធម៌គ្នា ព្រមទាំងអូសទាញអ្នកដទៃឱ្យដើរលើគន្លងផ្លូវដែលខ្លួនកំពុងដើរទៀតផង។ ផេនបានណែនាំ ម៉ឹង និង សាក់ ឱ្យខូចសីលធម៌ជាមួយនារី មឿន និង វណ្ណា។ ចំណែកខ្លួនឯងបានខូចសីលធម៌ជាមួយនារីម្នាក់ទៀតឈ្មោះ ខន។ ការប៉ះពាល់គ្នាផ្នែកសីលធម៌នេះ បានកើតឡើងជាហូរហែ ខណៈដែលសកម្មភាពបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងជីវិតមនុស្ស ក៏កំពុងកើតមានឡើងព្រមគ្នាដោយសារស្នាដៃ ម៉ឹង សាក់ ផេន មឿនវណ្ណា និង ខន។ ផេន បានរាយការណ៍ថា ខ្លួន និងម៉ឹង បានដុតបំផ្លាញឃ្លាំងថ្នាំពេទ្យនៅមន្ទីរពេទ្យ ព-១៧ ឆេះអស់មួយកន្លែងនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៨ ដែលការដុតបំផ្លាញនេះបានធ្វើឱ្យអង្គការបាត់បង់អគារពេទ្យ និងថ្នាំសង្កូវអស់យ៉ាងច្រើនសន្ធឹកសន្ធាប់។ ផេន និង ម៉ឹង ក៏បានសម្លាប់អ្នកជំងឺជាយុទ្ធជនអង្គការម្នាក់ តាមរយៈការចាក់ទឹក

ចូលទៅក្នុងសៀវភៅដែលកំពុងព្យួរឱ្យយុទ្ធជនម្នាក់នោះ។ ក្រោយមកទៀត នៅខែតុលា ឆ្នាំ១៩៧៨ ម៉ង់ និង រី បានសម្រេចកាត់ជើងម្ខាងរបស់យុទ្ធជនម្នាក់ដែលរបួសជើងនេះ គឺគ្រាន់តែជារបួសស្រាលដែលអាចព្យាបាលដោយមិនចាំបាច់កាត់បាន។ ម៉ង់ និង រី បានប្រាប់ពីមូលហេតុកាត់ជើងយុទ្ធជនម្នាក់នោះថា បើព្យាបាលជើងឱ្យជា យុទ្ធជនម្នាក់នោះពិតជាត្រូវវិលត្រឡប់ទៅកាន់អង្គភាពបម្រើបដិវត្តន៍វិញហើយ។ ដូច្នេះដើម្បីបំផ្លាញបដិវត្តន៍ និងមិនចង់ឱ្យយុទ្ធជនម្នាក់នោះមានឱកាសបម្រើបដិវត្តន៍តទៅទៀត អ្នកទាំងពីរបានកាត់ជើងយុទ្ធជនម្នាក់នោះត្រឹមជង្គង់។

## សឹង សុខនី ហៅ សុខនី

សឹង សុខនី ហៅ សុខនី ភេទស្រី អាយុ២០ឆ្នាំក្នុងពេលចាប់ខ្លួន។ តាំងពីក្មេងរហូតដល់អាយុ១៨ឆ្នាំ សុខនីរស់នៅជាមួយយាយ នៅភូមិទួល ស្រុកឈូក ខេត្តកំពត តំបន់៣៥។ នៅឆ្នាំ១៩៧០ សុខនី បានចូលបដិវត្តន៍តាមរយៈ ជឹម ជាប្រធាននារីតំបន់៣៣ ហើយបានរស់នៅជាមួយ ជឹម រហូតដល់ឆ្នាំ១៩៧៣។ បន្ទាប់ពីថ្ងៃ១៧ មេសា ១៩៧៥ សុខនីបានមកធ្វើការជានារីពេទ្យនៅមន្ទីរពេទ្យ ព-១៧។ នៅខែកញ្ញា ឆ្នាំ១៩៧៥ សុខនីបានខូចសីលធម៌ជាមួយយុទ្ធជនឈ្មោះ ដួរ។ សុខនី បានប្រាប់រឿងរ៉ាវខូចសីលធម៌ជាមួយ ដួរ ទៅ យន ដែលជាអ្នកទទួល សុខនី ឱ្យមកធ្វើជានារីពេទ្យ និងជាអ្នកបញ្ចុះបញ្ចូលឱ្យ សុខនី ប្រព្រឹត្តកំហុសឆ្គងសីលធម៌ផង ដើម្បីឱ្យ យនបានដឹង និងមានផែនការបន្ត។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ សុខនីបានខូចសីលធម៌ម្តងទៀតជាមួយយុទ្ធជនម្នាក់ទៀតឈ្មោះ ធឹម ជាមនុស្សចូលចិត្តខាងប្រព្រឹត្តសីលធម៌ជាមួយ នារីៗ និងមាននាទីជាកម្មាភិបាលនៅក្រសួងសង្គមកិច្ច ខណៈដែល សុខនី ត្រូវបានចាត់តាំងឱ្យផ្លាស់ប្តូរការងារមកធ្វើការនៅក្នុងឃ្លាំងថ្នាំពេទ្យ។ ឡេង សី ជាគណៈមន្ទីរពេទ្យ ព-១៧ មុនពេលចាប់ខ្លួន បានអប់រំ សុខនី ឱ្យបន្តធ្វើសកម្មភាពប៉ះពាល់សីលធម៌ជាមួយយុទ្ធជនដែលមកសម្រាកនៅក្នុងមន្ទីរពេទ្យ ឱ្យខ្លាំងក្លាថែមទៀត។ សី បានប្រាប់វិធី-សាស្ត្រទាក់ទងយុទ្ធជនសម្រាកពេទ្យឱ្យខូចសីលធម៌ជាមួយខ្លួនថា សុខនី ត្រូវតែសរសេរសំបុត្រស្នេហារួចប្រគល់ឱ្យអ្នកជំងឺជាយុទ្ធជន ហើយនៅពេលដែលយុទ្ធជននោះដឹងហើយ គឺរកពេលវេលាដើម្បីខូចសីលធម៌ជាមួយគ្នា។ រហូតដល់ឆ្នាំ១៩៧៧ សុខនី បានអប់រំនារីពេទ្យឈ្មោះ មួន, យឹម, និង គីម ឱ្យប្រព្រឹត្តសីលធម៌ខុសដូចខ្លួនដែរ ជាមួយយុទ្ធជន៥នាក់មានឈ្មោះ ពួក, វឿន, មឿន, ស្រៀង និង តាំង ដែលភាគច្រើនជាយុទ្ធជនមកពីភូមិភាគបូព៌ា។ ចំណែកខ្លួនឯង បានខូចសីលធម៌ជាមួយយុទ្ធជនម្នាក់ផ្សេងទៀតឈ្មោះ ណាត។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៨ សុខនី ត្រូវអង្គការចាប់ខ្លួន។

តាមរយៈឯកសារចម្លើយសារភាពទាំង៥ខាងលើ ខ្មែរក្រហមបានចំណាយពេលវេលាយ៉ាងច្រើនដើម្បីតាមដាន ចាប់ខ្លួន សួរចម្លើយពីសកម្មភាពក្បត់បដិវត្តន៍និងអ្នកដែលចូលរួមក្បត់ជាមួយ និងចុងក្រោយ សម្រាប់អ្នកទាំងនោះចោល។ ការព្យាយាមបង្កើតគោលការណ៍ថ្មីៗរបស់ខ្មែរក្រហមខុសពីក្រិតក្រមធម្មជាតិរបស់មនុស្ស គឺមិនទទួលបានជោគជ័យឡើយ។ ទោះបីជាអង្គការបដិវត្តន៍មានវិន័យតឹងរ៉ឹងចំពោះការប្រព្រឹត្តកំហុសឆ្គងសីលធម៌យ៉ាងណាក៏ដោយ ក៏សកម្មភាពនេះនៅតែកើតមានឡើងតាមទម្រង់ផ្សេងៗ ដែលរឹតតែធ្វើឱ្យអង្គការខ្មែរក្រហមលំបាកក្នុងការបោសសម្អាតខ្លាំង។ ផ្ទុយទៅវិញ ការហាមប្រាមនេះ វាបែរជាបង្កឱ្យមានភាពចលាចលក្នុងសង្គមដែលខ្លួនគ្រប់គ្រងទៅវិញ។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខD០៧៣៨២, D២១២៣៨, D២១២៥៦, D២១២៦៨, J០០០៣៧, J០០០៤១។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពទាំងនេះពិតប៉ុណ្ណោះទេ?**

# សហភាពសហព័ន្ធយុវជនកម្ពុជាមកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ក្ដុលផ្សារ

## ទស្សនកិច្ចសិក្សា និងចូលរួមវេទិកាថ្នាក់រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម

ឈុំ រ៉ា និង ទី ស៊ីថា



យុវជននៃសហភាពសហព័ន្ធយុវជនកម្ពុជា ហៅកាត់ថា ស.ស.យ.ក មកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ក្តុលផ្សារ ចំនួន១៥នាក់ មកធ្វើទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៥ មជ្ឈមណ្ឌលឯកសារកោះថ្ម បានទទួលស្វាគមន៍ យុវជននៃសហភាពសហព័ន្ធយុវជនកម្ពុជា ហៅកាត់ថា ស.ស.យ.ក មកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ក្តុលផ្សារ ចំនួន១៥នាក់ ក្នុងនោះមានស្រី១០នាក់ មកធ្វើទស្សនកិច្ចសិក្សា និងចូលរួមវេទិកាថ្នាក់រៀនស្តីអំពី ៖ ការចូលកាន់កាប់ទីក្រុងភ្នំពេញ, ការជម្លៀសប្រជាជនចេញពីទីក្រុងនិងទីប្រជុំជនដោយបង្ខំ និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ គោលបំណងនៃដំណើរទស្សនកិច្ចសិក្សាសម្រាប់ថ្ងៃនេះ គឺយុវជនចង់សិក្សាស្វែងយល់អំពីរឿងរ៉ាវខ្មែរក្រហមតាមរយៈឯកសារដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកោះថ្មពិព័រណ៍រូបថត និងទស្សនារចនាបថផ្ទះសហគមន៍ជនជាតិដើមភាគតិចស្មៀងភូមិក្តុលលើ។

ជាកិច្ចចាប់ផ្តើម លោក ឈុំ រ៉ា បានណែនាំខ្លួន និងក្រុមការងារនៃមជ្ឈមណ្ឌលឯកសារកោះថ្ម ដល់

យុវជនដែលបានមកទស្សនកិច្ចសិក្សានៅថ្ងៃនេះ។ បន្ទាប់មកលោក ឈុំ វ៉ា បានរៀបរាប់អំពីផ្ទាំងពិព័រណ៍រូបថតចំនួន៤ផ្ទាំង នៅខាងលើផ្ទះសហគមន៍ភូមិក្តុលលើ៖

**ផ្ទាំងរូបថត ទី១)** ការចងចាំពីដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត របស់សម្តេចតេជោ ហ៊ុន សែន។ សម្តេច ហ៊ុន សែន ក៏ជាស្ថាបនិករណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលបានបង្កើតឡើងនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨។

**ផ្ទាំងរូបថត ទី២) កិច្ចប្រជុំពិសេសនិមិត្តរូបរវាងឪពុក និងកូន ក្នុងដំណើរដែលសម្រេចបានសន្តិភាពពេញលេញនៅកម្ពុជា៖** សម្តេច ហ៊ុន សែន បានជួបជាមួយសម្តេចព្រះ នរោត្តម សីហនុ ជាលើកដំបូង នៅថ្ងៃទី២ ដល់ទី៤ ខែធ្នូ ឆ្នាំ១៩៨៧។ ចាប់ពីពេលនោះមក សម្តេច ហ៊ុន សែន បានចាប់ផ្តើមបន្តទំនាក់ទំនងនេះឱ្យកាន់តែប្រសើរឡើងជាមួយសម្តេចព្រះ នរោត្តម សីហនុ ដើម្បីគាំទ្រកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយនៅកម្ពុជា។ មានការបោះឆ្នោតជាសកលនៅកម្ពុជា នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៣ ប៉ុន្តែខ្មែរក្រហមមិនបានចូលរួមការបោះឆ្នោតនោះទេ។

**ផ្ទាំងរូបថត ទី៣) ការអនុវត្តយុទ្ធសាស្ត្រគន្លឹះរបស់សម្តេចតេជោ ហ៊ុន សែន ក្នុងការបញ្ចប់សង្គ្រាមគឺ «នយោបាយ ឈ្នះ ឈ្នះ»៖** ក្រោយពីការបោះឆ្នោត នៅខែឧសភា ឆ្នាំ១៩៩៣ ខ្មែរក្រហមនៅតែបចេសរឹងរូសបន្តសង្គ្រាម ប៉ុន្តែមិនបានសម្រេចជោគជ័យនោះទេ។ កងកម្លាំងរបស់រាជរដ្ឋាភិបាលដែលមានបទពិសោធន៍ច្បាស់លាស់ និងទទួលបានការហ្វឹកហ្វឺនជាប្រចាំ បានវាយបក និងទប់ស្កាត់ក្រុមខ្ទាមខ្មែរក្រហម។ រហូតដល់ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៨ មេដឹកនាំខ្មែរក្រហម រួមមាន ខៀវ សំផន, នួន ជា និង អៀង សារី សុំចុះចូលនៅគេហដ្ឋានរបស់សម្តេច ហ៊ុន សែន។

**ផ្ទាំងរូបថត ៤) ការពារមនុស្សធម៌ និងសង្គ្រោះ៖** ទោះបីជាប្រឈមនឹងការឆ្លងពីជំងឺរាតត្បាតកូវីដ-១៩ តែកងយោធពលខេមរភូមិន្ទនៅតែបន្តការចូលរួមក្នុងការប្តេជ្ញាបន្តភារកិច្ចរបស់ខ្លួន ដើម្បីជាតិ និងអន្តរជាតិ។ សម្តេចតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី ដែលតំណាងឱ្យប្រជាជនកម្ពុជាទូទាំងប្រទេស បានបង្ហាញសណ្តានចិត្តមនុស្សធម៌នៅក្នុងឱកាស



យុវជននៃសហភាពសហព័ន្ធយុវជនកម្ពុជា ហៅកាត់ថា ស.ស.យ.ក មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ក្តុលដូង ចំនួន១៥នាក់ មកធ្វើទស្សនកិច្ចសិក្សានៅផ្ទះសហគមន៍ជនជាតិស្មៀងភូមិក្តុលលើ នៃមជ្ឈមណ្ឌលឯកសារកោះថ្មុ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាច្រើនៗ ជាឧទាហរណ៍ នៅក្រោមការដឹកនាំរបស់សម្តេច តេជោ ហ៊ុន សែន រាជរដ្ឋាភិបាលកម្ពុជាបានជួយដល់ភ្ញៀវទេសចរណ៍អន្តរជាតិដែលកំពុងជាប់គាំងនៅលើនាវា វេស្ទើរដាម ឱ្យវិលត្រឡប់ទៅស្រុកកំណើតវិញ។

បន្ទាប់ពីក្រុមយុវជន សហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក) ទស្សនាពិព័រណ៍រូបភាពរបនាបថផ្ទះសហគមន៍ជនជាតិដើមភាគតិចស្មៀងភូមិក្តុលលើរួច លោក ឈុំ វ៉ា បានដឹកនាំក្រុមយុវជន ស.ស.យ.ក ធ្វើដំណើរទៅ មជ្ឈមណ្ឌលឯកសារកោះថ្ម។ នៅទីនោះ ក្រុមយុវជន ស.ស.យ.ក ដើរទស្សនាពិព័រណ៍រូបភាព ស្តីពីសង្គ្រាមកាលពីចុងទសវត្សរ៍ឆ្នាំ១៩៦០ រូបថតអំពីរបបខ្មែរក្រហម (១៩៧៥-១៩៧៩) រូបថតអំពីជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ រូបថតភស្តុតាងអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបខ្មែរក្រហម (១៩៧៥-១៩៧៩) រូបគំនូរ និងផែនទីបង្ហាញផ្លូវនៃដំណើររបស់សម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្ត៤រូប ចេញទៅប្រទេសវៀតណាមនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដើម្បីកសាងកងកម្លាំងប្រដាប់អាវុធ សាមគ្គីសង្គ្រោះជាតិកម្ពុជាវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត សង្គ្រោះអាយុជីវិតប្រជាជនកម្ពុជាប្រមាណ៥លាននាក់ឱ្យរួចផុតពីសេចក្តីស្លាប់។

ចុងបញ្ចប់នៃទស្សនកិច្ចសិក្សា និង វេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) យុវជនបានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖

**លីន ស៊ីវម៉ី** ភេទស្រី រៀនថ្នាក់ទី១១«ក» មកពីវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនក្តុលផ្សារ។ នៅថ្ងៃនេះនាងខ្ញុំពិតជាមានសេចក្តីត្រេកអរ ដែលបានសិក្សាបន្ថែមពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ខ្ញុំមានអារម្មណ៍ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ឬរបបខ្មែរក្រហម ពិតជាឃោរឃៅណាស់សម្រាប់ប្រជាជនខ្មែរ។ ខ្មែរក្រហមបានប្រើប្រជាជនឱ្យធ្វើការងារគ្មានពេលឈប់សម្រាក។ ខ្មែរក្រហមបានធ្វើទារុណកម្មលើប្រជាជន និងបានបំបែកបំបាក់ប្រជាជនចេញពីក្រុមគ្រួសារ។ បច្ចុប្បន្ន ប្រទេសកម្ពុជាមានសន្តិភាព សេរីភាព ដូច្នេះខ្ញុំនឹងខិតខំប្រឹងប្រែងរៀនសូត្រដើម្បីកុំឱ្យអតីតកាលដ៏អាក្រក់ត្រឡប់មកវិញ។

**ភាក់ ចំរុង** ភេទប្រុស ជាសិស្សថ្នាក់ទី១១ «ក» នៃវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ក្តុលផ្សារ បានរៀបរាប់ថា មុនពេលមកទស្សនកិច្ចសិក្សានេះ ខ្ញុំបានយល់ដឹងតិចតួចអំពីរបបខ្មែរក្រហមពីការសិក្សាតាមរយៈសៀវភៅរបស់ក្រសួងអប់រំ។ ប៉ុន្តែបន្ទាប់ពីបុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្មពន្យល់ណែនាំបន្ថែម ធ្វើឱ្យខ្ញុំកាន់តែដឹងច្រើននិងយល់ច្បាស់ជាងមុនអំពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ខ្ញុំបានដឹងថារបបខ្មែរក្រហមឃោរឃៅកាចសាហាវ ព្រោះបានសម្លាប់ប្រជាជនខ្មែរ។ ខ្ញុំមិនចង់ឱ្យមានរបបខ្មែរក្រហមកើតឡើងម្តងទៀតនោះទេ។ ខ្ញុំពិតជាអរគុណដល់មជ្ឈមណ្ឌលឯកសារកោះថ្ម ដែលរៀបចំឱ្យមានដំណើរទស្សនកិច្ចនេះ ដើម្បីផ្តល់ចំណេះដឹងផ្នែកប្រវត្តិសាស្ត្រដល់យុវជនជំនាន់ក្រោយ។

ខ្ញុំឈ្មោះ **វ៉យ៉មរិទ្ធី** ភេទប្រុស ជាសិស្សថ្នាក់ទី១០ «ខ» នៃវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែនក្តុលផ្សារ។ មុនពេលចុះមកទស្សនកិច្ចសិក្សានេះ ខ្ញុំបានយល់ដឹងអំពីស្ថានភាពរស់នៅរបស់ប្រជាជនក្នុងរបបខ្មែរក្រហមខ្លះៗ។ ប៉ុន្តែបន្ទាប់ពីបានសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមរួច ខ្ញុំបានដឹងកាន់តែស៊ីជម្រៅ និងធ្វើឱ្យខ្ញុំចង់សិក្សាស្វែងយល់បន្ថែមទៀត។ វាគឺជាបទពិសោធន៍ដ៏ឈឺចាប់មួយសម្រាប់ប្រជាជនខ្មែរដែលបណ្តាលឱ្យមានការបាត់បង់ជីវិតប្រជាជនរាប់លាននាក់។ ខ្ញុំគ្រាន់តែចង់ឱ្យអ្នកសិក្សាជំនាន់ក្រោយបន្តការសិក្សា និងស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដើម្បីកុំឱ្យកំហុសនៃអតីតកាលកើតឡើងម្តងទៀត។

ខ្ញុំឈ្មោះ **ជា ម៉េងហ៊ាង** ភេទប្រុស រៀនថ្នាក់ទី១១ «គ» នៅវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្តុលដង្ក្រារ។ ខ្ញុំយល់ថារបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) គឺជារបបមួយដែលធ្វើឱ្យប្រជាជនកម្ពុជានៅតែចងចាំ ព្រោះរបបនេះបានបំបែកបំបាក់ឪពុកម្តាយ ប្តីប្រពន្ធ កូន និងបានសម្លាប់ប្រជាជនខ្លួនឯង។ បន្ទាប់ពីបានចូលរួមទស្សនកិច្ចសិក្សានេះរួច ធ្វើឱ្យខ្ញុំយល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិប-តេយ្យបានច្រើនជាងមុន។ ជាពិសេស ខ្ញុំបានដឹងពីព្រឹត្តការណ៍ដែលបានកើតឡើងក្នុងរបបខ្មែរក្រហម, ការតស៊ូរបស់ថ្នាក់ដឹកនាំឆ្ពោះទៅរកសន្តិភាព និងការអភិវឌ្ឍន៍។ ខ្ញុំសូមអរគុណចំពោះបងៗក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម និងលោកគ្រូដែលបានផ្តល់ឱកាសដល់ខ្ញុំក៏ដូចជាសិក្សានុសិស្សដទៃទៀត ឱ្យបានចូលរួមក្នុងដំណើរទស្សនកិច្ចអំពីប្រវត្តិសាស្ត្រក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ជាចុងក្រោយ ខ្ញុំចង់សំណូមពរឱ្យមានដំណើរទស្សនកិច្ចនេះកើតឡើងជារៀងរាល់ខែ ទៅកាន់តំបន់សាស្ត្រខ្មែរក្រហមផ្សេងៗទៀត។





យុវជននៃសហភាពសហព័ន្ធយុវជនកម្ពុជា ហៅកាត់ថា ស.ស.យ.ក មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្តុលដង្ក្រារ ចំនួន១៥នាក់ មកធ្វើទស្សនកិច្ចសិក្សានៅផ្ទះសហគមន៍ជនជាតិស្ទៀងភូមិក្តុលលើ នៃមជ្ឈមណ្ឌលឯកសារកោះថ្ម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)









យុវជននៃសហភាពសហព័ន្ធយុវជនកម្ពុជា ហៅកាត់ថា ស.ស.យ.ក មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្ដុលដូរ ចំនួន១៥នាក់ មកធ្វើទស្សនកិច្ចសិក្សានៅផ្ទះសហគមន៍ជនជាតិស្មៀងភូមិក្ដុលលើ និងមជ្ឈមណ្ឌលឯកសារកោះថ្ម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# «អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)»

## នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលសិស្សមកពីអនុវិទ្យាល័យអូរស្វាយ មកទស្សនកិច្ចសិក្សា

**ស្រេង លីដា**




សិស្សានុសិស្សមកពីអនុវិទ្យាល័យអូរស្វាយ ទស្សនកិច្ចសិក្សា អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៥ អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) បានរៀបចំទទួលសិស្សានុសិស្សមកពីអនុវិទ្យាល័យអូរស្វាយចំនួន១០នាក់ ដែលកំពុងរៀនថ្នាក់ទី៧។ ដំណើរទស្សនកិច្ចសិក្សានេះ ដឹកនាំដោយលោកគ្រូនាយក សឺន សុផា និងអ្នកគ្រូ សុគុណ ថាវី។ គោលបំណងនៃទស្សនកិច្ចសិក្សានេះ គឺដើម្បីសិក្សាស្វែងយល់បន្ថែមពីសារប្រយោជន៍នៃអគារប្រវត្តិសាស្ត្រ អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) និងចូលរួមស្តាប់រឿងរ៉ាវជីវិតរបស់លោកតា សើង សារ៉ាង ដែលធ្លាប់រស់នៅក្នុងតំបន់អូរស្វាយតាំងពីកុមារភាព។ លោកតា សើង សារ៉ាង ក៏ជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងបានចែករំលែកបទពិសោធន៍ជីវិតក្នុងរបបខ្មែរក្រហម ទៅកាន់សិស្សានុសិស្សដើម្បីចូលរួមទប់ស្កាត់កុំឱ្យរបបខ្មែរក្រហមកើតឡើងសារជាថ្មីម្តងទៀត។

លោក ស្រេង លីដា បុគ្គលិកប្រចាំការនៅ «អគារមរតកសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានលើកឡើងថា អគារមរតកសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) បានតម្កល់សៀវភៅរាប់ពាន់ក្បាល ទាំងជាភាសាខ្មែរ និងភាសាអង់គ្លេស បោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងព្រះរាជបណ្ណាល័យហ្វូងម៉ែៗ លើសពីនេះ សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គសព្វព្រះរាជហឫទ័យព្រះរាជទាននូវសៀវភៅសរុបចំនួន២៩ក្បាល សម្រាប់តម្កល់ និងរក្សាទុកនៅ «អគារមរតកសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)» ដែលជាឯកសារដ៏មានសារសំខាន់សម្រាប់កូនចៅរបស់ព្រះអង្គសិក្សារៀនសូត្រ។ សៀវភៅទាំង២៩ក្បាល គឺជាព្រះរាជស្នាព្រះហស្តរបស់ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋ និងសម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ដែលបង្ហាញអំពីប្រវត្តិសាស្ត្រ, ព្រះរាជជីវប្រវត្តិ, ព្រះរាជសកម្មភាព, ព្រះរាជនយោបាយ និងការកសាងសមិទ្ធិផលផ្សេងៗចាប់តាំងពីសម័យសង្គមរាស្ត្រនិយម រហូតមកដល់បច្ចុប្បន្ន ។ អគារមរតកសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) បានដើរតួនាទីជាបណ្ណាល័យយ៉ាងសំខាន់ក្នុងការផ្ដល់ធនធានចំណេះដឹងដ៏សម្បូរបែប រួមមាន ប្រវត្តិសាស្ត្រ បរិស្ថាន បច្ចេកវិទ្យា ទស្សនវិជ្ជា និងមាតិកាផ្សេងៗដល់សាធារណជន។

សិស្សានុសិស្សមកពីអនុវិទ្យាល័យបុរីអូរស្វាយ, គ្រូបង្រៀន, អ្នកសិក្សាស្រាវជ្រាវ និងប្រជាពលរដ្ឋទូទៅនៅមូលដ្ឋានស្រុកបុរីអូរស្វាយ-សែនជ័យ និងខេត្តស្ទឹងត្រែង ទទួលបានការលើកទឹកចិត្តឱ្យចូលមកអានសៀវភៅនៅបណ្ណាល័យនៃអគារមរតកសង្គម



សិស្សានុសិស្សមកពីអនុវិទ្យាល័យអូរស្វាយ កំពុងស្ដាប់គ្រូបង្រៀន និងចាស់ទុំរៀបរាប់អំពីរឿងរ៉ាវជីវិតឆ្លងកាត់របបខ្មែរក្រហម នៅអគារមរតកសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





រាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)។ បណ្ណាល័យនេះមានបំពាក់នូវអ៊ីនធឺណែតល្បឿនលឿន ដែលអាចឱ្យសិស្សានុសិស្សទាំងអស់មកអានសៀវភៅ និងសិក្សាស្រាវជ្រាវពេលទំនេរពីការសិក្សានៅក្នុងថ្នាក់។

ជាចុងក្រោយ លោកតា សើង សារ៉ាង បានផ្តែផ្តាំទៅសិស្សានុសិស្សទាំងអស់ឱ្យខិតខំរៀនសូត្រ ដើម្បីជួយអភិវឌ្ឍន៍សហគមន៍បុរីអូរស្វាយ-សែនជ័យ និងប្រទេសកម្ពុជាឱ្យកាន់តែរីកចម្រើនទៅមុខទៀត និងធ្វើយ៉ាងណាកុំឱ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញម្តងទៀត។

អគាររមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៃមជ្ឈមណ្ឌលឯកសារកម្ពុជាបើកទទួលសាធារណជន ភ្ញៀវជាតិ និង អន្តរជាតិ កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៤ ហើយចាប់ពីពេលនេះមក មានភ្ញៀវមកទស្សនកិច្ចសិក្សានៅអគារនេះជាបន្តបន្ទាប់។



សិស្សានុសិស្សមកពីអនុវិទ្យាល័យអូរស្វាយ កំពុងស្តាប់គ្រូបង្រៀន និងចាស់ទុំរៀបរាប់អំពីរឿងរ៉ាវជីវិតឆ្លងកាត់របបខ្មែរក្រហម នៅអគាររមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រវត្តិភូមិកំពៃ ឬ ភូមិកុំភ័យ

ឡុង ដានី



ប្រជាជនរស់នៅភូមិកំពៃ ឬកុំភ័យ រៀបរាប់អំពីប្រវត្តិភូមិ និងរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហមប្រាប់ដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ភូមិកំពៃ ឬភូមិកុំភ័យ ជាភូមិចំណាស់មួយក្នុងចំណោមភូមិទាំង១៣ នៃឃុំរំចេក ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ភូមិកំពៃស្ថិតនៅទិសខាងជើងឈៀងខាងលិចឃុំរំចេក និងទីរួមស្រុកមេមត់ក្នុងចម្ងាយប្រមាណជាង៤០គីឡូម៉ែត្រ ដោយធ្វើដំណើរពីចេញពីទីរួមស្រុកមេមត់តាមផ្លូវក្រាលកៅស៊ូទល់មុខផ្សារមេមត់ឆ្ពោះទៅកាន់ឃុំមេមង និងបន្តតាមផ្លូវលេខ ៣៧៣C ត្រង់ចំណុចគីឡូម៉ែត្រលេខ៣៧ ត្រូវបត់ស្តាំប្រមាណ ៧គីឡូម៉ែត្រ គឺជាទីតាំងភូមិកំពៃ ឬភូមិកុំភ័យ។

បើតាមមេភូមិកំពៃ ឬភូមិកុំភ័យ និងចាស់ៗក្នុងភូមិបានឱ្យដឹងថា កាលពីជំនាន់អាណានិគមនិយមបារាំង ភូមិកំពៃ មានឈ្មោះថា ភូមិកុំភ័យ ពីព្រោះនៅពេលទាហានបារាំងចូលមកដល់ក្នុងភូមិ ទាហានបារាំងបានវាយធ្វើបាបអ្នកភូមិ ចាប់មាន់ទា បេះផ្លែដូង និងបានចោទប្រកាន់អ្នកភូមិថា បានចូលដៃចូលជើងជាមួយខ្មែរឥស្សរៈ។ ពេលដែលទាហានបារាំងចូលមកក្នុងភូមិម្តងៗ ប្រជាជនមានការភ័យខ្លាច និងបាននាំគ្នាទៅបន់ស្រន់នៅមុខខ្ទមអ្នកតាដែលស្ថិតនៅក្រោមដើមពោធិ៍នៅចុងភូមិថា កុំភ័យៗ រួចនាំគ្នារត់ចូលក្នុងព្រៃលាក់ខ្លួនរហូតដល់ទាហានបារាំងចេញទៅអស់ពីភូមិ ទើបនាំគ្នាចូលមកនៅក្នុងភូមិវិញធម្មតា។ ចាប់តាំងពីពេលនោះមក អ្នកភូមិ និងប្រជាជនដែលរស់នៅតាមភូមិក្បែរៗនោះ បានហៅឈ្មោះភូមិនេះថា ភូមិកុំភ័យ រហូតមកដល់ជំនាន់សង្គមរាស្ត្រនិយម ពាក្យហៅថាភូមិកុំភ័យនេះក៏បានក្លាយទៅជាភូមិកំពៃ រហូតមកដល់សព្វថ្ងៃនេះ។

កាលពីជំនាន់អាណានិគមនិយមបារាំង ភូមិកំពៃ ឬភូមិកុំភ័យ ជាភូមិដាច់ស្រយាលមួយមានប្រជាជនរស់នៅប្រមាណ៣០ ទៅ៤០គ្រួសារ និងមានប្រជាជនសរុបចំនួនប្រហែល១០០នាក់ប៉ុណ្ណោះ។ នៅបរិវេណជុំវិញ ភូមិកំពៃឬភូមិកុំភ័យ មានព្រៃឈើធំៗ និងសត្វព្រៃជាច្រើនប្រភេទ។ ចំណែកប្រជាជនភាគច្រើនប្រកបរបររកស៊ីធ្វើចម្ការដាំស្រូវ រកអនុផលព្រៃឈើ និងបរបាញ់សត្វព្រៃ។ អ្នកភូមិកំពៃ ឬភូមិកុំភ័យ តែងតែយកអនុផលព្រៃឈើ ដែលខ្លួនរកបានទៅលក់នៅផ្សារឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ។ បន្ទាប់មកទិញអំបិល ប្រហុក និងរបស់របរប្រើប្រាស់ប្រចាំថ្ងៃយកត្រឡប់មកផ្ទះវិញ។ នៅក្នុងសម័យអាណានិគមនិយមបារាំងនេះដែរ ក៏មានចលនាខ្មែរឥស្សរៈធ្វើសកម្មភាពតស៊ូប្រឆាំងនឹងបារាំងនៅក្នុងព្រៃក្បែរៗភូមិកំពៃ និងភូមិមួយចំនួនទៀតក្នុងស្រុកមេមត់។ នៅអំឡុងពេលនោះ ទាហានបារាំងតែងតែចូលមកក្នុងភូមិកំពៃ ឬភូមិកុំភ័យ ស្វែងរកចាប់ខ្លួនមេដឹកនាំចលនាខ្មែរឥស្សរៈ។ បន្ទាប់មក ទាហានបារាំងបានកៀរអ្នកភូមិកំពៃ ឬភូមិកុំភ័យ និងភូមិមួយចំនួនទៀតឱ្យទៅរស់នៅក្នុងភូមិកំពង់រាំងក្នុងស្រុកឆ្លូង ខេត្តក្រចេះជំនួសវិញ។

អ្នកភូមិកំពៃ ឬភូមិកុំភ័យ បានរស់នៅក្នុងភូមិកំពង់រាំងប្រមាណ២ឆ្នាំ ទើបប្រទេសកម្ពុជាទទួលបានឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣ និងបាននាំគ្នាត្រឡប់មករស់នៅក្នុងភូមិកំពៃ ឬភូមិកុំភ័យ វិញ។ នៅក្នុងរបបសង្គមរាស្ត្រនិយមចន្លោះឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧០ ប្រជាជនរស់នៅក្នុងភូមិកំពៃឬភូមិកុំភ័យ បានប្រកបរបរដាំស្រូវ ធ្វើចម្ការ និងរកអនុផលព្រៃឈើ បានសុខសាន្តរហូតដល់១៩៧០។

បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សង្គ្រាមក៏បានចាប់ផ្តើមកើតមាននៅភូមិកំពៃ និងទីកន្លែងផ្សេងទៀតទូទាំងប្រទេសកម្ពុជា។ នៅពេលនោះក៏មានវត្តមានទាហានសហរដ្ឋអាមេរិក ទាហានធីវគី មកច្បាំងជាមួយកងទ័ពវៀតកុង និងកងទ័ពខ្មែរក្រហមនៅតាមជាយៗព្រៃក្បែរៗភូមិកំពៃ។ អំឡុងពេលនោះ យន្តហោះទាហានសហរដ្ឋអាមេរិកបានមកទម្លាក់គ្រាប់បែកលើកងទ័ពវៀតកុងនៅតាមព្រៃ។ ចំណែកអ្នកភូមិកំពៃ ត្រូវជីកលេណដ្ឋាននៅក្បែរៗផ្ទះ ដើម្បីចូលលាក់ខ្លួននៅពេលដែលមានយន្តហោះសហរដ្ឋអាមេរិកមកទម្លាក់គ្រាប់បែកម្តងៗ។

នៅដើមទសវត្សរ៍ឆ្នាំ១៩៧០នេះ ចលនាខ្មែរក្រហមបានចូលមកដល់ភូមិកំពៃ និងភូមិផ្សេងៗទៀតក្នុងឃុំរំចេក ស្រុកមេមត់។ ពេលនោះភូមិកំពៃ ស្ថិតនៅក្នុងសង្កាត់រំចេក ស្រុកមេមត់ តំបន់២១ ភូមិភាគបូព៌ា (ភូមិភាគ២០៣)។ ខ្មែរក្រហមបានចាប់ផ្តើមរៀបចំប្រជាជនជាក្រុម កង និងចាត់តាំងឱ្យធ្វើការងារស្រែចម្ការជាក្រុមប្រវាស់ដៃ ដោយជួយធ្វើការងារស្រែចម្ការគ្នាទៅវិញទៅមកនៅតាមក្រុមនីមួយៗ។ ក្រុមនីមួយៗមានប្រជាជនចំនួន១០ ទៅ ១២គ្រួសារ។ នៅពេលនោះ ថ្នាក់ដឹកនាំខ្មែរក្រហម តំបន់២១ នៃភូមិភាគបូព៌ាម្នាក់ ឈ្មោះ ម៉ៃ ផូ មានស្រុកកំណើតនៅភូមិកំពៃ និងតែងតែចុះមកធ្វើការឃោសនាឱ្យប្រជាជនចូលរួមក្នុងចលនាខ្មែរក្រហមនៅក្នុងភូមិកំពៃ។

នៅក្នុងចុងឆ្នាំ១៩៧៣ ឬដើមឆ្នាំ១៩៧៤ ខ្មែរក្រហមបានរៀបចំឱ្យប្រជាជនក្នុងភូមិកំពៃរស់នៅ និងធ្វើការងារពលកម្មរួមនៅក្នុងសហករណ៍កម្រិតទាប គឺត្រូវយកទ្រព្យសម្បត្តិរបស់របរដាក់រួម ធ្វើស្រែចម្ការរួម និងចែកផលស្រូវទៅតាមសមាជិកគ្រួសារដែលមានកម្លាំងពេញវ័យ ចាស់ជរា និងកុមារប៉ុន្តែខ្មែរក្រហមអនុញ្ញាតឱ្យប្រជាជនហូបនៅតាមផ្ទះរៀងៗខ្លួនបាន។ បន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមរៀបចំប្រជាជនឱ្យរស់នៅក្នុងសហករណ៍ពេញលេញតែម្តង គឺប្រជាជនត្រូវធ្វើការងារពលកម្មរួម និងហូបរួមតែម្តង។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនថ្មី (ប្រជាជន១៧ មេសា) ប្រមាណ៤០ ទៅ៥០គ្រួសារឱ្យមករស់នៅភូមិកំពៃ។ នៅខណៈពេលនោះ ខ្មែរក្រហមបានឃោសនាបោកប្រាស់ឱ្យប្រជាជន១៧ មេសា ដែលជាអតីតទាហាន និងមន្ត្រីរដ្ឋការទៅចុះ

ឈ្មោះ ដើម្បីបានធ្វើទាហាន និងធ្វើការងាររដ្ឋការឡើងវិញ។ ប្រជាជន១៧ មេសា ដែលបានទៅចុះឈ្មោះជាមួយខ្មែរក្រហមត្រូវបានយោធាខ្មែរក្រហមយកទៅសម្លាប់នៅអណ្ដូងវៀតកុង ដែលមានទីតាំងស្ថិតនៅក្នុងភូមិកំពែ។ ចំណែកប្រជាជន១៧ មេសាផ្សេងៗទៀតត្រូវបានស្លាប់ដោយសារជំងឺ និងការអត់អាហារ។ ប្រជាជនមូលដ្ឋាន និងប្រជាជនថ្មីរស់នៅភូមិកំពែត្រូវបានខ្មែរក្រហមចាត់តាំងឱ្យរស់នៅ និងធ្វើការជាមួយគ្នា ដោយបែងចែកទៅតាមកងដូចជាៈ កងកុមារ កងចល័ត កងមីងៗ កងពូៗ កងតាៗ និងកងយាយៗជាដើម។ ចំពោះការហូបចុក ខ្មែរក្រហមបានឱ្យប្រជាជនហូបបបរក្នុងមួយថ្ងៃតែពីរពេល គឺពេលថ្ងៃត្រង់ និងពេលល្ងាចម៉ោង៥។

នៅឆ្នាំ១៩៧៨ កងទ័ពមជ្ឈិមខ្មែរក្រហមបានចូលមកដល់ក្នុងភូមិកំពែ ឃុំរំចេក។ កងទ័ពទាំងនោះបានកោះហៅកម្មាភិបាលខ្មែរក្រហមដែលជាគណៈឃុំរំចេក កងឈ្លប គណៈភូមិ ប្រធានកង ប្រធានក្រុមក្នុងភូមិកំពែ និងភូមិផ្សេងៗទៀតមកប្រជុំនៅផ្ទះសង្គមនិយម ស្ថិតនៅក្នុងភូមិញោ ឃុំរំចេក។ កម្មាភិបាលខ្មែរក្រហមក្នុងឃុំរំចេកសរុបទាំងអស់ប្រមាណ៧០នាក់ បានមកជួបជុំគ្នានៅផ្ទះសង្គមនិយម កងទ័ពមជ្ឈិមខ្មែរក្រហមបានចាប់ចងស្លាបសេក ដើម្បីយកទៅសម្លាប់ចោលនៅក្នុងព្រៃក្បែរភូមិញោ នាពេលយប់។ មុនពេលកងទ័ពមជ្ឈិមខ្មែរក្រហមយកទៅសម្លាប់នោះមានកម្មាភិបាលភូមិចំនួន២នាក់ បានលោតពីលើផ្ទះសង្គមនិយម ដើម្បីរត់គេចខ្លួន។ ក្នុងចំណោមនោះ មានម្នាក់រត់គេចខ្លួនរួច និងម្នាក់ទៀតត្រូវកងទ័ពមជ្ឈិមខ្មែរក្រហមបាញ់សម្លាប់។

បន្ទាប់មកកងទ័ពមជ្ឈិមខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់នៅភូមិកំពែ និងភូមិផ្សេងៗទៀតក្នុងឃុំរំចេកឱ្យទៅរស់នៅភូមិមួយចំនួនក្នុងខេត្តកំពង់ធំនៃភូមិភាគកណ្ដាល។ ប៉ុន្តែក៏មានអ្នកភូមិកំពែមួយចំនួនមានការភ័យខ្លាចកងទ័ពមជ្ឈិមខ្មែរក្រហមសម្លាប់ បាននាំគ្នារត់ទៅរស់នៅក្នុងព្រៃរយៈពេលប្រហែលជាមួយខែក្រោយមក ទើបកងទ័ព០៩ (កងទ័ពភូមិភាគបូព៌ាដែលបះបោរប្រឆាំងនឹងរបបខ្មែរក្រហម) និងកងទ័ពវៀតណាម នាំយកអ្នកភូមិទាំងនោះទៅស្នាក់នៅភូមិខ្នងក្រពើ ស្ថិតនៅទីរួមស្រុកមេមត់ និងបន្តបញ្ជូនទៅរស់នៅក្នុងជំរំជនភៀសខ្លួននៅក្នុងខេត្តតៃនិញ ប្រទេសវៀតណាម ។

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទើបអ្នកភូមិកំពែដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមបានវិលត្រឡប់ពីខេត្តកំពង់ធំ និងប្រទេសវៀតណាមមករស់នៅភូមិកំណើតវិញ។ សព្វថ្ងៃភូមិកំពែ មានប្រជាជនរស់នៅចំនួន២៨៥គ្រួសារ ចំនួនប្រជាជនសរុប១១៥១នាក់ ក្នុងនោះមានស្រីចំនួន៥៨៦នាក់។





ផ្លូវលំក្នុងភូមិកំពែបុកកុំភ័យ ឃុំរំចេក ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# បណ្តាំចុងក្រោយរបស់បងប្រុស

**ស្រ៊ាង លីហ្វារ**

ដំណើរគ្មានថ្ងៃត្រឡប់ ដោយទឹកមុខស្រពោន និងបន្សល់តែបណ្តាំមុនពេលចាកចេញ នេះជារឿងរ៉ាវរបស់អ្នកជាប់ឃុំឃាំងមន្ទីរសន្តិសុខ ស-២១។ តាមរយៈប្រវត្តិរូបអ្នកជាប់ឃុំឃាំងមន្ទីរសន្តិសុខ ស-២១ អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានទៅសម្ភាសន៍ជាមួយប្អូនស្រីរបស់អ្នកជាប់ឃុំឃាំងឈ្មោះ ឡាច កប ដើម្បីដឹងពីរឿងរ៉ាវដែលកើតមានឡើងពីអតីតកាល និងមូលហេតុនៃការចាប់ខ្លួន។ ប្អូនស្រីរបស់ ឡាច កប មានឈ្មោះ ឡាត់ ស៊ុខ អាយុ៦១ឆ្នាំ (ក្នុងឆ្នាំ២០០៦) មានស្រុកកំណើតនៅភូមិតាលាស់ ឃុំតាលាស់ ស្រុកមោងឫស្សី ខេត្តបាត់ដំបង។

បើតាមឯកសារលេខK០៩៣២៨ ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំងតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ឡាច កប មានអាយុ ៣៥ឆ្នាំ (ឆ្នាំ១៩៧៨) ជាប្រជាជនចាស់ និងជាអន្តភាពសហករណ៍វត្តចាស់ រស់នៅភូមិតាលាស់ ឃុំតាលាស់ ស្រុកមោង ខេត្តបាត់ដំបង តំបន់៤ ភូមិភាគពាយ័ព្យ។ កប មានប្រពន្ធឈ្មោះ ម៉ៃ វិច រស់នៅសហករណ៍ត្រស់ និងមានកូនប្រុស២នាក់។ កប មានឪពុកឈ្មោះ ឡាច ឡាត់ និងម្តាយឈ្មោះ ស៊ី កាយ។ កប មានបងប្អូនចំនួន៧នាក់ (ស្រី២នាក់ និងប្រុស៥នាក់)។ បងប្រុសទី១ ឈ្មោះ ឡាត់គីម, បងស្រីទី២ ឈ្មោះ ឡាត់គួម, ទី៣ ឈ្មោះ ឡាត់កប (ឡាចកប), ប្អូនស្រីទី៤ ឡាត់សុខ, ប្អូនប្រុសទី៥ ឈ្មោះ ឡាត់កើត, ប្អូនប្រុសទី៦ ឈ្មោះ ឡាត់ធឿន និងប្អូនប្រុសពៅ ឈ្មោះ ឡាត់ ធី។ ឡាច កប ត្រូវបានកងទ័ពភូមិភាគនិរតីចាប់ខ្លួន និងម្នាក់ទៀត ឈ្មោះ ឡាត់ ធឿន បានបាត់ខ្លួនក្នុងរបបខ្មែរក្រហមដោយគ្មានដំណឹង។




ប្រវត្តិរូបរបស់ ឡាច កប ដែលសន្តិសុខខ្មែរក្រហមធ្វើឡើងបន្ទាប់ពីចាប់ខ្លួន និងសួរចម្លើយ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តាមរយៈកិច្ចសម្ភាសន៍ជាមួយ សុខ នៅមុនឆ្នាំ១៩៧០ កប ចូលរៀននៅសាលាបឋមសិក្សាតាលាស់ និងបន្តរៀនឌីប្លូមនៅសាលាសោហ៊ើរ ត្រឹមថ្នាក់ទី៥ នៅក្រុងបាត់ដំបង។ ក្រោយមក កប បានឈប់រៀន និងឈ្មោះ ឡាច កប ត្រឡប់មកភូមិជួយការងារស្រែចម្ការឪពុកម្តាយ។

នៅឆ្នាំ១៩៧៤ ទាហាន លន់ នល់ បានកែនប្រជាជនក្នុងភូមិរួមទាំង កប ឱ្យចូលធ្វើទាហាន លន់ នល់ ក្នុងបន្ទាយភូមិតាលាស់។ កប បានធ្វើជាទាហានអស់រយៈពេល ១ឆ្នាំ រហូតដល់របប លន់ នល់ ដួលរលំ។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានឡើងកាន់កាប់អំណាចនៅទូទាំងប្រទេស។ កប និងគ្រួសារត្រូវបានបញ្ជូនឱ្យទៅរស់នៅភូមិសាគរ អស់រយៈពេលជាងមួយខែ។ ក្រោយមក កប ទៅរស់នៅភូមិទួលស្តៅ ដើម្បីធ្វើស្រែ និងនេសាទត្រី។ នៅភូមិទួលស្តៅ គឺមានការហូបចុកគ្រប់គ្រាន់ ដោយខ្មែរក្រហមចែករបបអង្ករឱ្យហូបតាមផ្ទះ ក្នុងមួយថ្ងៃម្នាក់មួយកំប៉ុង។ កប និង សុខ ត្រូវងើបពីព្រលឹមទៅភ្ជួរស្រែ ដកស្ទូង និងកាប់ព្រៃ អស់រយៈពេលមួយឆ្នាំ។

នៅឆ្នាំ១៩៧៦ ម្តាយរបស់ កប បានស្លាប់ដោយសារជំងឺរាក និងគ្មានថ្នាំព្យាបាល។ ចំណែកឪពុកបានស្លាប់តាំងពីមុនរបបខ្មែរក្រហម។ នៅចុងឆ្នាំដដែល បរិមាណអង្ករសម្រាប់ហូបចុក គឺមានការធ្លាក់ចុះ។ ប្រជាជនហូបចុកមិនគ្រប់គ្រាន់ បណ្តាលឱ្យស្លាប់ដោយសារអត់ឃ្លាន និងជំងឺផ្សេងៗរួមទាំងម្តាយរបស់អ្នកទាំងពីរ។ បន្ទាប់មក កប និងគ្រួសារត្រូវបានចាត់តាំងឱ្យទៅរស់នៅភូមិត្រស់ ដែលមានឈ្មោះ រី (ប្រុស) ជាប្រធានសហករណ៍នៅទីនោះ។ រី គឺជាអ្នកភូមិជាមួយ កប ដែលស្គាល់គ្នាតាំងពីកុមារភាពមក។ នៅភូមិត្រស់តំបន់៤ ភូមិភាគពាយ័ព្យ គឺជាសហករណ៍សម្រាប់ប្រជាជនថ្មី ដែលខ្មែរក្រហមជម្លៀសចេញពីស្រុកមោងឫស្សី។ ប្រជាជនចាស់នៅភូមិផ្សេងមានការហូបចុកគ្រប់គ្រាន់ ប៉ុន្តែសម្រាប់ប្រជាជនថ្មីនៅភូមិត្រស់ ត្រូវធ្វើការលត់ដំ ជីកប្រឡាយ លើកទំនប់ និងបង្កបង្កើនផលស្រូវ។ នៅក្នុងសហករណ៍ត្រូវធ្វើការរួម ដូចជា ធ្វើស្រែចម្ការ និងរែកទឹក។ នៅភូមិត្រស់ ប្រជាជននៅបន្តហូបចុកមិនបានគ្រប់គ្រាន់។ ជួនកាលប្រជាជនគ្មានបបរសម្រាប់ហូប និងហូបតែពោតក្រៀម និងកន្ទក់ជំនួស។ នៅអំឡុងខែវស្សា ការហូបចុកតែងតែខ្វះខាត និងប្រជាជនហូបតែបបរប៉ុណ្ណោះ។ ចំណែកនៅខែប្រាំង គឺមានបាយសម្រាប់ឱ្យប្រជាជនហូប។

នៅពេលនោះក្នុងសហករណ៍ត្រស់នៅមានចែកអង្ករតាមផ្ទះ ធ្វើស្រែ និងនេសាទត្រីតាមមូលដ្ឋាននៅឡើយ។ ប្រជាជនក្នុងភូមិទាំងអស់ ត្រូវបានកងទ័ពភូមិភាគពាយ័ព្យស្រាវជ្រាវប្រវត្តិរូប ចំពោះអ្នកណាដែលមានប្រវត្តិធ្វើជាមន្ត្រីឬជាទាហានក្នុងរបប លន់ នល់។ ទោះបីជាដឹងថា កប ធ្លាប់ធ្វើជាទាហាន លន់ នល់ ប៉ុន្តែ កប ត្រូវបានអត់ឱន ដោយសារតែមានបងប្អូនជាកងទ័ពខ្មែរក្រហម។

នៅអំឡុងឆ្នាំ១៩៧៦ ប្រជាជនដែលបន្តដំណើរពីទីក្រុងភ្នំពេញ និងប្រជាជនមកពីភូមិភាគបូព៌ា (ខេត្តស្វាយរៀងនិងខេត្តព្រៃវែង) ត្រូវបានខ្មែរក្រហមជម្លៀសតាមរថភ្លើង និងចុះនៅស្ថានីយរថភ្លើង ស្រុកមោងឫស្សី។ បន្ទាប់មកប្រជាជនទាំងនោះត្រូវខ្មែរក្រហមចាត់ឱ្យទៅរស់នៅតាមសហករណ៍។ នៅពេលប្រជុំនៅឃ្លាំងអង្ករ មានអ្នកមកពីភ្នំពេញម្នាក់ដែលលួចអង្ករ ហូបត្រូវខ្មែរក្រហមចាប់ខ្លួន និងវាយដំដោយចងភ្ជាប់នឹងដើមឈើយ៉ាងអាណោចអធ័ម។ អ្នកភ្នំពេញម្នាក់នេះ គឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សជាង៥០ម៉ឺននាក់ដែលត្រូវបានជម្លៀសពីភូមិភាគផ្សេងៗទៅកាន់ភូមិភាគពាយ័ព្យ។

នៅចុងឆ្នាំ១៩៧៧ កងទ័ពភូមិភាគនិរតីបានចូលមកគ្រប់គ្រងភូមិពាយ័ព្យ និងប្រកាសឱ្យកងទ័ពភូមិភាគពាយ័ព្យទម្លាក់កាំភ្លើងចុះ។ បន្ទាប់ពីរដ្ឋប្រហារកាត់មួយខែដំបូងនៃការគ្រប់គ្រងដោយកងទ័ពភូមិភាគនិរតី គឺមានបាយឱ្យប្រជាជនហូប។ ប៉ុន្តែមិនយូរប៉ុន្មានប្រជាជនដែលជម្លៀសមកពីភូមិភាគបូព៌ាពីមុនមកត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ ក្រោយពីធ្វើប្រវត្តិរូបតាមបញ្ជាកងទ័ពភូមិភាគនិរតី។ អ្នករស់នៅភូមិត្រស់ដែលជាអ្នកជម្លៀសមកពីភូមិភាគបូព៌ាត្រូវសម្លាប់ដោយគ្មានការអត់ឱន។

នៅឆ្នាំ១៩៧៨ ប្រជាជនមូលដ្ឋានក៏ត្រូវបានចាប់ខ្លួនដោយកងទ័ពភូមិភាគនិរតី។ ប្រធានសហករណ៍ឈ្មោះ រី ដែលជាបងប្អូនជាមួយប្រពន្ធរបស់ កប ត្រូវបានកងទ័ពភូមិនិរតីចាប់ចង និងសម្លាប់ ដោយចោទថាជាខ្សែបណ្តាញរបស់វៀតណាម។ ចំពោះគណៈតំបន់នៃភូមិភាគពាយ័ព្យណាដែលរត់គេចខ្លួន នោះ

ប្រពន្ធកូននិងត្រូវដឹកតាមរទេះយកទៅសម្លាប់នៅទួលតាង្វួកៗ កងទ័ពភូមិភាគនិរតីក៏ស្រាវជ្រាវរួមទាំងបងប្អូនរបស់អ្នកដែលរត់គេចខ្លួននោះៗ មនុស្សប្រហែលជា ៤ទៅ៥នាក់ ត្រូវបានចងបណ្តើរកាត់តាមវាលស្រែ យកទៅទីតាំងប្រឡាយផ្តៅ ដែលប្រជាជនស្គាល់ថាជាព្រៃខ្មោច ទាំងអស់សង្ឃឹម មុនពេលត្រូវវាយសម្លាប់ៗ

នៅឆ្នាំ១៩៧៨ ថ្ងៃមួយឈ្មោះ ង៉ែត ដែលជាប្រពន្ធគណៈឃុំឈ្មោះ ឈឺនបានមកហៅ កប ដោយប្រាប់ថា «មានគេឱ្យមកហៅ»ៗ ង៉ែត គឺជាកងសេដ្ឋកិច្ចនិងជាអ្នករស់នៅជាប់ភូមិផងរបងជាមួយគ្រួសាររបស់ កបៗ នៅពេលនោះ កប បានធ្វើដំណើរសំដៅទៅភូមិកាប់រទេះ ទាំងគ្មានសង្ឃឹម ដោយដឹងថា ភូមិកាប់រទេះ គឺជាទីតាំងមន្ទីរឃុំឃាំងៗ កប បាននិយាយទៅកាន់ប្អូនស្រី សុខ ថា «បងលាហើយមើលកូនឱ្យបងផង»ៗ ចាប់តាំងពីថ្ងៃនោះមក កប បានបាត់ខ្លួនរហូតមកដល់សព្វថ្ងៃៗ នៅចុងឆ្នាំ១៩៧៨ សុខ ត្រូវបានខ្មែរក្រហមជម្លៀសទៅពុស្សក្រាំង និងបន្តដំណើររហូតដល់អាង ១៧ មេសា ជាប់ព្រំប្រទល់រវាងខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ៗ

នៅឆ្នាំ១៩៧៩ សុខ បានត្រឡប់មកស្រុកវិញ ដោយធ្វើដំណើរអស់រយៈពេលជិតមួយខែ និងរស់នៅភូមិជ្រៃជើង ឃុំជ្រៃ ស្រុកមោងឫស្សី ខេត្តបាត់ដំបងៗ

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ម្តាយរបស់ កប បានស្លាប់ដោយសារជំងឺ កប និងប្អូនប្រុសឈ្មោះ ធឿន បានបាត់ខ្លួនៗ ក្រៅពីការសម្លាប់ ប្រជាជនក្នុងរបបខ្មែរក្រហមត្រូវស្លាប់ដោយសារជំងឺ ការធ្វើពលកម្មហួសកម្លាំង និងការហូបចុកមិនគ្រប់គ្រាន់ៗ លើសពីនេះ អ្នកដែលប្រព្រឹត្តអំពើខុសសីលធម៌ ឬលួចលាក់មានស្នេហា នឹងត្រូវខ្មែរក្រហមសម្លាប់ទាំងគូៗ



រូបថតអ្នកទោសនៅមន្ទីរសន្តិសុខស-២១ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រឿងរ៉ាវរបស់គ្រួសារ ឈឹម ហ៊ីន អំឡុងពេលខ្មែរក្រហមជម្លៀសទៅកាន់ខេត្តពោធិ៍សាត់

សោម ប៊ុនថន



ឈឹម ហ៊ីន រស់នៅភូមិដូង (បច្ចុប្បន្នភូមិបារិតលើ) សង្កាត់បារិត ស្រុកចន្ទ្រា (បច្ចុប្បន្នក្រុងបារិត) ខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីខ្មែរក្រហមឡើងគ្រប់គ្រងអំណាច ខ្មែរក្រហមបានជម្លៀសប្រជាជននៅទូទាំងប្រទេសចេញពីផ្ទះសម្បែងឱ្យទៅកាន់ទីជនបទដាច់ស្រយាល និងតំបន់ផ្សេងក្នុងប្រទេសកម្ពុជាដើម្បីធ្វើការងារពលកម្មធ្ងន់ធ្ងរ ក្នុងនោះក៏មានក្រុមគ្រួសារ ឈឹម ហ៊ីន ដែរ។ ឈឹម ហ៊ីន បានរៀបរាប់អំពីប្រវត្តិ និងរឿងរ៉ាវដែលបានកើតឡើងនៅក្នុងភូមិកំណើត រហូតដល់ខ្មែរក្រហមជម្លៀសគាត់ទៅរស់នៅក្នុងខេត្តពោធិ៍សាត់ បណ្តាលឱ្យសមាជិកគ្រួសាររបស់គាត់ស្លាប់។

ខ្ញុំឈ្មោះ ឈឹម ហ៊ីន អាយុ៦៧ឆ្នាំ កើតនៅភូមិដូង (បច្ចុប្បន្នភូមិបារិតលើ) សង្កាត់បារិត ស្រុកចន្ទ្រា ខេត្តស្វាយរៀង។ ខ្ញុំមានឪពុកឈ្មោះ ឈឹម ជើង និងម្តាយឈ្មោះ យឹម ទើង។ ឪពុកម្តាយខ្ញុំស្លាប់អស់ហើយ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៩នាក់ គឺស្រី៥នាក់ និងប្រុស៤នាក់ ហើយសព្វថ្ងៃនៅរស់តែ២នាក់ប៉ុណ្ណោះ។ ខ្ញុំមានប្តីឈ្មោះ បូស សាវិន អាយុ៦០ និងមិនមានកូនទេ។

នៅពេលលន់នល់ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ឆ្នាំ១៩៧០ នៅក្នុងភូមិរបស់ខ្ញុំមានការប្រែប្រួលដោយសារមានកងកម្លាំងបដិវត្តន៍ខ្មែរក្រហម (ខ្លះរស់នៅក្នុងស្រុកចន្ទ្រា និងខ្លះទៀត

មកពីខេត្តព្រៃវែង) លួចចូលមកឃោសនានៅក្នុងភូមិនៅពេលយប់ ព្រោះទាហាន លន់ នល់ ដើរល្បាតនៅក្នុងភូមិតែពេលថ្ងៃប៉ុណ្ណោះ ហើយពេលយប់ក៏ដកត្រឡប់ទៅប្រចាំការនៅប៉ុស្តិ៍ជាប់ព្រំដែនវៀតណាមវិញ។ ដូច្នេះ នៅពេលយប់ប្រជាជនក្នុងភូមិមិនហ៊ានជជែកគ្នាទេ ព្រោះខ្លាចខ្មែរក្រហមលបស្តាប់។ ប្រជាជននៅក្នុងភូមិនាំគ្នាសម្ងំដេកនៅផ្ទះរៀងៗខ្លួន។ ទន្ទឹមនោះកងទ័ព លន់ នល់ ក៏ធ្វើការទម្លាក់គ្រាប់បែកនៅតាមព្រៃឆ្ងាយៗពីភូមិដែលខ្ញុំរស់នៅ ព្រោះគិតថាកងកម្លាំងបដិវត្តន៍ខ្មែរក្រហមបានសំងំលាក់ខ្លួននៅទីនោះ។ ថ្ងៃខ្លះកងទ័ព លន់ នល់ បានវាយប្រយុទ្ធតទល់ជាមួយកងកម្លាំងរំដោះខ្មែរក្រហមក្នុងមួយថ្ងៃពីរទៅបីដង នៅពេលដើរល្បាតនៅតាមថ្នល់ហើយជួបគ្នា ហើយពេលខ្លះទៀតក៏មានគ្រាប់ផ្លោងធ្លាក់មកក្បែរៗភូមិដែរ។ ជារឿយៗឧទ្ធម្ភាគចក្ររបស់ លន់ នល់ បានហោះឆ្វែលពិនិត្យមើលសកម្មភាពរបស់កងកម្លាំងបដិវត្តន៍ខ្មែរក្រហមនៅតាមភូមិ។ នៅអំឡុងពេលនោះ កងទ័ព លន់ នល់ ក៏បានបញ្ជូនជនអន្តោប្រវេសន៍វៀតណាមដែលមករស់នៅបាវិត ខេត្តស្វាយរៀង ឱ្យត្រឡប់ទៅរស់នៅប្រទេសវៀតណាមវិញដែរ។

បន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់ សម្តេចព្រះ នរោត្តម សីហនុ បានមួយរយៈ បងប្រុសរបស់ខ្ញុំឈ្មោះ ឈឹម ឆន បានឈប់រៀន ដើម្បីទៅបម្រើកងទ័ពបដិវត្តន៍ខ្មែរក្រហមតាមការឃោសនា។ ពេលនោះបងប្រុសរបស់ខ្ញុំរៀននៅសាលាកាឡេះ (អនុ-វិទ្យាល័យ) ក្នុងសង្កាត់បាវិត។ មុននឹងបងខ្ញុំចាកចេញពីផ្ទះ គាត់បានមកសុំឪពុករបស់ខ្ញុំថា «សុំទៅចូលបម្រើបដិវត្តន៍ខ្មែរក្រហម»។ ពេលនោះ ឪពុករបស់ខ្ញុំបានហាមឃាត់បង ឆន មិនឱ្យទៅទេ ព្រោះគាត់មានកូនប្រុសតែម្នាក់។ ប៉ុន្តែឪពុករបស់ខ្ញុំឃាត់យ៉ាងណា ក៏បងប្រុសរបស់ខ្ញុំមិនស្តាប់ដែរ។ បងប្រុសរបស់ខ្ញុំបានចាកចេញទៅជាមួយឈ្មោះ តាន រស់នៅក្នុងភូមិតាពៅ ឃុំបាវិត រួមជាមួយយុវជនជាច្រើននាក់ទៀត ប៉ុន្តែខ្ញុំមិនចាំឈ្មោះ។ បន្ទាប់ពីបង ឆន ចេញទៅបានមួយរយៈ គាត់បានសរសេរសំបុត្រផ្ញើមកឪពុកម្តាយរបស់ខ្ញុំ។ បងប្រុសខ្ញុំបានផ្តល់ដំណឹងមកថា គាត់នៅផ្នែកកាំភ្លើងធំ ប្រចាំនៅទន្លេបិត ក្នុងខេត្តកំពង់ចាម ប៉ុន្តែខ្ញុំមិនដឹងថាគាត់នៅកងឬអង្គភាពលេខប៉ុន្មានទេ ព្រោះខ្ញុំនៅក្មេង និងមិនសូវយល់ដឹងច្រើន។ បង ឆន បានផ្ញើសំបុត្រមកឱ្យឪពុកម្តាយខ្ញុំបីដង អំឡុងពេលគាត់ចេញទៅតស៊ូជាមួយខ្មែរក្រហម។

នៅពេលកងទ័ពខ្មែរក្រហមឡើងគ្រប់គ្រងប្រទេសកម្ពុជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់ខ្ញុំប្រកបរបរធ្វើស្រែ និងរស់នៅក្នុងភូមិដូងដដែល។ នៅពេលនោះ បង ឆន បានមកលេងឪពុកម្តាយរបស់ខ្ញុំនៅផ្ទះ។ បង ឆន មិនទាន់មានប្រពន្ធទេ។ ខ្ញុំឃើញបង ឆន មានកាំភ្លើងខ្លីសៀតនៅចង្កេះខោរបស់គាត់។ ឪពុកម្តាយរបស់ខ្ញុំ និងបងប្អូនរបស់ខ្ញុំសប្បាយរីករាយខ្លាំងណាស់ពេលបានជួបបង ឆន។ យើងបានក្រាលកន្ទេល ហូបបាយជុំគ្នាជាមួយបងប្អូន និងមីងមា។ មុនពេលបង ឆន មកលេងផ្ទះឪពុកម្តាយរបស់ខ្ញុំចិញ្ចឹមជ្រូកបានទម្ងន់១០០គីឡូ ហើយត្រូវទាហានបាញ់សំាប់ ទើបឪពុកម្តាយខ្ញុំយកសាច់ជ្រូកនោះមកប្រឡាក់និងធ្វើផ្អកទុក។ ឪពុកម្តាយរបស់ខ្ញុំបានយកសាច់ជ្រូកនោះមកធ្វើម្ហូបដើម្បីទទួលបង ឆន តែម្តង។ ខ្ញុំនិងបងប្អូនខ្ញុំក៏បាននាំបង ឆន ដើរលេងនៅក្នុងភូមិ។ បង ឆន ស្នាក់នៅផ្ទះបានរយៈពេល១០ថ្ងៃ ក៏ត្រឡប់ទៅធ្វើការនៅអង្គភាពទ័ពរបស់គាត់វិញ ហើយបាត់ដំណឹងរហូត។ មុនពេលត្រឡប់ទៅវិញ បង ឆន បានឱ្យរូបថតរបស់គាត់ ដែលបានថតជុំគ្នាជាមួយឈ្មោះ តាន់ ពេលចេញទៅតស៊ូនៅក្នុងព្រៃមកឱ្យឪពុកម្តាយរបស់ខ្ញុំមើល និងរក្សាទុក។ ក្រោយមក រូបថតនោះក៏បាត់។

នៅពេលបង ឆន ចាកចេញបានមួយរយៈ ខ្មែរក្រហមបានប្រមូលប្រជាជនឱ្យធ្វើស្រែតាមក្រុមប្រវាស់ដៃ និងបង្កើតជាសហករណ៍។ ចំណែកខ្ញុំ ខ្មែរក្រហមប្រើឱ្យកិនអង្ករ រែកដី ស្ទូង ដក នៅក្នុងភូមិដូង។ ពេលនោះ ប្រធានសង្កាត់បាវិតឈ្មោះ ឌុត គឺជាអ្នកស្រុកនេះតែម្តង។ មួយរយៈក្រោយមក ខ្មែរក្រហមក៏ជម្លៀសប្រជាជនមកពីស្រុកមានជ័យថ្មី (បច្ចុប្បន្នស្រុកស្វាយជ្រំ ខេត្តស្វាយរៀង) ឱ្យមកនៅស្នាក់នៅផ្ទះរបស់ខ្ញុំ។ ចំណែកប្រជាជនថ្មីដែលជម្លៀសមកពី

ភ្នំពេញ និងតំបន់ផ្សេងៗទៀត ខ្មែរក្រហមយកទៅដាក់នៅវត្តពោធិ៍ថ្មី ស្ថិតនៅក្នុងសង្កាត់បារិតៗ ប្រជាជនជម្លៀសមកថ្មីទាំងនោះភាគច្រើនជាប់សែស្រឡាយចិន និងវៀតណាមៗ រយៈពេល២-៣ថ្ងៃក្រោយ ប្រជាជនថ្មីដែលជាប់សែស្រឡាយចិន និងវៀតណាម ទាំងនោះ ក៏បាត់ខ្លួនពីវត្តពោធិ៍ថ្មីទាំងអស់ មិនដឹងខ្មែរក្រហមបញ្ជូនទៅណាទៀតទេៗ នៅសម័យនោះ សូម្បីតែជនជាតិខ្មែរដែលយកប្រពន្ធឬប្តីជនជាតិវៀតណាម ក៏ខ្មែរក្រហមឱ្យបំបែកគ្នាដែរ ហើយប្តី ឬប្រពន្ធជនជាតិវៀតណាម ទាំងនោះភាគច្រើនបាត់ខ្លួនមិនដឹងទៅណាឡើយៗ ដាក់ស្តែងពូរបស់ខ្ញុំឈ្មោះ យ៉ាត់ ជនជាតិខ្មែរ យកប្រពន្ធជនជាតិវៀតណាម ត្រូវខ្មែរក្រហមយកទៅបាត់ទាំងគ្រួសារតែម្តងៗ បន្ទាប់ពីប្រជាជនដែលជាប់សែស្រឡាយចិន និងវៀតណាមចេញអស់ ខ្មែរក្រហមយកព្រះវិហារវត្តពោធិ៍ថ្មី ធ្វើជាកន្លែងផលិតជី ដោយយកដើមទន្រ្ទានខែត្រមកកាត់ចិញ្ច្រាំលាយច្របល់ជាមួយលាមកមនុស្ស, សត្វ និងដីដំបូកៗ

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមប្រមូលក្រុមធ្វើស្រែប្រវាស់ដៃ និងសហករណ៍បញ្ចូលគ្នាៗ បន្ទាប់មក ទើបខ្មែរក្រហមប្រមូលប្រជាជនមកហូបបាយរួម ដោយមានចុងភៅចែករបបអាហារឱ្យម្នាក់មួយចានរួច ហើយចេញទៅធ្វើការរៀងៗខ្លួនៗ អំឡុងពេលនោះខ្មែរក្រហមក៏ចាប់ខ្លួនប្រជាជនដែលប្រព្រឹត្តខុស និងអ្នកដែលត្រូវបានចោទប្រកាន់យកទៅដាក់នៅមន្ទីរសន្តិសុខទប់ខ្សាច់ (ស្ថិតនៅជិតសាលាស្រុកចន្ទ្រាសព្វថ្ងៃ)ៗ ពេលយប់ខ្មែរក្រហមឃុំឃាំងអ្នកទោសទាំងនោះ ហើយពេលថ្ងៃឆ្នាំគុកបណ្តើរអ្នកទោសទាំងនោះទៅធ្វើការនៅខាងជើងចុងសំរិទ្ធៗ ក្នុងចំណោមអ្នកទោសទាំងនោះក៏មានបងថ្លៃរបស់ខ្ញុំឈ្មោះ ម៉ិ ផន ដែលត្រូវជាប្តីរបស់បងស្រីខ្ញុំឈ្មោះ ឈឹម សឿន ដែរៗ មូលហេតុដែលចាប់បងថ្លៃរបស់ខ្ញុំទៅដាក់មន្ទីរសន្តិសុខគឺមុនពេលខ្មែរក្រហមឡើងគ្រប់គ្រងប្រទេស បងថ្លៃរបស់ខ្ញុំបានយកក្របីឡើងមួយនឹមទៅដូរជាមួយប្រជាជនរស់នៅខាងលិចភូមិដូង បានម៉ូតូវេស្ប៉ាមួយគ្រឿងពណ៌សៗ បន្ទាប់ពីខ្មែរក្រហមឡើងគ្រប់គ្រងអំណាច ប្រធានសង្កាត់បារិតឈ្មោះ តា ឌុត បានស្នើខ្ចីម៉ូតូពីបងថ្លៃរបស់ខ្ញុំថាយកទៅជិះធ្វើការតាមភូមិ ប៉ុន្តែបងថ្លៃរបស់ខ្ញុំមិនឱ្យខ្ចី ទើប តា ឌុត ខឹង និងគុំបងថ្លៃរបស់ខ្ញុំៗ ក្រោយមក តា ឌុត បានចោទបងថ្លៃរបស់ខ្ញុំ ហើយចាប់បងថ្លៃរបស់ខ្ញុំយកទៅដាក់នៅមន្ទីរសន្តិសុខទប់ខ្សាច់ៗ រយៈពេល៣ខែក្រោយមក ប្រធានសន្តិសុខទប់ខ្សាច់បានដោះលែងបងថ្លៃរបស់ខ្ញុំ និងប្រជាជនផ្សេងទៀតឱ្យត្រឡប់មកផ្ទះវិញ លើកលែងតែអតីតទាហាន (ពីសង្គមចាស់) ដែលខ្មែរក្រហមមិនដោះលែង ហើយក្រោយមកយកទៅសម្លាប់ចោល ទាំងអស់ៗ

នៅឆ្នាំ១៩៧៦ ដដែល ខ្មែរក្រហមបានជម្លៀសខ្ញុំចេញពីភូមិដូង ឃុំបារិត ទៅនៅឃុំព្រៃគគីរ ក្នុងស្រុកចន្ទ្រា ដដែលៗ មុននឹងជម្លៀសគ្រួសារខ្ញុំ ខ្មែរក្រហមបានជម្លៀសប្រជាជនថ្មី (ប្រជាជន ១៧មេសា) ដែលមកស្នាក់នៅផ្ទះខ្ញុំចេញទៅអស់ហើយៗ ដូច្នេះនៅក្នុងភូមិកំណើតរបស់ខ្ញុំលែងមានប្រជាជនរស់នៅទៀតហើយ ហើយផ្លូវក៏គ្មានមនុស្សដើរដែរៗ ខ្ញុំរស់នៅឃុំព្រៃគគីរបានរយៈពេលមួយខែ ទើបខ្មែរក្រហមជម្លៀស ខ្ញុំនិងគ្រួសារបន្តទៅនៅភូមិធំ និងអំពិលព្រៃ ស្ថិតនៅខាងជើងទីរួមខេត្តស្វាយរៀងៗ ខ្មែរក្រហមមិនបានប្រកាសប្រាប់អំពីមូលហេតុច្បាស់លាស់នៃការជម្លៀសនោះទេគឺគ្រាន់តែប្រាប់ឱ្យយើងចាកចេញ ហើយក្រុមគ្រួសាររបស់ខ្ញុំ និងប្រជាជននៅសង្កាត់បារិតបានចេញទៅតាមគ្នាជាបន្តបន្ទាប់ៗ ពេលធ្វើដំណើរ ឪពុកម្តាយរបស់ខ្ញុំមានកូនរទេះមួយសម្រាប់ដឹករបស់របរ និងអង្ករ ហើយខ្ញុំដើរតាមក្រោយៗ ខ្ញុំទៅនៅភូមិធំ និងភូមិអំពិលព្រៃ បានរយៈពេលមួយខែ ឪពុករបស់ខ្ញុំក៏ធ្លាក់ខ្លួនឈឺធ្ងន់ហើយស្លាប់នៅទីនោះៗ អំឡុងពេលជម្លៀសឆ្នាំ១៩៧៦ ក៏មានប្រជាជនខ្មែរមួយចំនួនបានភៀសខ្លួនទៅប្រទេសវៀតណាមដែរៗ ដំបូងឪពុកម្តាយរបស់ខ្ញុំក៏ចង់ភៀសខ្លួនទៅប្រទេសវៀតណាមដែរ ប៉ុន្តែមិនដាច់ចិត្តពីកូនៗដែលរស់នៅប្រទេសកម្ពុជាៗ ម្យ៉ាងទៀត ឪពុកម្តាយខ្ញុំបារម្ភខ្លាចពេលគាត់រត់ទៅប្រទេសវៀតណាម ខ្មែរក្រហមសម្លាប់កូនៗរបស់គាត់ៗ ទោះបីយ៉ាងណា ប្រជាជន

ខ្មែរដែលរត់ភៀសខ្លួនទៅប្រទេសវៀតណាម ទាំងនោះ ក៏ប្រឈមនឹងគ្រោះថ្នាក់ដែរ ព្រោះប្រសិនបើខ្មែរក្រហមចាប់ខ្លួនបាន គឺខ្មែរក្រហមយកជនភៀសខ្លួនទាំងនោះទៅឃុំឃាំង និងសម្លាប់ចោលតែម្តង។ ជាក់ស្តែង អំឡុងពេលខ្ញុំរស់នៅក្នុងភូមិដូង ខ្មែរក្រហមបានយកក្របីទៅដូរយកប្រជាជនខ្មែរដែលរត់ភៀសខ្លួនទៅនៅវៀតណាមពីអាជ្ញាធរវៀតណាមមកសម្លាប់ចោល។ មួយថ្ងៃខ្មែរក្រហមបញ្ជូនជនភៀសខ្មែរទៅសម្លាប់ពីរដង។ ខ្មែរក្រហមបានវាយសម្លាប់ជនភៀសខ្លួនខ្មែរ ទាំងនោះទម្លាក់ចូលទៅក្នុងអន្លង់ត្រពាំង នឹងរណ្តៅនៅតាមវាលស្រែ ស្ថិតក្នុងសង្កាត់បារិត ដោយក្នុងមួយអន្លង់ ឬមួយរណ្តៅមានមនុស្ស៣នាក់ៗ សាកសពណាដែលកប់មិនជិតត្រូវបានឆ្កែកាយ និងខាំពាំមកខាងក្រៅរណ្តៅ។ ខ្មែរក្រហមសម្លាប់ជនភៀសខ្លួនខ្មែរ ទាំងនោះមិនឱ្យប្រជាជនក្នុងភូមិដឹងឡើយ គឺភាគច្រើនហៅជនភៀសខ្លួនខ្មែរដែលដូរពីអាជ្ញាធរវៀតណាមថា ទៅធ្វើការនេះ ឬធ្វើការនោះ តាមពិតគឺយកទៅសម្លាប់ចោល។ ខ្មែរក្រហមបានកៀងក្របី ទាំងហ្វូងៗទៅដូរយកជនភៀសខ្លួនខ្មែរត្រឡប់មកវិញ ដោយក្របីមួយក្បាលដូរយកជនភៀសខ្លួនខ្មែរម្នាក់។ ខ្មែរក្រហមបានដឹងថា សមាជិកគ្រួសារណាខ្លះរត់ភៀសខ្លួនទៅប្រទេសវៀតណាម ហើយពេលនាំយកពីប្រទេសវៀតណាមត្រឡប់មកវិញ ក៏មិនឱ្យអ្នកទាំងនោះមកជួបជុំជាមួយគ្រួសារដែរ គឺទុកនៅកន្លែងផ្សេងៗ នៅថ្ងៃបន្ទាប់គឺបញ្ជូនអ្នកទាំងនោះទៅបាត់តែម្តង។ ក្រោយមក ទើបជនភៀសខ្លួនខ្មែរដែលរស់នៅប្រទេសវៀតណាមស៊ើបដឹងថា ខ្មែរក្រហមបានយកសាច់ញាតិរបស់ខ្លួនដែលត្រូវអាជ្ញាធរវៀតណាមបញ្ជូនមកប្រទេសកម្ពុជាវិញទៅសម្លាប់ចោល ទើបស្នើទៅអាជ្ញាធរវៀតណាមកុំឱ្យបញ្ជូនជនភៀសខ្លួនខ្មែរមកដូរយកក្របីជាមួយខ្មែរក្រហមទៀត។ ជនភៀសខ្លួនខ្មែរមួយចំនួនដែលមានប្រពន្ធជនជាតិវៀតណាម ត្រូវបានប្រពន្ធធានាជាមួយអាជ្ញាធរវៀតណាម ស្នើសុំឱ្យប្តីបន្តស្នាក់នៅវៀតណាមដោយមូលហេតុឱ្យប្តីនៅថែទាំព្រោះខ្លួនមានផ្ទៃពោះ។ ជាក់ស្តែង បងប្រុសរបស់ខ្ញុំដែលរត់ភៀសខ្លួនទៅប្រទេសវៀតណាម និងមានប្រពន្ធនៅកាយ៉ូវ ខេត្តតៃនិញ ប្រទេសវៀតណាម ត្រូវបានខ្មែរក្រហមយកក្របីទៅដូរជាមួយអាជ្ញាធរវៀតណាមយកបងប្រុសរបស់ខ្ញុំមកប្រទេសកម្ពុជាវិញ ប៉ុន្តែអាជ្ញាធរវៀតណាមមិនបានបញ្ជូនបងប្រុសរបស់ខ្ញុំត្រឡប់មកវិញទេ។ បន្ទាប់ពីវៀតណាមឈប់បញ្ជូនជនភៀសខ្លួនខ្មែរជាថ្នូរនឹងក្របីជាមួយខ្មែរក្រហម វៀតណាមបានប្រមូលជនភៀសខ្លួនខ្មែរទៅដាក់នៅជំរំបេនសាំង ដោយមានការជួយឧបត្ថម្ភក្នុងការរស់នៅ។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសារខ្ញុំពីភូមិអំពៅព្រៃ ខេត្តស្វាយរៀង ទៅនៅព្រៃពោធិ៍ ស្ថិតនៅខាងត្បូងផ្សារកអណ្តើក ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ខ្ញុំធ្វើការងារដាំដំឡូងនៅព្រៃពោធិ៍បានរយៈពេលមួយខែ។ មុនពេលខ្ញុំមកនៅព្រៃពោធិ៍ ខ្មែរក្រហមជ្រើសរើសប្រជាជនថ្មី (ប្រជាជន ១៧ មេសា) ដែលជម្លៀសមកដល់មុនគ្រួសារខ្ញុំ ទៅខេត្តពោធិ៍សាត់ហើយ។ បន្ទាប់ពីខ្មែរក្រហមបញ្ជូនប្រជាជនថ្មីចេញទៅអស់ ខ្មែរក្រហមក៏ចាប់ផ្តើមជ្រើសរើសគ្រួសាររបស់ខ្ញុំ ដោយប្រាប់ថា នៅខេត្តពោធិ៍សាត់ មានអាហារហូបឆ្អែត។ ខ្ញុំនិងគ្រួសារបានដើរពីព្រៃពោធិ៍ ស្រុកកំពង់ត្របែក ទៅដេកនៅអ្នកលឿងរយៈពេល៣យប់ ដើម្បីរង់ចាំជិះកប៉ាល់បន្តទៅក្រុងភ្នំពេញ។ នៅអ្នកលឿង ខ្មែរក្រហមបានប្រកាសជ្រើសអ្នកស្ម័គ្រចិត្តទៅរស់នៅខេត្តពោធិ៍សាត់ម្តងទៀត ប៉ុន្តែដោយសារខ្លាចខ្មែរក្រហម ទើបគ្រួសារខ្ញុំនិងប្រជាជនផ្សេងទៀតឆ្លើយថាស្ម័គ្រចិត្តទាំងអស់គ្នា។ ពេលទៅដល់ក្រុងភ្នំពេញខ្មែរក្រហម បានបែកបាយឱ្យក្រុមគ្រួសារខ្ញុំហូបរួចហើយយកឡានមកដឹកក្រុមគ្រួសារខ្ញុំទៅដាក់នៅស្ថានីយរថភ្លើងក្រុងភ្នំពេញ។ ខ្ញុំដេកនៅចំណតរថភ្លើងនៅក្នុងក្រុងភ្នំពេញមួយរយៈ ដើម្បីរង់ចាំជិះរថភ្លើងបន្តទៅកាន់ខេត្តពោធិ៍សាត់។

ពេលទៅដល់ខេត្តពោធិ៍សាត់ ខ្មែរក្រហមបានបញ្ជូនគ្រួសារខ្ញុំឱ្យទៅនៅតាលោ ក្នុងស្រុកបាកាន។ ខ្មែរក្រហមចាត់តាំងបងថ្លៃខ្ញុំទៅនៅកងកិនអង្ករ

ចំណែកបងស្រីខ្ញុំឈ្មោះ ឈឹម សឿន ទូលស្រូវពីសហករណ៍ស្តុកខ្លាំទៅតាលោ។ ខ្មែរក្រហមបានបំបែកសមាជិកគ្រួសារអ្នកជម្លៀសមិនឱ្យនៅជុំគ្នា ឡើយ គឺបែងចែកទៅតាមកងផ្សេងៗ ដូចជា កងកុមារ, កងវ័យកណ្តាល, កងនារី, កងយុវជន, កងមនុស្សចាស់ កងតាៗ និងកងយាយៗ ហើយឱ្យទៅរស់នៅដាច់ដោយឡែកពីគ្នា និងមានប្រធានកងដឹកនាំរៀងៗខ្លួន។ នៅទីនោះការហូបចុកគឺលំបាកខ្លាំងណាស់។ ខ្មែរក្រហមចែកបាយអេកឱ្យខ្ញុំម្នាក់មួយចាន ប៉ុន្តែខ្ញុំហូបមិនដែលគ្រប់គ្រាន់ទេ។ ពេលនោះ ខ្មែរក្រហមចាត់តាំងខ្ញុំឱ្យធ្វើការងារលើកភ្លឺស្រែ។

នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានមកហៅបងថ្លៃរបស់ខ្ញុំឈ្មោះ ម៉ី ផន ថាទៅកាប់ដងកណ្តាប ហើយបាត់ខ្លួនរហូត។ បន្ទាប់មកប្រធានកងនារីឈ្មោះ ម៉ែ ហួយ មកពីខេត្តតាកែវ បានមកសួរប្រពន្ធបង ម៉ី ផន (ឈ្មោះ ឈឹម សឿន ត្រូវជាបងស្រីខ្ញុំ) ថា អ៊ុំមានកូនទេ? ពេលនោះប្រពន្ធបង ម៉ី ផន ប្រាប់ថា កូនខ្ញុំនៅតូចណាស់។ ដូច្នេះ ប្រធានកងឈ្មោះ ហួយ នោះទៅហៅប្អូនស្រីខ្ញុំឈ្មោះ ឈឹម ហឿន ឱ្យទៅជំនួស។ ប្អូនស្រីខ្ញុំរួមទាំងប្តី ត្រូវបានខ្មែរក្រហមយកទៅសម្លាប់បន្តទៀត ចំណែកកូនម្នាក់បានស្លាប់មុនដោយសារជំងឺគ្រុនក្តៅ។ ខ្ញុំចាំថា ខ្មែរក្រហមបានមកហៅប្អូន ស្រី ឈឹម ហឿន ដែលនៅមិនឆ្ងាយប៉ុន្មានពីរោងកិនអង្ករបស់សហករណ៍ថា ទៅកាប់ដងកណ្តាបនៅដំណាក់រុន។ ខ្ញុំបានឮខ្មែរក្រហមមកហៅប្អូនស្រីដែរ ប៉ុន្តែខ្ញុំមិនហ៊ានចេញមកមើលព្រោះខ្លាចខ្មែរក្រហមហៅខ្ញុំទៅដែរ ហើយចាប់តាំងពីពេលនោះប្អូនស្រីខ្ញុំក៏បាត់ខ្លួនរហូត។ ក្រោយមកប្អូនថ្លៃខ្ញុំ (ត្រូវជាប្តីរបស់ប្អូនស្រី ឈឹម ហឿន) បានឈឺគ្រុនចាញ់ ឃើញដូច្នេះបងស្រីខ្ញុំឈ្មោះ ឈឹម សឿង បានជួយរែកទឹកយកទៅឱ្យប្អូនថ្លៃទុកប្រើប្រាស់។ ប្អូនថ្លៃខ្ញុំនៅធ្វើការងារឱ្យខ្មែរក្រហមបានមួយព្រឹក នៅពេលល្ងាចប្អូនថ្លៃខ្ញុំធ្វើការមិនកើត ក៏ខ្មែរក្រហមយកទៅសម្លាប់ចោលតែម្តង។

នៅពេលកងទ័ពវៀតណាមវាយចូលមក នៅឆ្នាំ១៩៧៩ ទើបខ្ញុំធ្វើដំណើរត្រឡប់មកស្រុកកំណើត។ ខ្ញុំដើររយៈពេលជិត៣ខែ ពីខេត្តពោធិ៍សាត់មកដល់ក្រុងភ្នំពេញ បន្ទាប់មកទើបខ្ញុំធ្វើដំណើរបន្តមករស់នៅស្រុកកំណើតនៅខេត្តស្វាយរៀងវិញ។



ប្រជាជនកម្ពុជាវិលត្រឡប់មកស្រុកកំណើតវិញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ណិប ផល៖ ខ្ញុំពិការដៃ ដោយសារតែផ្ទុះគ្រាប់មីន

ស្លួត ទិចិត្រ



ណិប ផល រស់នៅភូមិជើងភ្នំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ណិប ផល ភេទស្រី អាយុ៦៨ឆ្នាំ មានទីកន្លែងកំណើតនៅភូមិបាឃុង ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ។ បច្ចុប្បន្ន ផល រស់នៅក្នុងភូមិជើងភ្នំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

ផល បានផ្តល់បទសម្ភាសន៍រៀបរាប់អំពីបទពិសោធន៍ជីវិតដែលបានឆ្លងកាត់តាំងពីកុមារ និងការរស់ នៅក្នុងរបបខ្មែរក្រហមថា៖ កាលកុមារភាព ខ្ញុំរៀនបានត្រឹមថ្នាក់ទី២ ដោយសារតែសង្គ្រាម ខ្ញុំក៏បានសម្រេចចិត្តឈប់រៀន ហើយមកនៅផ្ទះ ដើម្បីជួយធ្វើការងារឪពុកម្តាយ។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែង។ បន្ទាប់មកបាតុកម្មបានផ្ទុះឡើងនៅក្នុងស្រុកភូមិរបស់ខ្ញុំ។ បងៗរបស់ខ្ញុំបានបបួលគ្នាទៅចូលរួមធ្វើបាតុកម្មនៅអង្គតាសោម ជិតទីរួមខេត្តតាកែវ។ គោលបំណងរបស់បាតុករគឺទាមទារអំណាចជូនសម្តេចព្រះ នរោត្តម សីហនុ។ បាតុករបានឡើងទៅធ្វើបាតុកម្មអស់រយៈពេលមួយឆ្នាំ។

នៅចន្លោះឆ្នាំ១៩៧១-១៩៧២ ខ្ញុំបានចូលក្នុងសង្គមកិច្ចភូមិ និងធ្វើការខាងផ្នែកស្លថ្នាំជាមួយចាស់ៗ។ ជារៀងរាល់ថ្ងៃ ក្រៅពីស្លថ្នាំ ខ្ញុំត្រូវដើររកជីកឫសថ្នាំជាមួយចាស់ៗនៅក្នុងព្រៃ ដើម្បីយកមកស្លធ្វើថ្នាំទុកសម្រាប់ព្យាបាលប្រជាជននៅក្នុងភូមិនៅពេលឈឺថ្កាត់។ នៅពេលមានអ្នកជំងឺមក

សម្រាកព្យាបាលនៅមន្ទីរពេទ្យ ខ្ញុំគឺជាអ្នកមើលថែ និងរៀបចំថ្នាំជូនអ្នកជំងឺ។ ខ្ញុំធ្វើការចាប់តាំងពីព្រឹកព្រលឹមរហូតដល់ពេលល្ងាច ទើបខ្ញុំត្រឡប់ទៅសម្រាកនៅផ្ទះជាមួយឪពុកម្តាយវិញ។

នៅក្នុងឆ្នាំ១៩៧៣ ភូមិរបស់ខ្ញុំក៏ចាប់ផ្តើមមានការទម្លាក់គ្រាប់បែក ដែលបណ្តាលឱ្យមានការខូចខាតយ៉ាងសន្ធឹកសន្ធាប់ដល់ផ្ទះសម្បែង និងទ្រព្យសម្បត្តិរបស់ប្រជាជននៅក្នុងភូមិ ដូចជា៖ ផាប់ជ្រូក គោ ក្របី ជាដើម។ នៅពេលនោះ គ្រប់ផ្ទះសម្បែងត្រូវតែមានលេណដ្ឋានសម្រាប់លាក់ខ្លួនពីការទម្លាក់គ្រាប់បែក។ ការរស់នៅរបស់ប្រជាជនពីមួយថ្ងៃទៅមួយថ្ងៃកាន់តែមានភាពភ័យខ្លាច និងទុក្ខលំបាកក្នុងការចេញទៅធ្វើការរកស៊ីខាងក្រៅផ្ទះ និងប៉ះពាល់ដល់ការប្រកបមុខរបរធ្វើស្រែ ប្រមូលផល។

នៅក្នុងឆ្នាំ១៩៧៥ ខ្ញុំក៏បានទទួលដំណឹងថាខ្មែរក្រហមទទួលបានជ័យជម្នះនៅទីក្រុងភ្នំពេញ។ ខ្ញុំពិតជាមានការត្រេកអរជាខ្លាំងដោយគិតថាប្រទេសជាតិបានទទួលសុខសន្តិភាព និងបានត្រឡប់ទៅផ្ទះជួបជុំជាមួយគ្រួសារដូចដើមវិញ។ ប៉ុន្តែអ្វីដែលខ្ញុំបានរំពឹងទុកគឺមិនអាចទៅរួចនោះទេ។ ខ្មែរក្រហមបានធ្វើការផ្លាស់ប្តូរការគ្រប់គ្រងទាំងស្រុងនៅពេលខ្លួនទទួលបានជ័យជម្នះ។

ក្រោយខ្មែរក្រហមកាន់កាប់អំណាច ខ្ញុំត្រូវអង្គការបញ្ជូនឱ្យទៅធ្វើការនៅសហករណ៍ស្រែអំបិលក្នុងខេត្តកំពត។ ការធ្វើអំបិល និងប្រមូលផលអំបិល គឺមានការលំបាកខ្លាំងណាស់សម្រាប់ខ្ញុំរួមទាំងប្រជាជនទាំងអស់ ដែលធ្វើការនៅទីនោះ។ ជារៀងរាល់ថ្ងៃ យើងត្រូវឈរនៅហាលក្តៅ ដើម្បីហាលអំបិលតាំងពីព្រឹក រហូតដល់ម៉ោង១២ថ្ងៃត្រង់។ បន្ទាប់ពីហូបបាយថ្ងៃត្រង់រួចរាល់ យើងចាប់ផ្តើមចុះធ្វើការបន្តទៀតនៅម៉ោងមួយរសៀល។ នៅក្នុងអំឡុងពេលធ្វើការនៅស្រែអំបិល ខ្ញុំតែងតែឃើញកម្មាភិបាលជាន់ខ្ពស់មកពិនិត្យមើលកម្មករស្រែអំបិលជាញឹកញាប់ ប៉ុន្តែខ្ញុំមិនបានស្គាល់អ្នកទាំងអស់នោះទេ។ ចំណែកឯការហូបចុក កម្មករស្រែអំបិលមានការលំបាក។ ខ្ញុំទទួលបានអាហារពីរពេល នៅថ្ងៃត្រង់ និងល្ងាចជារៀងរាល់ថ្ងៃ។ ជួនកាល ខ្ញុំបានហូបបាយក្តាំងមួយដុំតែប៉ុណ្ណោះក្នុងមួយថ្ងៃ។ បើទោះបីជាខ្ញុំឃ្លាន ក៏ខ្ញុំគ្មានអ្វីយកមកហូបនោះទេ ព្រោះអាហារទាំងអស់គឺជារបស់រួម។ យើងមិនអាចទៅយកមកហូបតែម្នាក់ឯងបានទេ។ ប្រសិនបើមានអ្នកលួចអាហារហូបចុក អ្នកនោះនឹងត្រូវចាប់ខ្លួន ហើយចោទថាជាជនក្បត់សហករណ៍ ឬអង្គការ។

ខ្ញុំធ្វើការងារនៅស្រែអំបិលរហូតដល់ឆ្នាំ១៩៧៨ បន្ទាប់មកខ្ញុំក៏បានផ្លាស់ប្តូរទៅធ្វើជាកងការពារស្រុក «៣១» ក្នុងខេត្តបាត់ដំបងវិញ។ កាលនោះ ខ្ញុំធ្វើដំណើរតាមរយៈរថភ្លើង។ នៅពេលនោះ ការងារជាកងការពារមិនមានព្រៃទាំងអស់នោះទេ មានចម្ការចេក និងចម្ការក្រូច។ ក្រោយមក អង្គការបានរៀបចំឱ្យខ្ញុំប្តេជ្ញាមានគ្រួសារ ក្នុងចំណោមប្រជាជនចំនួន១២គូផ្សេងទៀត។ ចំពោះកម្មវិធីនៅពេលនោះ ទាំងភាគីប្រុស និងស្រី ត្រូវអង្គុយទល់មុខគ្នារួចចាប់ដៃគ្នាប្តេជ្ញាចិត្តរស់នៅជាមួយគ្នា ថែរក្សាគ្នាធ្វើជាគូអនាគតរហូតដល់ចាស់ និងត្រូវបម្រើ ស្មោះត្រង់ជាមួយអង្គការ។ មុនពេលអង្គការរៀបចំប្តេជ្ញា ខ្ញុំមិនបានស្គាល់គ្នាជាមួយប្តីរបស់ខ្ញុំពីមុនមកនោះទេ។ ប៉ុន្តែអង្គការបានរៀបចំឱ្យខ្ញុំទាំងពីរនាក់រៀបការជាមួយគ្នា។ យើងក៏មិនអាចតវ៉ា ឬប្រកែកជាមួយអង្គការបានឡើយ។ បន្ទាប់ពីខ្ញុំបានរៀបការហើយ អង្គការក៏បានបញ្ជូនប្តីប្រពន្ធខ្ញុំទៅនៅធ្វើការក្នុងចម្ការកប្បាស ដែលស្ថិតនៅស្រុករតនមណ្ឌល ខេត្តបាត់ដំបង។ ខ្ញុំរួមទាំងប្តីបានបន្តធ្វើការនៅចម្ការកប្បាសរហូតដល់ឆ្នាំ១៩៧៩។

នៅពេលដែលកងទ័ពវៀតណាមចូលមករំដោះ យើងក៏នាំគ្នារត់ឆ្ពោះទៅព្រំដែនថៃ។ អំឡុងពេលរត់ ខ្ញុំមានផ្ទៃពោះកូនទីមួយ។ ខ្ញុំពិតជាមានការលំបាកជាខ្លាំងនៅក្នុងការធ្វើដំណើររត់ចូលព្រៃ។ មានប្រជាជន និងកងទ័ពខ្មែរក្រហមរាប់ពាន់នាក់បានរួមដំណើរជាមួយគ្នាឆ្ពោះទៅព្រំដែន។ ពេលធ្វើដំណើរក៏មានប្រទះគ្នា និងបាញ់រះរវាងកម្លាំងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាម ហើយពេលខ្លះក៏ត្រូវដាច់បាយ

ដាច់ទឹកហូប។ ប្រជាជនអស់កម្លាំង និងមិនអាចបន្តដំណើរទៅមុខបានលឿន។ ឯអ្នកខ្លះទៀតកង្វះជីវជាតិអាហារ និងទឹកធ្វើឱ្យមានរូបរាងស្គមស្គាំងបណ្ដាលឱ្យស្លាប់តាមផ្លូវធ្វើដំណើរ។ ការធ្វើដំណើរនេះមានរយៈពេលពីមួយខែទៅដល់ពីរខែទើបទៅដល់ព្រំដែនថៃ។ ស្ថិតនៅទីតាំងព្រំដែនថៃ ការរស់នៅក៏មិនទាន់បានល្អប្រសើរដែរ។ ប្រជាជននៅតែជួបទុក្ខលំបាកគ្មានកន្លែងដេកស្រួលបួល។ យើងត្រូវផ្លាស់ប្ដូរទីកន្លែងរស់នៅជាបន្តបន្ទាប់។ ពេលខ្លះយើងដេកតែទីតាំងខ្មោចស្លាប់។ ខ្ញុំរួមទាំងប្រជាជនទាំងអស់រស់នៅជួបការលំបាកអស់រយៈពេលមួយឆ្នាំទើបមានកាកបាទក្រហមជួយផ្គត់ផ្គង់អាហារហូបចុកបានគ្រប់គ្រាន់។ ចាប់តាំងពីពេលនោះមក ការហូបចុកលែងមានការខ្វះខាតទៀតហើយ។ ខ្ញុំ និងប្ដីបានបន្តរស់នៅតាមព្រំដែនរហូតដល់ឆ្នាំ១៩៨០ ទើបមានការជ្រើសរើសកម្លាំងមកខាងខេត្តឧត្ដរមានជ័យ។ គ្រួសារខ្ញុំសម្រេចចិត្តមកភូមិភាគឧត្តរ។

គ្រួសារខ្ញុំត្រូវរស់នៅលើភ្នំដងរែករហូតដល់ឆ្នាំ១៩៩០ ទើបចុះមករស់នៅក្នុងភូមិជើងភ្នំ។ ដល់ភូមិជើងភ្នំ ប្ដីប្រពន្ធខ្ញុំក៏នាំគ្នាកាប់ឆ្ការព្រៃដើម្បីរៀបចំសង់ផ្ទះសម្បែង និងបង្កបង្កើនផលដំណាំសម្រាប់ផ្គត់ផ្គង់គ្រួសារ។ ការកាប់ឆ្ការព្រៃនៅតំបន់អន្លង់វែងមានគ្រោះថ្នាក់ខ្លាំងណាស់ ដោយសារតែតំបន់នេះជាតំបន់សម្បូរគ្រាប់មីនមិនទាន់ផ្ទុះដែលសេសសល់ពីសង្គ្រាម។ ខ្ញុំពិការដៃមកដល់សព្វថ្ងៃនេះ ក៏ដោយសារតែផ្ទុះគ្រាប់មីនពេលខ្ញុំទៅធ្វើចម្ការ។ ចំពោះសុខភាពរបស់ខ្ញុំបច្ចុប្បន្ននេះ គឺជាការបន្សល់ទុកពីសម័យសង្គ្រាម ធ្វើឱ្យខ្ញុំមានជំងឺប្រចាំកាយដូចជា៖ លើសឈាម, ឡើងជាតិស្ករ, ឈឺភ្នែក និងសន្លាក់ដៃជើង។

ស្រែអំបិលក្នុងរបបខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# គ្រួសារខ្ញុំចូលបម្រើបដិវត្តន៍ ប៉ុន្តែបដិវត្តន៍ ធ្វើឱ្យគ្រួសារខ្ញុំ ស្ទើរតែបាត់បង់ជីវិត

**អេង សុខម៉េង**

បដិវត្តន៍ជាពាក្យមួយដែលមេដឹកនាំខ្មែរក្រហមយកមកប្រើដើម្បីអូសទាញកម្លាំងប្រជាជន ពិសេសកសិករក្រីក្រនៅតាមទីជនបទ ដើម្បីឱ្យស្ម័គ្រចិត្តចូលរួមជាមួយចលនាខ្មែរក្រហម ក្នុងការផ្លាស់ប្តូរប្រទេសជាតិចេញពីសង្គ្រាម ការទម្លាក់គ្រាប់បែក ប្រទេសទទួលបានឯករាជ្យ និងប្រជាជនរស់នៅស្មើភាពគ្នានៅក្នុងសង្គម។ បើយោងតាមវចនានុក្រមខ្មែរសម្តេចព្រះសង្ឃរាជ ជួន ណាត ពាក្យបដិវត្តន៍ មានន័យថា គឺជាការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនូវរបបគ្រប់គ្រងចាស់ ដែលមិនចម្រើនឱ្យបានចម្រើនលូតលាស់ទាន់សម័យកាល។


ប្រាក់ សឿន រស់នៅភូមិស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខាងក្រោមនេះគឺជាប្រវត្តិរូបសង្ខេបរបស់ ប្រាក់ សឿន ហៅ សែ ដែលបានចូលបម្រើបដិវត្តន៍ក្នុងគោលបំណងចូលរួមចំណែករំដោះប្រទេសជាតិពីភ្លក់ភ្លើងសង្គ្រាម ការទម្លាក់គ្រាប់បែក និងលុបបំបាត់វណ្ណៈជិះជាន់នៅក្នុងសង្គម៖

ប្រាក់ សឿន ហៅ សែ ភេទស្រី អាយុ៤៨ឆ្នាំ (ឆ្នាំ២០០៥) មានទីកន្លែងកំណើត និងរស់នៅភូមិស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ ឪពុកឈ្មោះ ប្រាក់ មុត ម្តាយឈ្មោះ រស់ អ៊ុន។ អ្នកទាំងពីរសុទ្ធតែបានចូលរួមជាមួយបដិវត្តន៍ខ្មែរក្រហម។ សែ ជាកូនពៅក្នុងគ្រួសារដែលមានបងប្អូនចំនួន៤នាក់។ បងប្រុសទី១) ឈ្មោះ ប្រាក់ សាវ៉ាន់ មានតួនាទីជាប្រធានដឹកជញ្ជូនស្រុកត្រូវបានអង្គការចាប់ខ្លួននៅឆ្នាំ១៩៧៧ ដោយចោទប្រកាន់ថាខុសសីលធម៌ និងក្រោយមកបានស្លាប់ក្នុងគុក ដោយសារជំងឺ។ បងប្រុសទី២) ឈ្មោះ ប្រាក់ សាម៉ន ជាគ្រូពេទ្យស្រុក។ បងស្រីទី៣) ឈ្មោះ ប្រាក់ សន ជាកងនារីស្រុក។ អ្នកទាំងបីសុទ្ធតែជាជនបដិវត្តន៍ខ្មែរក្រហម។ កាលពីកុមារភាព សែ រៀនបានត្រឹមថ្នាក់អក្ខរកម្ម ប៉ុន្តែគាត់អាចអាន និងសរសេរអក្សរខ្មែរបានខ្លះ។

នៅឆ្នាំ១៩៧០ ក្នុងរបប លន់ នល់ ក្នុងភូមិរបស់ សែ ចាប់ផ្តើមមានការទម្លាក់គ្រាប់បែក ចំណែកកងទ័ពវៀតណាម បានចូលមករស់នៅតាមភូមិ ដែលបង្កឱ្យមានអំពើអសន្តិសុខផ្សេងៗ ដូចជា លួច ឆក់

ប្អូន និងចាប់រំលោភកូនស្រីអ្នកក្នុងភូមិ។ ប្រជាជនមួយចំនួនត្រូវបានបង្ខំចិត្តចាកចេញពីផ្ទះសម្បែងទៅរស់នៅតាមវាលស្រែ និងក្នុងព្រៃឆ្ងាយពីភូមិ។ នៅឆ្នាំ១៩៧១ សែ ឃើញកងទ័ពធីវគី (វៀតណាមខាងត្បូង) សហការគ្នាជាមួយទាហាន លន់ នល់ បានចាប់យុវជន និងយុវនារីក្នុងភូមិឱ្យចូលធ្វើជាកងទ័ព។

នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៧២ សែ មានអាយុប្រហែលជា១២ឆ្នាំ បានស្ម័គ្រចិត្តចូលរួមជាមួយបដិវត្តន៍ខ្មែរក្រហមក្នុងនាមជាវណ្ណៈកសិករកណ្ដាល តាមរយៈការណែនាំរបស់ឪពុកខ្លួនឈ្មោះ ប្រាក់ មុត ដែលធ្វើការនៅមន្ទីរយោសនាការ នៃស្រុកមានជ័យថ្មី (បច្ចុប្បន្នស្រុកស្វាយជ្រំ) ខេត្តស្វាយរៀង។ ការចូលបដិវត្តន៍របស់ សែ ធ្វើឡើងនៅកងកុមារ ឃុំស្វាយយារ ស្រុកមានជ័យថ្មី ខេត្តស្វាយរៀង។ សែ និយាយថានៅពេលនោះក្នុងឃុំស្វាយយារ ឃុំស្វាយជ្រំ និងឃុំផ្សេងៗទៀត នៃស្រុកមានជ័យថ្មី ខ្មែរក្រហមបានចូលគ្រប់គ្រងហើយ។ ឪពុកម្ដាយរបស់គាត់ដែលជាអ្នកយោសនាអប់រំម្នាក់នៅស្រុកមានជ័យថ្មី នៃមន្ទីរ និងភូមិភាគបូព៌ា ក៏បានដើរអូសទាញក្មេងៗ យុវជន និងយុវនារីផ្សេងៗទៀត ឱ្យស្ម័គ្រចិត្តចូលរួមជាមួយចលនាកម្លាំងបដិវត្តន៍ខ្មែរក្រហមដើម្បីរួមគ្នារំដោះប្រទេសជាតិពីសង្គ្រាម ការទម្លាក់គ្រាប់បែក និងការជិះជាន់វណ្ណៈសក្តិភូមិ។ បន្ទាប់ពីចូលបដិវត្តន៍ សែ ទទួលបានការបណ្ដុះបណ្ដាលអប់រំពីរបៀបដើរនិយាយយោសនាកុមារៗឱ្យស្រឡាញ់មាគ៌ាបដិវត្តន៍។ ក្រោយមកគាត់អូសទាញបានកុមារក្នុងភូមិឃុំមួយចំនួនចូលរួមចលនាបដិវត្តន៍ខ្មែរក្រហម។

នៅឆ្នាំ១៩៧៣ សែ និងកុមារ៦នាក់ទៀត ត្រូវបានផ្លាស់ប្ដូរការងារមកក្រុមសិល្បៈស្រុកមានជ័យថ្មីវិញ។ គាត់ទទួលបានការបណ្ដុះបណ្ដាលពីការសម្ដែងល្ខោន និងសម្ដែងយីកេរយៈពេល៤ខែ ពីគ្រូជាជនជាតិខ្មែរ និងគ្រូជនជាតិចិន។ សែ និងកុមារទាំង៦នាក់ត្រូវក្រោកពីដេកនៅម៉ោង៤ទៀបភ្លឺ ដើម្បីទៅហាត់សិល្បៈដោយហាត់ពីរបៀបពត់ដៃ ពត់ជើង និងការសម្ដែងធ្វើគ្រាប់តាមគ្រូ។ បន្ទាប់ពីហាត់រៀនសិល្បៈចេះចាំស្ទាត់គាត់ និងក្រុមសិល្បៈបានចេញទៅសម្ដែងតាម ភូមិ ឃុំ ក្នុងស្រុកមានជ័យថ្មី នៅពេលមានកម្មវិធីជួបជុំ និងកម្មវិធីជប់លៀងរបស់ថ្នាក់ដឹកនាំខ្មែរក្រហមម្ដងៗ។ រៀងរាល់ការសម្ដែងស្ថិតក្រោមការដឹកនាំរបស់ឈ្មោះ នួល ដែលជាប្រធានសិល្បៈស្រុកមានជ័យថ្មី។ ការសម្ដែងសិល្បៈរបស់ សែ រយៈពេលប្រហែល ៣ឆ្នាំ របបខ្មែរក្រហមក៏ទទួលបានជ័យជម្នះទាំងស្រុងលើរបប លន់ នល់។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សែ មានអាយុប្រហែល១៥ឆ្នាំ ខ្មែរក្រហមបានឱ្យគាត់ទៅរស់នៅខេត្តព្រៃវែង រយៈពេល២ខែ ដើម្បីហាត់រៀនពីក្បួនកងទ័ព និងរៀនពីគោលនយោបាយមាគ៌ាបក្ស និងបដិវត្តន៍។ ក្រៅពីរៀនសូត្រ សែ ក៏ត្រូវទៅជួយធ្វើស្រែប្រាំងប្រជាជននៅភាគខាងត្បូងទន្លេ ខេត្តព្រៃវែង គឺតំបន់ទួលបារាយណ៍អណ្ដែត។ នៅខែកក្កដា ឆ្នាំ១៩៧៥ អង្គការបានផ្លាស់ប្ដូរ សែ ឱ្យទៅធ្វើការនៅភ្នំពេញ។ សែ បានសួរពីមូលហេតុនៃការផ្លាស់ប្ដូរនេះ ប៉ុន្តែថ្នាក់លើបានប្រាប់គាត់ថា ជាបញ្ជាមកពីមជ្ឈិម តម្រូវឱ្យជ្រើសរើសកម្មាភិបាលខ្មែរក្រហមពីគ្រប់តំបន់ និងភូមិភាគឱ្យឡើងទៅបំពេញកម្លាំងដែលខ្វះខាតនៅតាមអង្គភាព និងក្រសួង នៅភ្នំពេញ។ សែ និងកម្មាភិបាលខ្មែរក្រហម៦នាក់ផ្សេងទៀតបានធ្វើដំណើរទៅខេត្តកំពង់ចាម និងបន្តដំណើរជិះគ្នាជាមួយកម្មាភិបាលខ្មែរក្រហមរាប់រយនាក់ទៀត ពីកំពង់ចម្លងទន្លេបិទឆ្ពោះមកភ្នំពេញ នៅពេលយប់។ ពេលមកដល់ សែ និងកម្មាភិបាលខ្មែរក្រហមទាំងអស់បានសម្រាកនៅចាក់អង្រែមួយរយៈ មុនពេលដែលអង្គការបញ្ជូនអ្នកទាំងអស់នោះទៅតាមមន្ទីរ និងក្រសួងនានានៅភ្នំពេញ។ សែ ត្រូវបញ្ជូនទៅធ្វើការនៅក្រសួងពាណិជ្ជកម្ម។ ពេលទៅដល់ សែ ទទួលបន្ទុកដាំបាយ និងចម្អិនម្ហូបអាហារឱ្យកម្មាភិបាលខ្មែរក្រហមដែលមកពីភូមិភាគផ្សេងៗ ពេលមកប្រជុំនៅក្រសួងពាណិជ្ជកម្ម។ អ្នកមកប្រជុំទាំងអស់ សែ ដឹងថាសុទ្ធតែថ្នាក់ដឹកនាំ

តំបន់ និងភូមិភាគនៅទូទាំងប្រទេស។ កិច្ចប្រជុំធ្វើឡើងនៅភ្នំពេញមានរយៈពេលពីរបីថ្ងៃ ទៅមួយសប្តាហ៍។ សែ ត្រូវមានភារកិច្ចរៀបចំអាហារចំនួនបីពេលក្នុង១ថ្ងៃ គឺព្រឹក ថ្ងៃត្រង់ និងល្ងាច សម្រាប់គណៈប្រតិភូដែលមកចូលរួមប្រជុំ។

ក្រោយពីការងារដាំស្ល សែ ក៏ទទួលបន្ទុកខាងដឹកជញ្ជូនស្បៀងអាហារ ពីគី ឡូម៉ែត្រលេខ៦ទៅតាមមន្ទីរ និងក្រសួងនានានៅភ្នំពេញ។ គាត់ត្រូវដឹកជញ្ជូន ស្រូវ អង្ករ និងកន្ទក់ ជាមួយអ្នកបើកបរម្នាក់ យកទៅផ្គត់ផ្គង់តាមទីតាំងនីមួយៗជារៀងរាល់ខែ។ សែ ត្រូវកត់ត្រាចំនួនស្បៀងអាហារដែលបានផ្គត់ផ្គង់ដើម្បីរាយការណ៍ទៅឱ្យប្រធានរបស់គាត់ជារៀងរាល់ល្ងាច។ ក្រោយពីការងារដឹកជញ្ជូនស្បៀងអាហារ សែ ក៏មានតួនាទីមួយទៀតគឺជាអ្នកបោសសម្អាតបរិស្ថានទីក្រុង បោសសម្អាតផ្លូវ និងបោសសម្អាតផ្ទះផ្សេងៗនៅម្តុំផ្សារថ្មី ដែលម្ចាស់ផ្ទះត្រូវខ្មែរក្រហមបង្ខំឱ្យជម្លៀសចេញទៅទីជនបទ។

នៅឆ្នាំ១៩៧៧ អង្គការបានផ្លាស់ប្តូរការងារ សែ និងមនុស្ស៦នាក់ជាបន្តទៀតឱ្យទៅធ្វើជាអ្នកវាយអង្គុលីលេខឬអ្នកវាយអត្ថបទនៅផ្នែកនាំចេញនាំចូលទំនិញក្រៅប្រទេស ស្ថិតក្រោមក្រសួងពាណិជ្ជកម្មដដែល។ សែ និងអ្នកទាំង៦នាក់ទទួលបានការបណ្តុះបណ្តាលរយៈពេលមួយខែ ពីរបៀបប្រើប្រាស់ម៉ាស៊ីនវាយអង្គុលីលេខ។ តាមរយៈការរៀបរាប់របស់ សែ មានទំនិញដូចជា អង្ករ សណ្តែក អំពៅ និងកៅស៊ូ ត្រូវបានរបបខ្មែរក្រហមនាំចេញទៅក្រៅប្រទេស ដូចជា ទៅប្រទេសចិន ប្រទេសកូរ៉េ និងប្រទេសភូមា។ គាត់ត្រូវកត់ត្រារាល់ចំនួនទំនិញទាំងអស់ដែលបាននាំចេញដោយប្រើប្រាស់ម៉ាស៊ីនវាយអង្គុលីលេខតាមឯកសារសរសេរដោយដៃពីអ្នកធ្វើការនៅក្រសួងពាណិជ្ជកម្មនេះ។ កន្លែងការងារថ្មីរបស់ សែ ស្ថិតនៅម្តុំផ្សារថ្មី។ ក្រោយពីកត់ត្រាតួលេខទំនិញនាំចេញ សែ ក៏ត្រូវវាយអង្គុលីលេខឯកសារក្រដាសសរសេរដៃផងដែរ ដែលមានជាភាសាខ្មែរ និងភាសាបារាំង។ សែ មិនចេះភាសាបារាំងទេគ្រាន់តែគាត់អាចអានស្រៈនិងព្យញ្ជនៈបាន។ នៅកន្លែងធ្វើការ សែ ខស្សាហ៍ឃើញ អៀង ធីរិទ្ធ អតីតមេដឹកនាំខ្មែរក្រហមចេញចូលកន្លែងធ្វើការរបស់គាត់នៅក្រសួងសង្គមកិច្ចដែលនៅជិតកន្លែងវាយអង្គុលីលេខនៃក្រសួងពាណិជ្ជកម្ម។ គាត់ក៏ធ្លាប់ឃើញ អៀង សារី នាំគណៈប្រតិភូជនជាតិចិនមកធ្វើទស្សនកិច្ចនៅក្រសួងពាណិជ្ជកម្មម្តងផងដែរ។

នៅពាក់កណ្តាលឆ្នាំ១៩៧៨ សែ និងកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគបូព៌ាជាច្រើន ដែលធ្វើការក្នុងក្រសួង និងមន្ទីរ នៅភ្នំពេញ ត្រូវបានផ្លាស់ប្តូរទៅធ្វើការដ្ឋានផ្លូវរថភ្លើង នៅផ្លូវជាតិលេខ៤ តំបន់ពេជ្រនិល ក្រុងព្រះសីហនុ។ ការងារនៅការដ្ឋានធ្វើផ្លូវរថភ្លើង គឺជាការងារដែលលំបាកខ្លាំងជាងគេក្នុងជីវិតរស់នៅឆ្លងកាត់របបខ្មែរក្រហម។ សមាជិក២០នាក់ត្រូវជួសជុលផ្លូវដែកពីតំបន់ពេជ្រនិលឆ្ពោះទៅកាន់ក្រុងព្រះសីហនុ។ ការជួសជុលផ្លូវដែកនេះមានកន្លែងខ្លះត្រូវធ្វើឆ្លងកាត់ព្រៃ និងឆ្លងកាត់អូរនិងស្ទឹងជាដើម។ ចំណែកការស្នាក់នៅ គឺយប់កន្លែងណាចងអង្រឹង និងក្រាលតង់សម្រាកនៅកន្លែងនោះ។ ពេលយប់សែបានលឺសំឡេងខ្លាសំឡេងចចក និងសត្វសាហាវផ្សេងៗនៅស្ទើរតែពាសពេញព្រៃ។ របបអាហារគាត់ទទួលបានមិនគ្រប់គ្រាន់ទេខុសប្លែកគ្នាស្រឡះកាលពីនៅក្រសួងពាណិជ្ជកម្ម។

នៅចុងឆ្នាំ១៩៧៨ អង្គការបានរៀបចំឱ្យ សែ ប្តេជ្ញា (រៀបការ) ជាមួយនឹងកម្មាភិបាលខ្មែរក្រហមម្នាក់ដែលធ្វើការនៅការដ្ឋានផ្លូវរថភ្លើងជាមួយគ្នា។ សែ យល់ព្រមរៀបការដោយសារខ្លាចអង្គការបញ្ជូនគាត់ឱ្យទៅធ្វើជាយោធាវាយប្រយុទ្ធគ្នាជាមួយកងទ័ពវៀតណាម ព្រោះគាត់ឮព័ត៌មានអ្នកនៅលីវទាំងអស់នៅការដ្ឋាន និងត្រូវទៅភ្នំពេញដើម្បីជួយធ្វើសង្គ្រាម។ ក្នុងពិធីរៀបការរបស់ សែ និងអ្នកផ្សេង១៩គូទៀត ក៏មានប្រធានការដ្ឋានធ្វើផ្លូវរថភ្លើងជាអ្នករៀបចំ និងធ្វើជាគណៈអធិបតី។ គណៈអធិបតីបានណែនាំឱ្យប្តីប្រពន្ធទាំងអស់ដែលអង្គុយជាពីរជួរទល់មុខគ្នា ត្រូវចេះស្រឡាញ់គ្នាអស់មួយជីវិត។ សែ

រៀបការបានប្រហែលកន្លះខែ ក៏មានកងទ័ពវៀតណាមចូលមករំដោះតំបន់ដែលគាត់រស់នៅ។ ប្រធានការដ្ឋានបានជម្លៀស សែ និងអ្នកនៅការដ្ឋានទាំងអស់ឱ្យទៅកាន់ខេត្តភាគខាងលិចប្រទេសកម្ពុជា។ គាត់បានធ្វើដំណើរដោយថ្មើរជើង ឆ្លងកាត់ព្រៃ និងភ្នំរហូតទៅដល់ខេត្តពោធិ៍សាត់។ អំឡុងពេលធ្វើដំណើរ សែ និងប្តី បានបែកគ្នាព្រោះភាពច្របូកច្របល់ និងមានការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាម។

ពេលទៅដល់ខេត្តពោធិ៍សាត់ កម្មាភិបាលខ្មែរក្រហម ទាំងអស់ត្រូវរស់នៅក្នុងព្រៃដោយគ្មានអាហារហូបគ្រប់គ្រាន់។ បន្ទាប់មកទៀត កម្មាភិបាលខ្មែរក្រហមចាប់ផ្តើមលែងទុកចិត្តគ្នា និងសង្ស័យគ្នាទៅវិញទៅមក ដោយធ្វើការចោទប្រកាន់គ្នាឯងថាជាគិញសម្ងាត់របស់ប្រទេសវៀតណាម រួចចាប់ផ្តើមសម្លាប់គ្នាទៅវិញទៅមក។ ឃើញដូច្នេះ សែ ក៏បានរត់គេច និងត្រឡប់មកស្រុកកំណើតវិញក្នុងឆ្នាំ១៩៨១។



កងសិល្បៈក្នុងរបបខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មាស ផ្កា ៖ ជនពិការត្រូវស្រវាចាប់ ឈើច្រត់សិន មុននឹងបោះជំហានទៅមុខ

**លី សុខឃាង**

មាស ផ្កា ភេទប្រុស អាយុ៦៨ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិគោកជី ឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប។ បច្ចុប្បន្ន មាស ផ្កា រស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

ផ្កា បាននិយាយថា៖ «ខ្ញុំគឺជាកូនច្បងក្នុងចំណោមបងប្អូនបង្កើតចំនួន២នាក់។ កាលពីកុមារភាព ខ្ញុំមិនបានរៀនសូត្រនោះទេ ដោយសារសង្គ្រាមចាប់តាំងពីសម័យ លន់ នល់ មក។ ក្រុមគ្រួសាររបស់ខ្ញុំមានជីវភាពមធ្យម។ នៅឆ្នាំ១៩៧០ ខ្ញុំបានស្ម័គ្រចិត្តចូលបម្រើកងឈ្លបរបស់ខ្មែរក្រហម ដោយសារនៅពេលនោះ កងទ័ពវៀតណាមបានចូលដល់ភូមិរបស់យើង។ ខ្មែរក្រហមមិនបានឱ្យយើងចូល ហ្វឹកហាត់ទេ ប៉ុន្តែបញ្ជូនឱ្យចូលប្រយុទ្ធជាក់ស្តែងតែម្តង។ អ្វីដែលយើងអាចធ្វើបានគឺរៀនគេចគ្រាប់កាំភ្លើង និងគ្រាប់ផ្លោងដោយខ្លួនឯង។ ក្រៅពីនេះ យើងរៀនមើលផ្លូវ និងភូមិសាស្ត្រដោយខ្លួនឯង។ នៅក្នុងឆ្នាំ១៩៧៣ ខ្មែរក្រហមចាប់ផ្តើមបង្កើតក្រុមប្រវាស់ដៃ ដើម្បីលើកស្ទួយវិស័យកសិកម្ម។

នៅក្នុងឆ្នាំ១៩៧៣ដដែល ខ្ញុំបានចូលកងទ័ពខ្មែរក្រហមពេញសិទ្ធិ ហើយបន្តរហូតដល់យើងរត់ចូលព្រៃនៅពេលប៉ះទង្គិចគ្នាជាមួយកងទ័ពវៀតណាម។ នៅពេលនោះ តួនាទីរបស់ខ្ញុំគឺដឹកជញ្ជូនបាយទៅកាន់សមរភូមិមុខ។ ការងារជាអ្នកដឹកជញ្ជូនបាយមិនងាយស្រួលនោះទេគឺដូចទៅនឹងកងទ័ពប្រយុទ្ធក្នុងសមរភូមិដែរ។ យើងបានលួនកាត់គ្រាប់ ដើម្បីយកបាយទៅក្នុងទីស្នាក់ការ។ បន្ទាប់មក អង្គភាពខ្មែរក្រហមបានចាត់កម្លាំងបញ្ជូនបាយនោះបន្តឱ្យកងទ័ព។



មាស ផ្កា អាយុ៦៨ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រហូតដល់ឆ្នាំ១៩៧៥ យើងចាប់ផ្តើមរស់នៅរួមក្នុងសហករណ៍។ នៅពេលចូលដល់សម័យខ្មែរក្រហម ខ្ញុំបានរស់នៅក្នុងសហករណ៍។ ជីវិតរបស់យើងនៅពេលនោះបានជួបប្រទះនឹងការហូបចុកមិនគ្រប់គ្រាន់។ ជាក់ស្តែង អង្ករមួយកំប៉ុងហូបគ្នាចំនួន៥០នាក់។ សហករណ៍ខ្មែរក្រហមបានបង្ខិតបង្ខំឱ្យយើងធ្វើការងាររួម និងរស់នៅរួម។ ប្រជាជនត្រូវបានតម្រូវឱ្យ

យកទ្រព្យ និងសម្ភារផ្ទះបាយរបស់ខ្លួនមកដាក់រួម។ នៅពេលនោះខ្មែរក្រហមបានចាត់ខ្ញុំចូលធ្វើជាកងចល័តតំបន់។ ខ្ញុំឃើញថា សហករណ៍នីមួយៗមានអាហារហូបគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់ អាស្រ័យលើប្រធានសហករណ៍។ ជាទូទៅ សហករណ៍របស់ខ្ញុំនៅក្នុងស្រុកជីក្រែងហូបបបររាវ។ ហើយរយៈពេលកន្លះខែម្តង យើងទទួលបានបាយ។ ការហូបបាយម្តងម្កាលនោះ បានឆ្អែតគ្រប់គ្រាន់ និងមានម្ហូបឆ្ងាញ់ ដូចជាសាច់គោ និងសាច់ជ្រូកជាដើម។

នៅក្នុងឆ្នាំ១៩៧៩ នៅពេលដែលរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ យើងក៏បានធ្វើដំណើរទៅភ្នំឪរ៉ាល់ ខេត្តកំពង់ស្ពឺ។ ខ្ញុំមិនចង់វិលត្រឡប់ទៅស្រុកវិញទេ ដោយសារខ្ញុំមិនចង់ធ្វើទាហានរដ្ឋាភិបាល។ ម្យ៉ាងទៀត ខ្ញុំឮពាក្យចចាមអារ៉ាមថា កងទ័ពវៀតណាមនឹងចាប់អារក និងញាត់ស្មៅ។ ដូចនេះ ខ្ញុំបានរត់ចូលព្រៃ និងសុខចិត្តស្លាប់នឹងការធ្វើសង្គ្រាមប្រសើរជាង។ មនុស្សភាគច្រើនបានចូលរួមតស៊ូជាមួយខ្មែរក្រហមក៏ជួបប្រទះដូចខ្ញុំដែរ។ មូលដ្ឋានដែលខ្ញុំឈរជើង ស្ថិតនៅក្នុងខេត្តសៀមរាប។

នៅថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៨៤ ខ្ញុំបានពិការជើងម្ខាង ដោយសារជាន់មីននៅតំបន់១០០៣។ នៅពេលនោះ ខ្ញុំស្ថិតក្នុងចំណុចនៃការប្រយុទ្ធគ្នាជាមួយកងទ័ពវៀតណាម ហើយខ្ញុំក៏បានរត់ចូលជ្រកតាមព្រៃ ប៉ុន្តែជាន់មីនផ្ទុះ ដែលបណ្តាលឱ្យដាច់ជើងម្ខាង។ កម្លាំងរបស់ខ្មែរក្រហមបានស្លាប់ និងពិការជាច្រើននាក់ ដោយសារផ្ទុះមីនអំឡុងពេលវាយប្រយុទ្ធគ្នានៅតំបន់នេះ។ កងកម្លាំងរបស់ខ្មែរក្រហមបានទទួលរងនូវបរាជ័យក្នុងការប្រយុទ្ធជាមួយកងទ័ពវៀតណាម ដោយសារមានកម្លាំងតិចជាង និងមិនសូវមានអាវុធទំនើបផង។ ភាគច្រើនកងទ័ពវៀតណាមប្រើប្រាស់កាំភ្លើងធំ និងរថក្រោះ។ នៅពេលកម្លាំងរបស់ខ្មែរក្រហមស្លាប់ច្រើនពេក យើងមិនដឹងថាអ្នកណាកប់អ្នកណានោះទេ។ សាកសពយុទ្ធមិត្តមួយចំនួនត្រូវបានចងអង្រឹងទុកចោលនៅក្នុងព្រៃ។ ខ្ញុំបានសន្លប់បាត់ស្មារតីម្តងម្កាល ដោយសារហូរឈាមច្រើនពេក។

បន្ទាប់ពីជាសះស្បើយពីរបួស និងពិការជើងម្ខាង ខ្ញុំបានរៀបការនៅក្នុងឆ្នាំដដែល ក្រោមការរៀបចំរបស់អង្គភាពខ្មែរក្រហមក្នុងភូមិ៨០ នៃដីរំអួរត្រាវ។ នៅទីនោះ យើងទទួលបានស្បៀងអាហារហូបចុកគ្រប់គ្រាន់ក្រោមការជួយទំនុកបម្រុងពីតាម៉ុក ដូចជាអង្ករ ត្រីខ មី ប្រហុក និងទឹកដោះគោជាដើម។ តាម៉ុក គឺជាមនុស្សសម្តីអាក្រក់ ប៉ុន្តែទឹកចិត្តល្អ។ គាត់ជេរស្តីយើង ប៉ុន្តែគាត់ឱ្យស្បៀងអាហារ។ លើសពីនេះ គាត់ប្រមូលទិញស្រូវពីប្រជាជនគ្រប់ៗគ្នា ហើយយកឱ្យយើងហូបវិញ។ ខ្ញុំធ្លាប់សុំស្បៀងអាហារហូបចុក និងលុយ (លុយបាត) ពីគាត់។ ជួនកាលខ្ញុំសុំលុយពីគាត់ម្តងបានចំនួន៥០០បាត។

ខ្ញុំមានការសោកស្តាយចំពោះការតស៊ូមួយដែលខ្ញុំបានលះបង់គ្រប់បែបយ៉ាង ហើយខ្ញុំមិនអាចទាមទារអ្វីបានទាល់តែសោះពីរបបខ្មែរក្រហម។ អ្វីដែលខ្ញុំទទួលបានគឺប្រាក់បៀវត្សរ៍ពីរាជរដ្ឋាភិបាលកម្ពុជា នាពេលបច្ចុប្បន្ននេះទៅវិញ នៅពេលដែលខ្ញុំបានធ្លាក់ខ្លួនពិការ។ ខ្ញុំធ្លាប់ទទួលរងនូវការរើសអើងពីហាងលក់បាយ ដោយគិតថាយើងគ្មានលទ្ធភាពឱ្យថ្លៃបាយមួយពេលនោះ។

ថ្វីត្បិតតែស្រុកអន្លង់វែងសម្បូរទៅដោយជនពិការក៏ដោយ ក៏យើងមិនសម្រេចចិត្តដើរសុំទានតាមផ្លូវដែរ។ យើងសុខចិត្តស៊ូលំបាកជាមួយនឹងការងារស្រែចម្ការតាមលទ្ធភាពរៀងៗខ្លួន។ សូម្បីតែថ្នាក់ដឹកនាំនៅអន្លង់វែងក៏ស្ងើចសរសើរដែរ។ ខ្ញុំបានជួបការលំបាកក្នុងការរស់នៅប្រចាំថ្ងៃដូចជាការធ្វើដំណើរ និងប្រកបរបររកស៊ី ពីព្រោះយើងមិនអាចធ្វើដំណើរបានលឿនដូចមនុស្សធម្មតា។ មនុស្សមានកាយសម្បទាគ្រប់គ្រាន់ និងជនពិការ គឺខុសគ្នាខ្លាំងណាស់ ព្រោះជនពិការត្រូវស្រវាចាប់ឈើច្រត់សិនមុននឹងអាចបោះជំហានឈានជើងធ្វើដំណើរទៅមុខ។

ខ្ញុំរស់នៅក្នុងភូមិជើងភ្នំតាំងពីឆ្នាំ១៩៩៣ ដោយ

ខ្ញុំបានដោះមីននិងកាប់ឆ្ការព្រៃដោយខ្លួនឯង។ បច្ចុប្បន្ននេះ ខ្ញុំសប្បាយចិត្ត នៅពេលសង្គ្រាមបានបញ្ចប់ទៅ និងបន្សល់ទុកឱកាសឱ្យក្មេងៗជំនាន់ក្រោយបានរៀនសូត្រចេះដឹង។ ម្យ៉ាងទៀត យើងអាចប្រកបមុខរបរអ្វីក៏បាន។ កូនចៅរបស់យើងមិនជួបប្រទះសង្គ្រាមតទៅទៀតទេ។ យើងមិនសប្បាយចិត្តនោះទេ ប្រសិនបើយើងឃើញទិដ្ឋភាពលំបាកវេទនារបស់ប្រជាជនដែលត្រូវវែកកូនចៅគេចពីសង្គ្រាម។ ក្នុងសម័យនេះ យើងមានឱកាសបានជួបប្រពន្ធកូន ជួបក្រុមគ្រួសារ ហើយកូនចៅរបស់យើងអាចប្រកបរបរចិញ្ចឹមជីវិតដោយខ្លួនឯង»។



កងទ័ពបដិវត្តន៍ខ្មែរក្រហមនៅស្តាតអូឡាំពិក។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# ស្រី ហួន ៖ ពេទ្យឯកទេសជំងឺគ្រុនចាញ់នៅក្នុងរបបខ្មែរក្រហម

សោម ប៊ុនថន

នៅពេលខ្មែរក្រហមដើរឃោសនានៅតាមភូមិឃុំ ដើម្បីប្រមូលកម្លាំងធ្វើការតស៊ូប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរដឹកនាំដោយ លន់ នល់ ខ្មែរក្រហមបានជ្រើសរើសខ្ញុំឱ្យចូលរៀនពេទ្យបឋម ដើម្បីព្យាបាលជំងឺប្រជាជនក្នុងភូមិ។ ក្រោយមក ខ្មែរក្រហមបានបញ្ជូនខ្ញុំឱ្យទៅធ្វើការនៅមន្ទីរពេទ្យតំបន់ ជំនាញខាងជំងឺគ្រុនចាញ់រហូតដល់របបខ្មែរក្រហមដួលរលំ។

ខ្ញុំឈ្មោះ ស្រី ហួន កើតនៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៥១ នៅភូមិគគីរ ឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង។ ពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧២ ខ្មែរក្រហមបានប្រកាសជ្រើសរើសយុវជននិងយុវនារីនៅតាមភូមិឱ្យចូលធ្វើពេទ្យ ហើយខ្ញុំក៏ត្រូវបានជ្រើសរើសឱ្យចូលរៀនពេទ្យនៅឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង ដែលជាតំបន់រំដោះរបស់ខ្មែរក្រហម។ ដំបូងខ្ញុំចូលរៀនពេទ្យបឋម។ នៅឆ្នាំ១៩៧៤ ខ្មែរក្រហមបានប្រាប់ខ្ញុំថា នៅមន្ទីរខេត្តស្វាយរៀងខ្វះខាតបុគ្គលិកពេទ្យ ហើយបានបញ្ជូនខ្ញុំឱ្យទៅធ្វើការនៅទីនោះ។ មន្ទីរពេទ្យខេត្តស្វាយរៀងនៅពេលនោះ គឺបោះទីតាំងនៅក្នុងព្រៃបោះ ដែលមានដើមប្របាក់ដុះព័ទ្ធជុំជិត ស្ថិតនៅត្រពាំងរាំង (ខាងលិចវត្តព្រៃស្វាយ) ក្នុងឃុំសម្បត្តិមានជ័យ ស្រុករមាសហែក ខេត្តស្វាយរៀង ព្រោះខ្មែរក្រហមមិនទាន់វាយរំដោះបានក្រុងស្វាយរៀងទេ។ ។

នៅពេលកងទ័ពខ្មែរក្រហមទទួលជ័យជម្នះលើរបប លន់ នល់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានផ្លាស់ខ្ញុំឱ្យមកធ្វើការនៅមន្ទីរពេទ្យ



ស្រី ហួនរស់នៅភូមិត្រពាំងស្គន់ ឃុំគគីរ ស្រុករមាសហែក។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខេត្តស្វាយរៀង ស្ថិតនៅក្នុងក្រុងស្វាយរៀង តំបន់២៣ ភូមិភាគបូព៌ា។ ចាប់តាំងពីពេលនោះមក ខ្ញុំត្រូវរស់នៅបែកពីប្រពន្ធ និងកូនរបស់ខ្ញុំ។ ក្រោយមក ខ្ញុំបានសុំប្រធានពេទ្យទៅលេងប្រពន្ធកូនបានបីដង ដោយពេលទៅលេងម្តងៗបានរយៈពេលតែមួយថ្ងៃទៅពីរថ្ងៃតែប៉ុណ្ណោះក៏ត្រឡប់មកអង្គភាពវិញ ព្រោះខ្មែរក្រហមចែករបបអាហារសម្រាប់តែប្រជាជនដែលធ្វើការងារនៅក្នុងមូលដ្ឋានតែប៉ុណ្ណោះ។ ដូច្នេះ ពេល

ហូបអាហារម្តងៗ ខ្ញុំត្រូវទៅសុំពីប្រធានរោងបាយសហករណ៍នៅក្នុងភូមិ។ ដោយឡែកនៅក្នុងមន្ទីរពេទ្យខេត្តស្វាយរៀង ខ្ញុំទទួលបានរបបអាហារពីរពេលក្នុងមួយថ្ងៃ និងបានហូបឆ្អែត។ មួយរយៈក្រោយមក ទើបប្រធានអង្គភាពពេទ្យបានកាត់បន្ថយរបបអាហាររបស់ខ្ញុំ ដោយឱ្យហូបតែបបរខាប់ជាមួយ សម្លម្ជូរត្រកួន និងព្រលិតលាយត្រីនិងសាច់ជ្រូកតិចតួចតែប៉ុណ្ណោះ។ ថ្ងៃមួយបន្ទាប់ពីហូបអាហារពេលល្ងាចរួច កម្មាភិបាលថ្នាក់លើបានប្រាប់គ្រូពេទ្យដែលមានឈ្មោះនៅក្នុងបញ្ជីឱ្យនៅជុំគ្នា ដើម្បីឡើងទៅប្រជុំនៅមន្ទីរមួយភ្លែត ក៏ស្រាប់តែបាត់ខ្លួនអ្នកទាំងនោះតែម្តង។ ខ្ញុំមិនដឹងថាគ្រូពេទ្យទាំងនោះប្រព្រឹត្តកំហុសអ្វី ហើយខ្មែរក្រហមយកទៅទីណាឡើយ។

នៅឆ្នាំ១៩៧៧ ខ្ញុំបានផ្លាស់ទៅធ្វើការនៅចម្ការក្រូច នៅកន្ទុយវៃ ក្នុងសង្កាត់ចេក ខាងលិចក្រុងស្វាយរៀង រយៈពេលពីរខែ។ អង្គភាពពេទ្យរបស់ខ្ញុំមានតួនាទីព្យាបាលអ្នកជំងឺ ហើយពេលខ្លះក៏យើងយកថ្នាំអំពូលចាក់ឱ្យអ្នកជំងឺដែរ។ ក្រោយមកទៀត ខ្ញុំបានផ្លាស់ទៅធ្វើការនៅមន្ទីរពេទ្យស្ថិតនៅវត្តស្វាយជ្រំ ក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង និងនៅវត្តព្រះធាតុ ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង តំបន់២៣។ នៅទីនោះ ប្រធានពេទ្យបានចាត់តាំងខ្ញុំឱ្យរៀនមុខវិជ្ជាជំនាញឯកទេសខាងព្យាបាលជំងឺគ្រុនចាញ់ ជាមួយគ្រូពេទ្យមកពីភូមិភាគបូព៌ា។ បន្ទាប់ពីខ្ញុំរៀនចប់ ប្រធានពេទ្យបានបែងចែកក្រុមគ្រូពេទ្យដែលមានសមាជិកសរុប១១នាក់ឱ្យចេញទៅធ្វើការនៅតាមស្រុកនានាក្នុងខេត្តស្វាយរៀង។ ខ្ញុំត្រូវទៅធ្វើការនៅស្រុករមាសហែករយៈពេលមួយខែ។ ខ្ញុំបានដើរជួសឈាមអ្នកជំងឺយកមកពិនិត្យរកមើលជំងឺគ្រុនចាញ់ ព្រោះនៅសម័យនោះប្រជាជនកើតជំងឺគ្រុនចាញ់ច្រើនណាស់។ ខ្ញុំនិងសមាជិកក្រុមបានប្រើមីក្រូស្កុបសម្រាប់ពិនិត្យ និងវិភាគមើលមេរោគ។ លើសពីនោះ ខ្មែរក្រហមក៏បានដាក់ផែនការឱ្យគ្រូពេទ្យនៅតាមភូមិឃុំដើរបាញ់ថ្នាំកម្ចាត់មូសនៅតាមផ្ទះប្រជាជនដែរ។ អំឡុងពេលមកធ្វើការនៅស្រុករមាសហែក ខ្ញុំបានជួបប្រពន្ធរបស់ខ្ញុំម្តងពេលប្រធានកងចាត់តាំងគាត់ឱ្យទៅធ្វើការងារនៅព្រែកត្នោត ក្នុងឃុំសំបួរ។ បន្ទាប់មក ខ្ញុំត្រូវទៅធ្វើការនៅស្រុកកំពង់រោទ៍, ស្រុកស្វាយទាប និងចុងក្រោយនៅស្រុកចន្ទ្រា។ ពេលទៅដល់ស្រុកចន្ទ្រា ខ្ញុំបានហៅគ្រូពេទ្យឃុំ និងស្រុក មកប្រជុំដើម្បីរកវិធីកម្ចាត់មូស ដោយពេលយប់ត្រូវដើរចាប់មូស និងពេលថ្ងៃពិនិត្យមើលមូសដែលចាប់បានទាំងនោះដើម្បីធ្វើការបែងចែកទៅតាមក្រុម ថាតើមូសទាំងនោះស្ថិតនៅក្នុងក្រុមណា ហើយចម្លងមេរោគកម្រិតណាដល់អ្នកជំងឺគ្រុនចាញ់។ បន្ទាប់មក ខ្ញុំត្រូវយកទិន្នន័យដែលប្រមូលបានឡើងទៅប្រជុំនៅមន្ទីរពេទ្យខេត្តស្វាយរៀង ក្នុងរយៈពេលមួយសប្តាហ៍ម្តង។

នៅអំឡុងឆ្នាំ១៩៧៨ ខ្មែរក្រហមបញ្ជូនខ្ញុំឱ្យទៅរស់នៅខាងកើតភ្នំឈើកាច់ ក្នុងស្រុកបាភ្នំ ខេត្តព្រៃវែង។ មួយរយៈក្រោយមកស្រាប់តែមានហេតុការណ៍ផ្ទុះឃ្លាំងគ្រាប់នៅអ្នកលឿង។ ខ្ញុំបានសាកសួរព័ត៌មានពីអ្នកដំណើរដែលបានទៅដល់ទីនោះ ទើបអ្នកដំណើរនោះប្រាប់ថា នៅអ្នកលឿងវៀតណាមចូលមកកាន់កាប់ហើយ និងហាមខ្ញុំមិនឱ្យទៅទីនោះ។ ខ្ញុំបានដើរវៀងមកភាគខាងត្បូងស្រុកស្វាយអន្ទរ ក្នុងខេត្តព្រៃវែង ដើម្បីវិលត្រឡប់មកស្រុកកំណើតវិញ។ ខ្ញុំដើរមកដល់ផ្សារបាតគ្រាស់ ក្នុងឃុំដូង ស្រុករមាសហែក ក៏បានសាកសួរប្រជាជននៅទីនោះរកព័ត៌មានប្រពន្ធរបស់ខ្ញុំដែលរស់នៅភូមិគគីរ។ ប្រជាជននៅផ្សារបាតគ្រាស់ បានប្រាប់ខ្ញុំថាប្រជាជននៅក្នុងភូមិគគីរ ត្រូវបានខ្មែរក្រហមជម្លៀសឱ្យទៅនៅឃុំសម្បត្តិមានជ័យអស់ហើយ។ ខ្ញុំបានទៅជួបប្រពន្ធកូន និងឪពុក ពុកក្មេករបស់ខ្ញុំដែលកំពុងរៀបចំដឹកគោ ទឹមរទេះបរមកភូមិកំណើតវិញ។ ខ្ញុំនិងប្រពន្ធបានមកស្នាក់នៅភូមិត្រពាំងពិការ ឃុំអំពិល ជាបណ្តោះអាសន្នរយៈពេលពីរខែ ព្រោះនៅភូមិកំណើតរបស់ខ្ញុំមានព្រៃដុះជុំជិត និងមានសត្វព្រៃជាច្រើនប្រភេទរស់នៅ ម្យ៉ាងទៀតមិនទាន់មានប្រជាជនចូលទៅរស់នៅទេ។ ក្រោយមក ខ្ញុំនិងគ្រួសារបានសម្រេចចិត្តនាំគ្នាមករស់នៅភូមិត្រពាំងស្គន់ ឃុំគគីរ ស្រុករមាសហែក រហូតមកដល់សព្វថ្ងៃ។

# ឪពុកខ្ញុំ បានបង្រៀនកូនចៅឱ្យដាំដើមគ និង ចេះលះបង់ជូនអង្គការ ប៉ុន្តែអង្គការនៅតែចាប់ខ្លួនគាត់

***មីន សាណាស់***



*កុមារជនជាតិភាគតិចចាមនៅភូមិទី៥ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ហាក់ ម៉ាត់ អាយុ៥២ឆ្នាំ (ក្នុងឆ្នាំ២០០១) មានតួនាទីជាអធិការនគរបាលស្រុកក្រូចឆ្មារ និងរស់នៅក្នុងភូមិទី៥ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម (បច្ចុប្បន្នស្ថិតនៅខេត្តត្បូងឃ្មុំ)។ ម៉ាត់បានផ្តល់បទសម្ភាសន៍ឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ស្តីពីការចងចាំនៃរឿងរ៉ាវដែលធ្លាប់ឆ្លងកាត់ក្នុងរបបខ្មែរក្រហម ជាពិសេសការលត់ដំខ្លួន និងលះបង់សម្ភារជូនអង្គការដើម្បីប្តូរយកវណ្ណៈស្អាតស្អំ។ ម៉ាត់ បានរំឭកថា «ខ្ញុំមិនបានដឹងពីដើមហេតុអ្វី បានជាមានកម្លាំងខ្មែរក្រហមកើតឡើង? ស្រាប់តែស្រុះៗ ឃើញកងកម្លាំងខ្មែរក្រហមចូលមកត្រួតត្រាក្នុងភូមិខ្ញុំរស់នៅ។ ខ្ញុំចងចាំបានថា កងកម្លាំងខ្មែរក្រហមចូលមកត្រួតត្រាភូមិស្វាយឃ្លាំងក្នុងអំឡុងឆ្នាំ១៩៧០។ ចន្លោះពីឆ្នាំ១៩៧០-១៩៧២ គឺថ្នាក់ដឹកនាំខ្មែរក្រហម ធ្វើការយកចិត្តទុកដាក់លើប្រជាជនជនជាតិចាមយ៉ាងកក់ក្តៅ ដូចជាមានចែកសម្ភារណាដែលអ្នកភូមិខ្វះខាត ដូចជា ចែកក្រណាត់ និង មានខោអាវជាដើម។ កងកម្លាំងខ្មែរក្រហមមានចរិតស្អាតស្អំ និង ត្រឹមត្រូវជានិច្ច។ ពេលបំពេញការងារ គឺមានភាពច្បាស់លាស់ និង មិនឱ្យប៉ះពាល់សម្ភារអ្នកភូមិនោះឡើយ។ ហេតុ

នេះ ប្រជាជនក្នុងភូមិមានការគោរពស្រឡាញ់ និងគាំទ្រកម្លាំងបដិវត្តន៍ទាំងស្រុង»។ តួយ៉ាងភូមិជនជាតិចាមតាមបណ្តោយទន្លេមេគង្គ នៃស្រុកក្រូចឆ្មារ ភាគច្រើនត្រូវបានកងកម្លាំងខ្មែរក្រហម គ្រប់គ្រងបានទាំងស្រុង ក៏ព្រោះតែមានកម្លាំងជនជាតិចាមជួយគាំទ្រ។

គួររំឭកថា ក្រោយពេលដែលលោកសេនាប្រមុខ លន់ នល់ បានដណ្តើមអំណាចពីសម្តេចព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ គឺសង្គ្រាមកំពុងរីករាលដាលនៅតាមតំបន់នានាក្នុងប្រទេសកម្ពុជា។ លោកវរសេនីយ៍ឯក ឡេះ កូសេម ដែលមានដើមកំណើតជាប្រជាជនចាម ត្រូវបានរបប លន់ នល់ ផ្តល់តួនាទីឱ្យដឹកនាំកងវរសេនាតូចដែលមានកូនទាហានជាជនជាតិចាម មួយដាច់ដោយឡែក។ ប៉ុន្តែក្នុងអំឡុងឆ្នាំ១៩៧០-១៩៧២ កងវរសេនាតូចនេះ ត្រូវបានរាយការណ៍ថាបានបំផ្លាញ និងសម្លាប់ជាប្រព័ន្ធនូវភូមិដែលខ្មែរក្រហមកំពុងកាន់កាប់។ ក្រោយមក កងវរសេនាតូចជនជាតិចាមត្រូវបានបែងចែកឱ្យចូលទៅតាមអង្គភាពផ្សេងៗទៀត។ ស្របពេលគ្នានេះដែរ ជនជាតិចាមជាច្រើនបានចូលរួមក្នុងបុព្វហេតុបក្សកុម្មុយនីស្ត។ ហេតុនេះភូមិជនជាតិចាមភាគច្រើន ក្រុមទាហាន លន់ នល់ មិនអាចចូលមកគ្រប់គ្រងបាននោះឡើយ។ ម៉ាត់ បានបន្តទៀតថា «ប្រជាជនក្នុងភូមិស្វាយឃ្លាំងរួមទាំងរូបខ្ញុំបានចូលរួមធ្វើការជូនអង្គការបដិវត្តន៍ដោយស្មោះស្ម័គ្រ។ ប៉ុន្តែមិនបានប៉ុន្មានផង ខ្មែរក្រហមចាប់ផ្តើមចោទប្រកាន់មកលើប្រជាជនក្នុងភូមិថា មានពាក់សក្តិ កម្រិតប៉ុណ្ណេះ កម្រិតប៉ុណ្ណោះ និងជាគិញស៊ើបការណ៍ឱ្យទាហាន លន់ នល់។ ករណីចាប់ខ្លួនក៏ឈានមកដល់។ ដន្ទោ លី ម៉ាត់ និង ដន្ទោ ចៃភិនជាពាណិជ្ជករអ្នកលក់ដូរថ្នាំជក់ និងជាថៅកែអួនប្រចាំស្រុកក្រូចឆ្មារ ត្រូវសន្តិសុខស្រុកនាំខ្លួនទៅបាត់ដោយគ្មានមូលហេតុ។ ការបាត់ខ្លួនរបស់អ្នកមានធនធានក្នុងភូមិ ធ្វើឱ្យអ្នកឯទៀតមានការខ្លាចរអា និងប្រុងប្រយ័ត្នខ្លួនជានិច្ច»។

ចំពោះគ្រួសាររបស់ ម៉ាត់ ដែលមានឪពុកឈ្មោះ ដន្ទោ ម៉ាន ហាក់ ជាអ្នកមានទ្រព្យសម្បត្តិច្រើនមួយរូបក្នុងភូមិ តែងតែនិយាយណែនាំ ហាមប្រាមកូនចៅថា៖ «កុំឱ្យភ្លើតភ្លើន កុំនិយាយស្តីអ្វីផ្តេសផ្តាស កូនៗត្រូវដាំដើមគ ត្រូវរក្សាភាពស្ងៀមស្ងាត់ ធ្វើជាគ ធ្វើជាថ្លង់ និង ត្រូវលះបង់ជូនអង្គការ»។ ប៉ុន្តែមិនបានប៉ុន្មានពីការចាប់ខ្លួនរបស់ដន្ទោ លី ម៉ាត់ និង ដន្ទោ ចៃភិន ឪពុករបស់ ម៉ាត់ ត្រូវកម្មាភិបាលថ្នាក់ស្រុកក្រូចឆ្មារចំនួន៤នាក់ មកហៅចេញទៅ ទាំងស្លៀកសារុង និង អាវយឺតដៃខ្លី យកទៅមន្ទីរខាងលិច ក៏បាត់ខ្លួនគ្មានត្រឡប់មកផ្ទះវិញ។ ម៉ាត់ បានត្រឹមតែចងចាំនៅថ្ងៃចុងក្រោយ នៃការបាត់ខ្លួនរបស់ឪពុកថា «មុនពេលកងសន្តិសុខទាំងនោះមកហៅឪពុកគាត់ចេញទៅ គឺពេលព្រឹកឪពុកគាត់បានជិះកង់ដោរ៉ា និងស្លៀកសារុងចាស់ អាវដៃខ្លីក៏ចាស់ ទៅដឹកកាហ្វេ។ ពេលត្រឡប់មកវិញ ឪពុកគាត់មានទម្លាប់សម្រាកលើអង្រឹង និង យោលតិចៗ»។ ចាប់ពីពេលនោះមក ក្រុមគ្រួសាររបស់ ម៉ាត់ មិនដែលបានឃើញមុខឪពុកគាត់ទៀតរហូតដល់សព្វថ្ងៃ។ រយៈពេលពីរថ្ងៃបន្ទាប់នៃការចាប់ខ្លួនឪពុករបស់ ម៉ាត់ ស្រាប់តែមានក្រុមសន្តិសុខចំនួនបួននាក់មកសុំឆែកឆេរផ្ទះ ម៉ាត់។ ក្រុមសន្តិសុខទាំងនោះ ធ្វើការឆែកឆេរយ៉ាងលម្អិត សូម្បីប្រហោងតាមជញ្ជាំងផ្ទះ ឬស្នាមប្រេះ ដំបូលផ្ទះ រួចកត់ត្រាចូលក្នុងកំណត់ហេតុ។ សម្ភារ លុយកាក់ មាសប្រាក់ក្នុងផ្ទះ ក៏កត់ត្រាចូលគ្មានសល់ និងមិនឱ្យបាត់សម្ភារក្នុងផ្ទះសូម្បីតែបន្តិចៗ ជាចុងក្រោយគឺសមាជិកក្នុងគ្រួសាររបស់ ម៉ាត់ ត្រូវផ្តិតមេដៃទទួលស្គាល់ ពីការស្នើសុំឆែកឆេរ និងចំនួនសម្ភារក្នុងបញ្ជីគឺពិតជាមានលក្ខណៈត្រឹមត្រូវ។

ក្រោយមកកងសន្តិសុខស្រុក នៅតែតាមចាប់ខ្លួនអ្នកភូមិជាច្រើននាក់ទៀត ដែលមានតួនាទីជាថ្នាក់ដឹកនាំភូមិផ្នែកសាសនា និងអ្នកមានទ្រព្យសម្បត្តិច្រើនៗ ម៉ាត់ និង គ្រួសារកាន់តែភ័យខ្លាច និង ព្រួយបារម្ភពីសុវត្ថិភាពគ្រួសារ។ ហេតុនេះ ម៉ាត់ បានធ្វើជាលត់ដំខ្លួន នាំប្អូនៗចុះជីកស្រះ ធ្វើស្រែចម្ការ បង្ហាញឱ្យអង្គការបានឃើញពីវណ្ណៈស្អាតស្អំ។ លើសពីនោះ ម៉ាត់ បានលះបង់សម្ភារផ្ទាល់ខ្លួនដោយលក់ម៉ូតូ

សត្វចិញ្ចឹមជាច្រើន យកថវិកា មកទិញរទេះ និង កាណូត សម្រាប់ដឹកសម្ភារមានដូចជា សណ្តែកបាយ សណ្តែកប្រេង ក្រូច ចេក ល្ហុង ពីស្រុកក្រូចឆ្មារ និង ស្រុកស្ទឹងត្រង់ យកទៅលក់ឱ្យតំបន់ លន់ នល់ (ទីរួមខេត្តកំពង់ចាម) ដែលកំពុងកាន់កាប់រួចទិញអង្ករយកមកលក់ប្ដូរផ្គត់ផ្គង់ឱ្យតំបន់ខ្មែរក្រហមវិញ។ ប៉ុន្តែអង្គការនៅតែចាត់ទុកក្រុមគ្រួសាររបស់ ម៉ាត់ ស្ថិតក្នុងបញ្ជីវណ្ណៈមិនស្អាតស្អំ។ ម៉ាត់ ជឿជាក់លើអង្គការណាស់ ដោយលះបង់យកចម្ការអំពៅ កិនជាស្ករ និង ផលស្រូវដែលស្តុកក្នុងផ្ទះ កិនជាអង្ករសម្រាប់ចិញ្ចឹមក្រុមសាមគ្គី។ ប៉ុន្តែខ្មែរក្រហមបានត្រឹមចាត់តាំង ម៉ាត់ ជាប្រធានក្រុមសាមគ្គី។ ក្រុមសាមគ្គីក្នុងដំណាក់កាលនោះ គឺមានន័យថា ក្រុមប្រជាជនដែលមានវណ្ណៈមិនស្អាតស្អំ។ ទោះបីជា ម៉ាត់ ខំធ្វើល្អ និង លះបង់យ៉ាងណាក៏ដោយ អង្គការនៅតែមិនព្រមឱ្យគ្រួសារម៉ាត់ ចូលក្នុងក្រុមសហករណ៍។ ក្រុមសាមគ្គី និង ក្រុមសហករណ៍ក្នុងរបបខ្មែរក្រហម មានការលំបាក និង ក្រីក្រ ដូចគ្នា តែ ម៉ាត់ ចង់មានឈ្មោះក្នុងបញ្ជីសហករណ៍ ព្រោះអ្នកក្នុងសហករណ៍គឺកើតចេញពីវណ្ណៈស្អាតស្អំ និងរស់នៅដោយមិនសូវមានការភ័យខ្លាចច្រើន។

នៅឆ្នាំ១៩៧៥ ក្រុមសាមគ្គី និង ក្រុមសហករណ៍ភូមិស្វាយឃ្លាំង កាន់តែមានភាពលំបាក ព្រមទាំងការគាបសង្កត់ពីកម្លាំងខ្មែរក្រហម។ បញ្ជាហាមប្រាមផ្នែកសាសនា មិនឱ្យជនជាតិចាមគោរពតាមប្រពៃណីសាសនាអ៊ិស្លាម ការបាត់ខ្លួនថ្នាក់ដឹកនាំភូមិជាច្រើន បានធ្វើឱ្យប្រជាជនទ្រាំទៀតលែងបាន ក៏នាំគ្នាងើបបះបោរឡើង។ គ្រាប់កាំភ្លើងរបស់កម្លាំងខ្មែរក្រហម បាញ់មកអ្នកភូមិផ្ទុះពេញទឹកពេញដី។ សម្រែកស្រែករបស់អ្នកភូមិដែលមានតែកាំបិតក៏ឮតែកាប់កាប់ៗ កម្លាំងបះបោរបានស្លាប់ជាច្រើន និងគ្មានកម្លាំងប្រឆាំងបន្តទៅមុខទៀត។ ក្នុងថ្ងៃតែមួយនោះ អ្នកភូមិស្វាយឃ្លាំង រួមទាំង គ្រួសារ ម៉ាត់ ត្រូវខ្មែរក្រហមជម្លៀសចេញពីភូមិភ្លាមៗ យកទៅឃុំឃាំង។ ម៉ាត់ ត្រូវកម្លាំងខ្មែរក្រហម ឃុំក្នុងឡថ្នាំរយៈពេលប្រមាណជា២០ថ្ងៃ ចំណែកម្តាយ ប្អូនៗ និង ប្រពន្ធកូនម៉ាត់ ត្រូវឃុំឃាំង នៅវត្តកញ្ចក់ ស្រុកក្រូចឆ្មារ។ ក្រោយមក កម្លាំងខ្មែរក្រហម បានជម្លៀសក្រុមគ្រួសារម៉ាត់ តាមរយៈកាណូត យកទៅដាក់ភូមិព្រែកអាជី ជាភូមិជនជាតិខ្មែរ។ ស្ថិតក្នុងភូមិព្រែកអាជី គ្រួសារម៉ាត់ ត្រូវធ្វើការក្នុងសហករណ៍។ ប្រជាជនមូលដ្ឋានអាណិតស្រឡាញ់គ្រួសារម៉ាត់ ព្រមទាំងលួចផ្តល់ជាម្ហូបអាហារដល់គ្រួសារ ម៉ាត់។ កន្លងទៅមិនបានប៉ុន្មាន ម៉ាត់ បានឮដំណឹងពីអ្នកមូលដ្ឋាន អំពីអង្គការ និងដកប្រជាជនចាមទាំងអស់ឱ្យទៅកាន់តំបន់ផ្សេងៗទៀតដូចជា តំបែរ សូភាស (ស្រុកស្ទឹងត្រង់) និង កំពង់ធំៗ ជាសំណាងសម្រាប់គ្រួសារ ម៉ាត់ គឺអង្គការឱ្យទៅរស់នៅក្នុងភូមិសូភាសទី២ ឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ ស្ថិតក្នុងភូមិសូភាស បានរយៈពេលមួយឆ្នាំ ម្តាយរបស់ ម៉ាត់បានស្លាប់ដោយសារអត់ឃ្លាន។

ជាចុងក្រោយ ម៉ាត់បានលើកឡើងថា «រឿងរ៉ាវក្នុងរបបបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃវាជាការឈឺចាប់ និង មិនអាចបំភ្លេចបាននូវអំពើប្រល័យពូជសាសន៍ មកលើប្រជាជនគ្រប់ជាតិសាសន៍។ យើងគួរតែថែរក្សាការចងចាំរឿងរ៉ាវទាំងនេះ សម្រាប់អ្នកជំនាន់ក្រោយ និងនិយាយប្រាប់កូនចៅតូចៗរបស់យើងជាបន្តទៀត»។



សឺនប៉ុហោជាភាសាចាមថា ម៉ាតាហ្គា គឺជាប៉មអ៊ិស្លាមមួយដែលបានសាងសង់ឡើងនៅដើមសតវត្សរ៍ទី១៩របស់ជនជាតិភាគតិចចាមនៅភូមិទី៥ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឡុង សៀង ៖ កងឡើងភ្លាតនៅទួលព្រីង ក្នុងរបបខ្មែរក្រហម

**សោម ប៊ុនថន**

ខ្ញុំឈ្មោះ ឡុង សៀង កើតឆ្នាំ១៩៤០ នៅភូមិពោធិ៍តារស់ ឃុំបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ ខ្ញុំគឺជាកូនទី៤ ក្នុងចំណោមបងប្អូនបង្កើតចំនួន ៤នាក់។ កាលពីក្មេងខ្ញុំចូលរៀននិងបួសនៅវត្តថ្មី ស្ថិតនៅក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ ខ្ញុំបានសឹកនៅសម័យសង្គមរាស្ត្រនិយម រួចហើយរៀបការប្រពន្ធ និងមានកូនចំនួន៣នាក់។ បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ រដ្ឋាភិបាលរបស់ លន់ នល់ បានមកចាប់ខ្ញុំឱ្យចូលបម្រើកងទ័ព និងបញ្ជូនខ្ញុំទៅមជ្ឈមណ្ឌលហ្វឹកហាត់យុទ្ធសាស្ត្រ នៅកំបូល ស្ថិតនៅខាងលិចទីក្រុងភ្នំពេញ។ ខ្ញុំហ្វឹកហាត់បានរយៈពេលពីរខែ អង្គភាពយោធាបានបញ្ជូនខ្ញុំត្រឡប់មកធ្វើការនៅខេត្តស្វាយរៀងវិញ។ អំឡុងពេលនោះ រដ្ឋាភិបាល លន់ នល់ គ្រប់គ្រងតែទីប្រជុំជនសំខាន់ៗ និងក្រុងស្វាយរៀងតែប៉ុណ្ណោះ ចំណែកនៅតាមភូមិ ឃុំស្រុកនិងជាយក្រុងគ្រប់គ្រងដោយកងកម្លាំងរំដោះខ្មែរក្រហម។ ទោះបីយ៉ាងណា នៅពេលខ្ញុំបើកប្រាក់ខែម្តងៗ ខ្ញុំតែងតែលួចលាក់យកប្រាក់មួយចំនួនទៅឧបត្ថម្ភកងកម្លាំងរំដោះខ្មែរក្រហមជាសម្ងាត់។



ឡុង សៀង រស់នៅភូមិពោធិ៍តារស់ ឃុំបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅពេលខ្មែរក្រហមគ្រប់គ្រងខេត្តស្វាយរៀង នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កម្មាភិបាលខ្មែរក្រហមនៅតំបន់រំដោះបានចោទប្រកាន់ខ្ញុំថាធ្លាប់ធ្វើជាកងទ័ព លន់ នល់ រួចហើយចាប់ខ្លួនខ្ញុំបញ្ជូនទៅអប់រំនៅស្រុកស្វាយជ្រំ។ នៅទីនោះខ្មែរក្រហមបានបង្រៀនខ្ញុំអំពីមាគ៌ាដឹកនាំរបស់ខ្មែរក្រហម ហើយពេលទំនេរគ្រូបង្រៀនខ្ញុំឱ្យច្រៀងចម្រៀងបដិវត្តន៍ ប៉ុន្តែមិនបានវាយធ្វើបាបខ្ញុំទេ។ ខ្មែរក្រហមបានឃុំឃាំងខ្ញុំរយៈពេល៤ខែ ហើយក្រោយមកបានស្រាវជ្រាវរកឃើញថា ខ្ញុំធ្លាប់ជួយឧបត្ថម្ភគាំទ្រដល់ចលនារបស់ខ្លួន ទើបដោះលែងខ្ញុំឱ្យត្រឡប់មកផ្ទះនៅភូមិពោធិ៍តារស់វិញ។ រីឯកងទ័ព លន់ នល់ មួយចំនួនដែលមិនធ្លាប់បានបង់វិភាគទានដល់កងកម្លាំងរំដោះខ្មែរក្រហមកន្លងមក ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោលទាំងអស់។

ពេលខ្ញុំមករស់នៅភូមិពោធិ៍តារស់ ប្រធានភូមិបានចាត់ខ្ញុំឱ្យធ្វើការនៅកងផលិតស្ករត្នោត ដែលបោះទីតាំងនៅទួលព្រីង ក្នុងភូមិពោធិ៍តារស់ ឃុំបាសាក់។ កងរបស់ខ្ញុំមានសមាជិក១០នាក់ ហើយក្នុងសមាជិកម្នាក់ត្រូវឡើងយកទឹកត្នោតឱ្យបាន១៥ដើមក្នុងមួយថ្ងៃ ដើម្បីរំងាស់យកស្ករ។ កងរបស់ខ្ញុំបានយកដើមឫស្សីធំៗមកកាត់ធ្វើបំពង់រួចហើយយកមកអប់ដើម្បីឱ្យមានក្លិនឈ្ងុយ ទុកត្រងទឹកត្នោត។ សមាជិកនៅក្នុងផលិតស្ករត្នោត អាចផឹកទឹកត្នោត និងហូបស្ករត្នោតដែលផលិតបាន ប៉ុន្តែប្រធានកងហាមមិនឱ្យយកទឹកត្នោត និងស្ករត្នោតមកផ្ទះទេ។ ចំណែករបបអាហារ ខ្ញុំនិងសមាជិកកងផលិតស្ករត្នោតហូបនៅក្នុងអគ្គភាពតែម្តង ដោយមានខាងចុងភៅធ្វើម្ហូប ប៉ុន្តែយើងហូបមិនបានគ្រប់គ្រាន់ឡើយ។ ពេលល្ងាចទើបខ្ញុំត្រឡប់មកដេកនៅផ្ទះវិញ។ ក្រៅពីឡើងយកទឹកត្នោត កងផលិតស្ករត្នោតរបស់ខ្ញុំត្រូវដើររកខសនិងស្ទឹកឈើមកដុតរំងាស់ទឹកត្នោតយកស្ករដោយខ្លួនឯង ព្រោះកងម៉ែៗត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិឱ្យទៅធ្វើស្រែនៅភូមិតាប៉ី ឃុំតាសួស ស្រុកស្វាយជ្រំ អស់ហើយ។ កងរបស់ខ្ញុំឡើងយកទឹកត្នោតមករំងាស់រាល់ថ្ងៃ ទោះបីជារដូវវស្សាក៏មិនឈប់សម្រាកដែរ។ ចំពោះស្ករត្នោតដែលកងរបស់ខ្ញុំផលិតបាន ប្រធានសហករណ៍បានយកទៅទុកនៅរោងបាយរួម។

ខ្ញុំនៅចាំថា នៅវេលាម៉ោង១០ព្រឹកថ្ងៃមួយ ខ្ញុំបានឡើងដើមត្នោតកម្ពស់១៥ម៉ែត្រនៅខាងក្រោយភូមិដើម្បីយកទឹកត្នោតមករំងាស់ដូចសព្វដង ប៉ុន្តែបែដន្យបង្អោងដែលខ្ញុំជាន់បានបាក់បណ្តាលឱ្យខ្ញុំធ្លាក់និងសន្លប់បាត់ស្មារតី។ ពេលនោះអ្នកធ្វើការនៅក្នុងអគ្គភាពផលិតស្ករត្នោតបានសែងខ្ញុំមកផ្ទះ ដើម្បីឱ្យពេទ្យក្នុងភូមិដែលភាគច្រើនជ្រើសចេញពីគ្រូជំរុំថ្នាំបុរាណ ជួយព្យាបាល។ បន្ទាប់មកឈ្លបខ្មែរក្រហមបានទៅប្រាប់ប្រពន្ធខ្ញុំដែលធ្វើការនៅភូមិតាប៉ី ប៉ុន្តែប្រធានភូមិតាប៉ីមិនទាន់ឱ្យប្រពន្ធខ្ញុំមកសួរសុខទុក្ខខ្ញុំភ្លាមៗទេ គឺឱ្យឪពុកក្មេកខ្ញុំមកមើលខ្ញុំមុន។ ខ្ញុំបានដឹងខ្លួនឡើងវិញនៅវេលាម៉ោង៧យប់។ ឪពុកខ្ញុំមកមើលខ្ញុំមួយភ្លែត ក៏ត្រឡប់ទៅកងរបស់គាត់វិញ។ លុះវេលាព្រឹកថ្ងៃបន្ទាប់ ទើបប្រពន្ធរបស់ខ្ញុំបានមកជួបខ្ញុំ ប៉ុន្តែខ្មែរក្រហមមិនឱ្យគាត់នៅយូរឡើយ ដូច្នេះប្រពន្ធរបស់ខ្ញុំក៏ទូលខសត្រឡប់ទៅកងរបស់គាត់នៅភូមិតាប៉ីវិញ។ ដំបូង ខ្ញុំមិនអាចក្រោកដើរបានទេ ព្រោះខ្ញុំឈឺចុកចាប់ត្រង់ឆ្អឹងត្រគាក។ ឃើញដូច្នេះពូរបស់ខ្ញុំនៅក្នុងកងវេញខ្សែគោបានមកជួយចាប់សរសៃ និងធ្វើចលនាឱ្យខ្ញុំ។ រយៈពេលមួយខែក្រោយមក ទើបខ្ញុំអាចដើរបាន។ ខ្មែរក្រហមលែងឱ្យខ្ញុំឡើងត្នោតទៀតហើយ គឺបានប្តូរខ្ញុំមកបររទេះដឹកខសពីភូមិពោធិ៍តារស់ ឃុំបាសាក់ ទៅភូមិតាប៉ី ឃុំតាសួស។

នៅពេលកងទ័ពខ្មែរក្រហមមានជម្លោះជាមួយកងទ័ពវៀតណាម នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសខ្ញុំ និងកងឡើងត្នោតទាំងអស់ចេញពីភូមិពោធិតារស់ ឱ្យទៅរស់នៅភូមិតាប៉ី ឃុំតាសួស ចំណែកគោក្របី ខ្មែរក្រហមបានកៀងយកទៅដាក់នៅវត្តជ្រៃក្តោង ហៅវត្តតានូ ស្ថិតនៅភូមិតានូ ឃុំចំបក់ ស្រុកស្វាយជ្រំ។ ដូច្នេះនៅក្នុងភូមិពោធិ៍តារស់លែងមានប្រជាជនរស់នៅទៀតហើយ គឺមានតែឈ្លបនិងកម្មាភិបាលខ្មែរក្រហមប៉ុណ្ណោះ។ ពេលមករស់នៅភូមិតាប៉ី ប្រធានភូមិចាត់តាំងខ្ញុំឱ្យបររទេះដដែល។ ខ្ញុំបានដឹកគោក្របីដែលងាប់នៅតាមភូមិមកដាក់នៅរោងបាយរួម។ ខ្ញុំធ្វើការនៅភូមិតាប៉ីបានមួយរយៈស្រាប់តែខ្មែរក្រហមថ្នាក់លើចុះមកចាប់គណៈឃុំ ប្រធានសន្តិសុខ និងកម្មាភិបាលខ្មែរក្រហមធំៗមួយចំនួនទៀតច្រកការុង ហើយដឹកចេញទៅបាត់អស់។ បន្ទាប់មកខ្មែរក្រហមយកកម្មាភិបាលថ្មីមកគ្រប់គ្រងឃុំតាសួសជំនួសកម្មាភិបាលចាស់ៗ។ នៅពេលព្រឹកថ្ងៃមួយ ខ្មែរក្រហមបានជម្លៀសខ្ញុំ ប្រពន្ធខ្ញុំ និងកូនៗព្រមទាំងប្រជាជនថ្មីជាច្រើនគ្រួសារទៀតទៅទិសខាងលិច។ ពេលខ្ញុំដើរមកដល់អ្នកលឿង ក្នុងខេត្តព្រៃវែង ឪពុករបស់ខ្ញុំបានឈឺធ្ងន់ និងស្លាប់នៅទី

នោះ។ ខ្ញុំបានសែងឪពុកខ្ញុំទៅកប់ដោយផ្ទាល់ដៃនៅទីលានចុះខ្ទម្ភាគចក្រ ស្ថិតនៅខាងត្បូងផ្លូវជាតិលេខ១ បន្ទាប់មកនាំគ្នាឡើងជិះស្រឡាងមកឈប់នៅច្បារអំពៅ។ នៅទីនោះខ្មែរក្រហមចែកខោខ្មៅអាវខ្មៅ និងក្រមាខៀវ ឱ្យខ្ញុំគ្រួសារខ្ញុំនិងប្រជាជនជម្លៀសម្នាក់មួយសម្រាប់ រួចហើយឱ្យឡើងជិះរថយន្តទៅឈប់នៅចំណតរថភ្លើងក្នុងក្រុងភ្នំពេញ។

ខ្ញុំជិះរថភ្លើងបន្តទៅឈប់នៅចំណតរថភ្លើង ក្នុងឃុំព្រៃស្វាយ ក្នុងស្រុកមោងឫស្សី ខេត្តបាត់ដំបង។ បន្ទាប់មកខ្មែរក្រហមបាននាំខ្ញុំ និងគ្រួសារដើរទៅវត្តរុន (ស្ថិតនៅខាងកើតទីរួមស្រុកមោងឫស្សី) ដែលខ្មែរក្រហមបានយកធ្វើជាមន្ទីរពេទ្យ។ ខ្ញុំនិងគ្រួសារបានដេកនៅវត្តរុនមួយយប់។ លុះព្រឹកថ្ងៃបន្ទាប់ ខ្មែរក្រហមបាននាំគ្រួសារខ្ញុំ និងប្រជាជនជម្លៀសជាង១០គ្រួសារ ទៅនៅសហករណ៍ទួលធ្នង់ ដែលមានចម្ងាយប្រមាណកន្លះគីឡូម៉ែត្រពីវត្តរុន។ ប្រធានសហករណ៍បានចាត់តាំងខ្ញុំឱ្យបររទេះដឹកឫស្សីពីព្រៃមកឱ្យក្រុមជាងធ្វើរោងឱ្យប្រជាជនជម្លៀសស្នាក់នៅ, កងយាយៗទៅច្រូតភ្លាំងយកមកក្រងប្រក់ដំបូល ហើយកូនៗរបស់ខ្ញុំនៅអង្គភាពកុមារ។ ពេលចប់ពីការងារ ខ្ញុំត្រូវទៅហូបអាហារនៅរោងបាយរួម ប៉ុន្តែខ្ញុំហូបមិនបានគ្រប់គ្រាន់ទេ គឺមានតែសម្លរាវៗគ្មានសាច់។ កូនរបស់ខ្ញុំបានលួចរត់ចេញពីកងកុមារមកជួបខ្ញុំនិងប្រពន្ធខ្ញុំជាញឹកញាប់ ដូច្នេះខ្ញុំតែងតែលួចយករបបអាហាររបស់ខ្ញុំទៅចែកឱ្យកូនៗ។ មួយរយៈក្រោយមក ខ្ញុំបាក់កម្លាំង និងធ្លាក់ខ្លួនឈឺ ទើបប្រធានសហករណ៍ឱ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យវត្តរុន។ គ្រូពេទ្យបានឱ្យថ្នាំអាចម៍ទន្សាយខ្ញុំលេប និងឱ្យហូបបបរ។ បន្ទាប់មកខ្មែរក្រហមបញ្ជូនខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យដំណាក់ឈើក្រម ស្ថិតនៅជាប់នឹងជើងភ្នំបន្តទៀត ចំណែកប្រពន្ធរបស់ខ្ញុំដែលទើបសម្រាលកូនបានមួយថ្ងៃ នៅវត្តរុនដដែល។ នៅម្តុំមន្ទីរពេទ្យដែលខ្ញុំសម្រាកខ្វះខាតទឹកខ្លាំងណាស់ ដូច្នេះខ្ញុំបានចេញទៅសម្រិតទឹកពីបាតអណ្តូងយកមកផឹក និងប្រើប្រាស់។ មិនយូរប៉ុន្មាន ពេទ្យនិងប្រធានរោងបាននាំគ្នាចាកចេញពីអង្គភាពអស់ ដោយទុកឱ្យខ្ញុំ និងអ្នកជំងឺដេករង់ចាំនៅពេទ្យ។ ក្រោយមក ទើបខ្ញុំដឹងថាកងទ័ពវៀតណាមបានរំដោះទីក្រុងភ្នំពេញបានរយៈពេលមួយខែហើយ ទើបធ្វើខ្មែរក្រហមភ័យខ្លាច និងរត់គេចខ្លួន។ នៅខណៈនោះ កូនៗរបស់ខ្ញុំដែលធ្វើការនៅអង្គភាពកុមារ ទាំង៣នាក់បានមករកខ្ញុំ។ កូនរបស់ខ្ញុំបានចេញទៅយកស្រូវនៅតាមសហករណ៍បានមួយល្អីយកមកបុក រួចហើយរែងយកអង្ករដើម្បីដាំបាយហូប។ បន្ទាប់មកខ្ញុំនិងប្រជាជនជម្លៀសបានទៅនៅប្រមូលផ្តុំគ្នានៅអណ្តូង១០០ និងបានជួបកងទ័ពខ្មែរក្រហមពីនាក់មកពីស្រុកចន្ទ្រា ខេត្តស្វាយរៀង។ កងទ័ពខ្មែរក្រហមពីរនាក់នោះបានដោះសម្លៀកបំពាក់យោធាចេញ រួចហើយស្លៀកពាក់ស៊ីវិលវិញ។ កងទ័ពទាំងពីរនាក់នោះនាំខ្ញុំនិងប្រជាជនជម្លៀសចេញពីអណ្តូង១០០ ដើម្បីគេចចេញពីកងទ័ពខ្មែរក្រហមដែលស្នាក់ចាំបាញ់។ ខ្ញុំបានជួបប្រពន្ធនៅស្ថានីយ៍រថភ្លើងព្រៃស្វាយ រួចហើយនាំគ្នាដើរត្រឡប់មកស្រុកកំណើតវិញ។ ខ្ញុំបានឈប់សម្រាកនៅមន្ទីរពេទ្យស្រុកក្រគរ ខេត្តពោធិ៍សាត់មួយរយៈ ដោយសារខ្ញុំមានជំងឺរាកធ្ងន់ធ្ងរ ចំណែកប្រពន្ធកូនរបស់ខ្ញុំបានត្រឡប់មកផ្ទះមុន។ ក្រោយមករថយន្តកងទ័ពវៀតណាមបានដឹកខ្ញុំ និងប្រជាជនជម្លៀសផ្សេងទៀតមកដាក់នៅច្បារអំពៅ ហើយខ្ញុំក៏បន្តដំណើរមករស់នៅជួបជុំប្រពន្ធកូនភូមិកំណើតវិញ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំមានបងប្អូនពីរនាក់បានស្លាប់ ដោយប្អូនម្នាក់ស្លាប់ដោយសារជំងឺ និងម្នាក់ទៀតខ្មែរក្រហមយកទៅសម្លាប់។ សព្វថ្ងៃនៅរស់តែខ្ញុំ និងបងខ្ញុំម្នាក់ប៉ុណ្ណោះ។

# អ៊ុន អៀង ៖ ខ្មែរក្រហមមានកម្លាំង និងស្មារតីនៅលើសមរភូមិ

**លី សុខឃាង**

អ៊ុន អៀង ភេទប្រុស អាយុ៧២ឆ្នាំ មានទីកន្លែងកំណើតនៅភូមិថ្មី ឃុំក្រយា ស្រុកស្ទោង ខេត្តកំពង់ធំ។ បច្ចុប្បន្ន អៀង រស់នៅក្នុងភូមិទឹកជុំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

អៀង និយាយថា៖ «ខ្ញុំមានបងប្អូនបង្កើតចំនួន ៤នាក់ ហើយខ្ញុំជាកូនទីពីរនៅក្នុងគ្រួសារ។ កាលពីវ័យកុមារ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៩។ ខ្ញុំបានឈប់រៀនដោយសារជីវភាពគ្រួសារមានការខ្វះខាត។ ខ្ញុំក៏បានបួសជាព្រះសង្ឃដើម្បីបានបន្តការសិក្សានៅក្នុងវត្តមួយ នៅក្នុងឃុំក្រយា។ ជីវភាពរស់នៅរបស់ប្រជាជនភាគច្រើននៅក្នុងភូមិ មានជីវភាពខ្សត់ខ្សោយខ្លាំង។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺថា ប្រជាជនមានសណ្ដានចិត្តល្អ បេះដូងទុក្ខធុរៈគ្នាទៅវិញទៅមក និងមិនសូវមានការឈ្លោះទាស់ទែងគ្នាទេ។ នៅជំនាន់នោះ គ្រួសាររបស់ខ្ញុំមិនមានមុខរបរបុកការងារអ្វីធ្វើនោះទេ ក្រៅពីការងារធ្វើស្រែចម្ការ។

នៅក្នុងឆ្នាំ១៩៧២ ខ្ញុំត្រូវបានកងទ័ពខ្មែរក្រហមប្រមូលយកទៅធ្វើជាកងទ័ពនៅក្នុងព្រៃ។ ដំបូងឡើយ ខ្ញុំបានកាន់កាំភ្លើងអាការ៤៧។ ខ្ញុំមានវ័យជំទង់ហើយ។ បន្ទាប់មកខ្ញុំក៏បានចូលទៅវាយនៅសមរភូមិជាមួយកងទ័ពជាច្រើននាក់ទៀតនៅភូមិភាគឧត្តរ។ នៅក្នុងសមរភូមិ មានភាពស្មុគស្មាញជាខ្លាំងកងទ័ពទាំងពីរភាគីអាចស្លាប់គ្រប់ពេល។ ប៉ុន្តែនៅពេលកងទ័ពចូលដល់សមរភូមិហើយ គ្មានអ្នកណាម្នាក់ខ្លាចញញើតនឹងការធ្វើសង្គ្រាមនោះទេ។ ជំនាន់នោះ យុវជនដែលចូលជាកងទ័ពភាគច្រើនមានអាយុចាប់ពី១៧ឆ្នាំទៅ១៨ឆ្នាំ។ កងទ័ពខ្មែរក្រហម មានការស៊ូទ្រាំខ្លាំងណាស់ចំពោះការវាយប្រយុទ្ធប្រឆាំងជាមួយកងទ័ព លន់ នល់។ បើទោះបីជាកងទ័ពខ្មែរក្រហមមិនសូវមានអាវុធទំនើបៗដូចកងទ័ព លន់ នល់ ក៏ពិតមែន កងទ័ពខ្មែរក្រហមមានទាំងកម្លាំង និងស្មារតីមុតមាំ។

ពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំតែងតែនឹកគិតដល់ក្រុមគ្រួសារនៅឯស្រុកកំណើត។ ប៉ុន្តែ នៅក្នុងសមរភូមិកំពុងក្តៅគគុក ខ្ញុំមិនអាចដកខ្លួនចេញភ្លាមៗបាននោះទេ។ គោលដៅខ្ញុំគឺត្រូវការពារទឹកដីជូនជាតិមាតុភូមិមកវិញ ទើបខ្ញុំអាចមានឱកាសទៅជួបជុំគ្រួសារវិញបាន។ នៅគ្រប់ខ្សែត្រៀមទាំងអស់កងទ័ពត្រូវមានរណ្ដៅត្រង់សេដើម្បីការពារខ្លួនអំឡុងពេលវាយជាមួយ លន់ នល់។ ប្រសិនបើកងទ័ពមួយណាមិនជីករណ្ដៅត្រង់សេទេ យើងគ្មានអ្វីការពារអាយុជីវិតខ្លួនឡើយ។

នៅអំឡុងពេលវាយសម្រុកចូលទីក្រុងភ្នំពេញ សង្គ្រាមកាន់តែខ្លាំងឡើងៗ។ កងទ័ពទាំងពីរភាគីក៏មានការស្លាប់បាត់បង់ជីវិតកាន់តែច្រើនដែរ។ កងទ័ព លន់ នល់ ទម្លាក់គ្រាប់បែកទាំងយប់ទាំងថ្ងៃ ដែលធ្វើឱ្យកងទ័ពខ្មែរក្រហមនៅក្នុងព្រៃមិនអាចដាំបាយ ឬសម្រាកបានស្រួលបួលនោះទេ។ ការអុកឡុករបស់កងទ័ព លន់ នល់ មកលើកងទ័ពខ្មែរក្រហមទាំងយប់ទាំងថ្ងៃនេះហើយ ដែលធ្វើឱ្យយើងខឹងកាន់តែខ្លាំងឡើង និងប្ដេជ្ញាវាយកម្ទេចវិញ។

នៅចុងឆ្នាំ១៩៧៥ ខ្ញុំត្រូវរបួសដៃ នៅសមរភូមិព្រែកក្តាម។ កាលណោះខ្ញុំ រួមទាំងកងទ័ពជាច្រើននាក់ទៀតបានសម្រុកវាយចូលទៅរំដោះទីក្រុងភ្នំពេញ

ពីទាហាន លន់ នល់។ ការវាយតទល់ប្រយុទ្ធគ្នារវាងភាគី លន់ នល់ និងភាគីកងទ័ពខ្មែរក្រហម ធ្វើឱ្យស្លាប់មនុស្សអស់ជាច្រើននាក់។ គ្រឿងសព្វាវុធរបស់កងទ័ព លន់ នល់ មានភាពទំនើបជាងខាងខ្មែរក្រហម ដោយសារមានអាមេរិកជួយផ្គត់ផ្គង់។ ប៉ុន្តែបើនិយាយពីកម្លាំងវិញ ខ្មែរក្រហមមានសន្ទុះខ្លាំងជាង ព្រោះកងកម្លាំងភាគច្រើនគឺជាប្រជាជនដែលស្ម័គ្រចិត្តចូលការពារទឹកដី មិនខ្លាចស្លាប់ និងបូជាសាច់ស្រស់ឈាមស្រស់ជូនជាតិមាតុភូមិ។ កងកម្លាំងខ្មែរក្រហមកាន់តែវាយរំកិលទៅមុខឆ្ពោះទៅទីក្រុងភ្នំពេញរហូតដល់ទទួលជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

ខណៈពេលខ្ញុំចូលទៅដល់ទីក្រុងភ្នំពេញភ្លាមៗ ខ្ញុំពិតជាមានការសោកស្តាយ និងស្រណោះដល់ទីក្រុងយ៉ាងខ្លាំង ដោយសារមើលឃើញពីសំណង់អគារបាក់បែកបន្សល់ទុកពីការទម្លាក់គ្រាប់បែក។ ជាពិសេស ខ្ញុំមានអារម្មណ៍សង្វេគជាពន់ពេកណាស់ នៅពេលដែល ប្រជាជនត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ។ នៅពេលខ្ញុំឃើញទិដ្ឋភាពបែបនេះ ខ្ញុំមិនយល់ពីនិយមន័យនៃការចង់បានរបស់ខ្មែរក្រហមនោះទេថាតើមានមូលហេតុអ្វីដែលត្រូវឱ្យប្រជាជនខ្មែរចាកចេញពីទីក្រុងភ្នំពេញ។ ខ្ញុំបានឃើញប្រជាជនជាច្រើននាក់ធ្វើដំណើរថ្មើរជើង ដោយទឹកមុខក្រៀមក្រំចំពោះការចាកចេញពីផ្ទះសម្បែងរបស់ខ្លួន។ អ្នកខ្លះដើរពរកូន។ អ្នកខ្លះទៀតរុញរទេះដឹកម្តាយឪពុកចាស់ៗ និងសម្ភារប្រើប្រាស់ផ្សេងៗ រីឯអ្នកខ្លះទៀតអត់មានស្បែកជើងពាក់ ហើយយកក្រណាត់អាវមករុំលើជើង ដើម្បីកុំឱ្យក្តៅឬរលាកបាតជើង។ ខ្ញុំក៏មិនដឹងថា ប្រជាជនហូបបាយ ហូបទឹកនៅទីណានោះទេ បើមនុស្សវក់វីពេញផ្លូវបែបនេះ។

នៅចន្លោះឆ្នាំ១៩៧៧-១៩៧៨ ខ្ញុំក៏ត្រូវរបួសជើងម្តងទៀត អំឡុងពេលឈរជើងនៅតាមព្រំដែនកម្ពុជា-វៀតណាម។ កាលនោះប្រហែលជាម៉ោង៣ទាបភ្លឺ វៀតណាមបានលួចឆ្មក់ចូលមកខាងទឹកដីខ្មែរ ហើយគប់គ្រាប់បែកដាក់ទីតាំងឈរជើងរបស់អង្គភាពខ្ញុំ។ ពេលនោះខ្ញុំកំពុងសម្រាកនៅក្នុងរណ្តៅលេណដ្ឋានទើបធ្វើឱ្យខ្ញុំត្រូវរបួសខ្លាំងមួយកំណាត់ខ្លួនខាងក្រោម។ ភ្លាមៗនោះកងកម្លាំងខ្ញុំក៏បានមកសែងខ្ញុំចេញពីថ្លុកឈាមទៅឱ្យផុតពីសមរភូមិ។ ស្ថានភាពខ្ញុំពេលនោះធ្ងន់ធ្ងរណាស់។ ខ្ញុំបានសន្លប់ភ្លាមៗបន្ទាប់ពីរងរបួសដោយសារគ្រាប់បែក។ ខ្ញុំមិននឹកស្មានថា ខ្លួនឯងមានជីវិតរស់នៅទេ។ ខ្ញុំអាចរួចផុតជីវិតមកដល់បច្ចុប្បន្ននេះ។ ពេលធ្វើដំណើរទៅដល់មន្ទីរពេទ្យ ខ្ញុំឃើញមានអ្នករបួសច្រើនណាស់ដែលដាច់ជើង និងដាច់ដៃ។ ខ្ញុំក៏បានសម្រាកព្យាបាលនៅមន្ទីរពេលអស់រយៈពេល២-៣ខែ ទើបបានជាសះស្បើយ។ ពេទ្យខ្មែរក្រហមល្អៗណាស់ ដោយបានជួយមើលថែជនពិការ និងអ្នកជំងឺផ្សេងៗយ៉ាងដិតដល់។ អ្នកជំងឺទទួលបានបាយទឹក និងម្ហូបចំណីយ៉ាងគ្រប់គ្រាន់។

បច្ចុប្បន្ននេះ ខ្ញុំមិនមានការអាក់អន់ចិត្តអ្វីនោះទេចំពោះការតស៊ូរបស់ខ្ញុំនៅជំនាន់សង្គ្រាម ដែលធ្វើឱ្យខ្ញុំធ្លាក់ខ្លួនពិការភាព។ ផ្ទុយទៅវិញ ខ្ញុំពិតជាមានមោទកភាពលើខ្លួនឯង ដែលមានជីវិតរស់នៅ មានគ្រួសារកូនចៅនាពេញបច្ចុប្បន្ននេះ។ ម្យ៉ាងវិញទៀតទោះបីជាខ្ញុំពិការភាព ប៉ុន្តែខ្ញុំបានទទួលការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលផ្តល់ជាប្រាក់បៀវត្សរ៍ប្រចាំខែឱ្យខ្ញុំសម្រាប់ជួយផ្គត់ផ្គង់ និងប្រើប្រាស់ប្រចាំថ្ងៃនៅក្នុងជីវភាពគ្រួសារបានយ៉ាងល្អ»។



កងទ័ពបដិវត្តន៍ខ្មែរក្រហមប្រយុទ្ធនៅសមរភូមិ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ព្រះពុទ្ធសាសនាសម្ភារនិយមបដិច្ចសមុប្បាទរបស់កុម្មុយនីស្តខ្មែរក្រហម

ព្រាំ ផល្លា



*ព្រះសង្ឃគង់នៅក្បែរព្រះពុទ្ធបដិមាបែកបាក់ៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*ព្រះពុទ្ធសាសនាគឺជាសាសនាធំមួយនៅប្រទេសកម្ពុជា ដែលអាចមានវត្តមាននៅក្នុងរជ្ជកាល ហ្វូណន នៅរវាងសតវត្សរ៍ទី៥ និងទី៦នៃគ្រិស្តសករាជ។ មានសេចក្តីសន្និដ្ឋានមួយបានរកឃើញថា ចំនួនអ្នកកាន់ព្រះពុទ្ធសាសនាមានរហូតដល់៩៥% នៅឆ្នាំ១៧០០។ ឥទ្ធិពលនេះនៅតែបន្តមានជាបន្តបន្ទាប់ ប៉ុន្តែបានថមថយបន្តិចវិញនៅរវាងសតវត្សរ៍ទី៧ ដល់ទី៨ និងទី១០ដល់១១។ ព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តម សីហនុ បានគ្រប់គ្រងប្រទេសដែលមានការគោរពព្រះពុទ្ធសាសនា ដែលត្រូវបានគិតថាដូចគ្នាទៅនឹងព្រះបាទជ័យវរ្ម័នទី៧ ដែលធ្វើឱ្យព្រះពុទ្ធសាសនារីកចម្រើនឡើងវិញនៅរវាងឆ្នាំ ១៩៥៣ ដល់ ១៩៧០។*

*អ្វីៗត្រូវបានប្រែប្រួលជាខ្លាំងដោយសារតែឥទ្ធិពលនៃជម្លោះរបស់ប្រទេសមហាអំណាចដែលធ្វើឱ្យប្រទេសកម្ពុជាធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិលនៅ*

រវាងឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥។ ខ្មែរក្រហមជាអ្នកឈ្នះសង្គ្រាមស៊ីវិលនេះ និងបានបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលបានគ្រប់គ្រងប្រទេសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យនៅជំពូកទី១៥ ត្រង់មាត្រា២០ បានចែងថា៖

***ប្រជាជនកម្ពុជាគ្រប់រូប មានសិទ្ធិជឿជំនឿ ឬសាសនាណាក៏បាន ហើយក៏មានសិទ្ធិ មិនមានជំនឿអ្វី ឬក៏មិនជឿសាសនាណាក៏បាន។ មិនអនុញ្ញាតឱ្យមានសាសនាប្រតិកិរិយា ដែលបំផ្លិចបំផ្លាញកម្ពុជាប្រជាធិបតេយ្យ និងប្រជាជនកម្ពុជា ដាច់ខាត ។***

ការដឹងឮជាទូទៅ គឺព្រះពុទ្ធសាសនាត្រូវបានហាមឃាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារព្រះសង្ឃត្រូវបានបណ្តេញចេញពីវត្ត បង្ខំឱ្យសឹកទៅចូលរួមការងារកសិកម្មដូចប្រជាជនទូទៅ ហើយព្រះសង្ឃដែលជំទាស់នឹងបទបញ្ជាត្រូវបានសម្លាប់ជាដើម។ ទោះបីជាមានការរឹតត្បិតយ៉ាងតឹងរ៉ឹងយ៉ាងណាក៏ដោយក៏ការគោរពប្រតិបត្តិសាសនានេះនៅតែមានក្នុងដួងចិត្តរបស់ប្រជាជន។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការធ្វើទុក្ខបុកម្នេញលើសាសនាព្រះពុទ្ធដែលជាបទល្មើសមួយនៅក្នុងចំណោមបទល្មើសជាច្រើនទៀត ដែលត្រូវបានតុលាការខ្មែរក្រហមកាត់ទោសមេដឹកនាំខ្មែរក្រហមអស់មួយជីវិត។

នួន ជា ដែលត្រូវបានចាត់ទុកថា មេដឹកនាំមានអំណាចទីពីរបន្ទាប់ពី ប៉ុល ពត បានបដិសេធថា របបរបស់ខ្លួនមិនមានចេតនាអាក្រក់ណាមួយ ដើម្បីបំបាត់ព្រះពុទ្ធសាសនានោះទេ។ នួន ជា បានយោងទៅលើរដ្ឋធម្មនុញ្ញខាងលើ។ គាត់បន្តប្រាប់ថា ការបង្ខំព្រះសង្ឃឱ្យសឹកធ្វើស្រែ ដាក់ទណ្ឌកម្ម ឬសម្លាប់អ្នកលួចគោរពសាសនា នោះគឺជារឿងប្រឌិត។ មេដឹកនាំខ្មែរក្រហមគិតរឿងប្រទេសជាតិជាធំ ឯសាសនា គឺវិវត្តទៅតាមចរន្តរបស់សង្គម ព្រោះប្រជាជនទាំងអស់គ្នាទៅធ្វើការក្នុងសហករណ៍ ហើយគ្មានអ្នកណាមានពេលមកដាក់បាត ចំណែកឯព្រះសង្ឃមិនអាចមានស្បង់ចីពរនោះទេ។ ដូចនេះចរន្តសង្គមអូសទាញទាំងអស់មិនមែនរបបខ្មែរក្រហមហាមទេ។ គាត់នៅតែបន្តលើកឡើងថា នៅឆ្នាំ១៩៧៥ ទៅ ១៩៧៩ ខ្លួនគាត់ផ្ទាល់ក៏មានបន់ស្រន់អុជធូបដែរ កុំជឿថាអ្នកណាមិនបន់ស្រន់នោះ។ តាមពិតនៅពេញអំឡុងពេលកម្ពុជាប្រជាធិបតេយ្យម្តាយរបស់ នួន ជា រស់នៅខេត្តបាត់ដំបងបានទៅវត្តគរជាធម្មតា ព្រោះមានលោកសង្ឃពីរអង្គគង់នៅវត្តនេះ។ ជាបន្តបន្ទាប់មកគ្មានប្រជាជនណាទៅបួសទេ ព្រោះគ្រប់គ្នាត្រូវទៅរស់នៅសហករណ៍ ដូចនេះព្រះសង្ឃត្រូវតែសឹកមកយកប្រពន្ធវិញ។ ឯវត្តក៏ត្រូវបានយកធ្វើជាឃ្លាំងដាក់អំបិលជាដើម ដែលជារឿងត្រឹមត្រូវព្រោះនៅទំនេរ។

នួនជា បានទទួលស្គាល់ថា ព្រះពុទ្ធសាសនាគឺជាជំនួយមួយដល់ជីវិតតស៊ូរបស់គាត់។ គាត់យល់ថា ទ្រឹស្តីកុម្មុយនីស្តមិនស្រី មិនស្រា វាមិនអាចធ្វើទៅបានមួយរយភាគរយទេ ប៉ុន្តែគាត់ស្រឡាញ់គំនិតនេះ ព្រោះវាស្របនឹងព្រះពុទ្ធសាសនា។ ដូចនេះ គាត់យកសាសនា និងទ្រឹស្តីកុម្មុយនីស្តមកប្រៀបធៀបគ្នា គឺម្យ៉ាងម្នាក់ដូចគ្នា។

ព្រះពុទ្ធសាសនាយកគុណធម៌ ប៉ុន្តែគុណធម៌របស់ជនកុម្មុយនីស្ត របស់អ្នកបដិវត្តន៍វាខុសពីគុណធម៌ព្រះពុទ្ធសាសនាដែលសម្ញុំសុខ។ ព្រះពុទ្ធសាសនាគិតរឿងមេត្តាករុណា ប៉ុន្តែកុម្មុយនីស្តមានមេត្តាករុណាចំពោះប្រជាជនក្រីក្រ។ ព្រះពុទ្ធសាសនា និងកុម្មុយនីស្តខុសគ្នាត្រង់ព្រះពុទ្ធសាសនាអត់ប្រើហិង្សា តែកុម្មុយនីស្តប្រកាន់ជំហរ ប្រសិនបើគេកម្ទេចយើង យើងកម្ទេចគេ តែព្រះពុទ្ធសាសនាគិតរឿងមេត្តាករុណារហូត បើទោះជាសត្រូវក៏ដោយ។ ប៉ុន្តែកុម្មុយ-នីស្តក៏ចេះមេត្តាករុណានៅក្នុងបក្សដែរ ដូចជា យកមកអប់រំម្តងហើយម្តងទៀត ប្រសិនបើមិនកែប្រែ គឺត្រូវដោះស្រាយតាមវិធីជួនណាតាមកម្ទេច ជួនណាតាមការដាក់គុក។ ការដោះស្រាយមានតាមសតិអារម្មណ៍តែប្រសិនបើនៅតែមិនស្តាប់ នោះឈានទៅ

ដល់ការដោះស្រាយខ្ពស់គឺ "កម្ទេច" មានន័យថា "សម្លាប់"។ កម្ទេចក៏បានន័យថា កម្ទេចឱ្យអស់ធាតុវណ្ណៈ គំនិតទ្រឹស្តី មិនមែនចេះតែសម្លាប់ទេ។ ដូចជាបោសសម្អាតមានន័យថា បោសសម្អាតសតិអារម្មណ៍ដែលពុករលួយដែលស៊ីសំណូកសូកប៉ាន់ បើបោសសម្អាតហើយ នៅតែមិនកែប្រែទៀត គឺចាប់ដាក់គុកបញ្ជូនឱ្យយោធា ហើយបក្សគ្មានសិទ្ធិសម្លាប់នោះទេ។ អំណាចខ្ពស់បំផុតគឺមហាសន្និបាតបក្សទូទាំងប្រទេស។ នួន ជា និយាយថា មហាសន្និបាតតំណាងបក្សទូទាំងប្រទេសជាអង្គការកំពូល ដែលកំណត់មាគ៌ានយោបាយបក្សដោយប្រជុំ៥ឆ្នាំម្តង និងតែងតាំងសមាជិកគណៈមជ្ឈិម។ គាត់សង្ខេបងាយយល់ដូចនេះអំពីអង្គការពីធំទៅតូច៖ មហាសន្និបាតតំណាងបក្សទូទាំងប្រទេស, មជ្ឈិមបក្សកុម្មុយនីស្ត, គណៈអចិន្ត្រៃយ៍បក្ស (ប្រហែលជាគាត់យោងទៅរកលក្ខន្តិកបក្សទំព័រ៣២)។ ការសង្ខេបនេះគឺវាផ្ទុយទៅនឹងការរកឃើញរបស់អ្នកវិភាគ និងអ្នកស្រាវជ្រាវអំពីរបបខ្មែរក្រហម។ សាសនាមិនឱ្យគុំកួនសងសឹក តែកុម្មុយនីស្តគុំកួន ពេលណាដែលមិនកែប្រែ តែបើគេកែប្រែ នោះគេជាមិត្ត។ ព្រះពុទ្ធសាសនា និងកុម្មុយនីស្តដូចគ្នា ត្រង់មិនបុគ្គលនិយម ។

នួន ជា បានលើកឡើងបន្តទៀតថា ជីវិតរបស់គាត់ដែលជោគជ័យគឺការអនុវត្តតាមសីលប្រាំរបស់អ្នកកាន់សាសនាព្រះពុទ្ធ គឺ ១) កុំសម្លាប់សត្វ ឬប្រមាថជីវិតគេ, ២) ការមិនប្រណែនឈ្នានីសអ្នកដទៃ ឬមិនលួចរបស់ទ្រព្យគេ, ៣) មិននិយាយកុហក, ៤) មិនក្រេបគ្រឿងស្រវឹង, ៥) មិនប្រព្រឹត្តខុសផ្លូវលោក ដូចជាការលួចប្រពន្ធគេ។ ជនកុម្មុយនីស្ត គឺត្រូវគិតរួមដើម្បីសមូហភាពមិនបុគ្គលនិយម គិតជាតិជារួម ហើយគិតបុគ្គលជាក្រោយ។ នួន ជា បានអះអាងថា ជនកុម្មុយនីស្តក៏មានមនោសញ្ចេតនាជាមួយគ្រួសារដែរ ហើយគាត់មានមនោសញ្ចេតនាខ្លាំងណាស់ ក៏ប៉ុន្តែភារកិច្ចមិនអនុញ្ញាតឱ្យគាត់ធ្វើតាមចិត្ត ដោយសារតែវិន័យជនកុម្មុយនីស្ត ប្រសិនបើរវល់តែគិតរឿងគ្រួសារផលប្រយោជន៍ផ្ទាល់ខ្លួន នោះដឹកនាំការងារមិនបាន ហើយក៏មិនអាចធ្វើជាគំរូគេដែរ។

នួន ជា បានលើកឡើងបន្ថែមទៀតពីកត្តាបីដែលគាត់គិតថា ធ្វើឱ្យជីវិតនយោបាយរបស់គាត់រីកចម្រើន គឺ ជាតិ បក្ស និង សាសនា។ គាត់បញ្ជាក់ថា គាត់យកទ្រឹស្តីម៉ាក-ឡេនីនរួមផ្សំជាមួយព្រះពុទ្ធសាសនាសម្ភារនិយមបដិច្ចសមុប្បាទមកអនុវត្ត។ ការលើកឡើងរបស់ នួន ជា គឺត្រូវគ្នាទៅនឹងលក្ខន្តិកបក្សកុម្មុយនីស្តកម្ពុជា។

ឯកសាររបស់ខ្មែរក្រហមអំពីកសាង និងពង្រឹងបក្សខាងទស្សនៈ ម៉ាក្ស-ឡេនីន មួយចំនួន បានពន្យល់យ៉ាងលម្អិតអំពីទ្រឹស្តី និងឧទាហរណ៍ជាក់ស្តែងនៅក្នុងសង្គមនៃការអនុវត្តគោលគំនិត "សម្ភារនិយមបដិច្ចសមុប្បាទ"។ ជាសង្ខេបសម្ភារនិយមបដិច្ចសមុប្បាទមានក្រឹត្យក្រម៤គឺ ១) អ្វីទាំងអស់សុទ្ធតែមានការទាក់ទងគ្នាជានិច្ច មិននៅតែឯងទេ។ ២) អ្វីទាំងអស់សុទ្ធតែប្រែប្រួលជានិច្ច មិននៅនឹងថ្កល់ទេ។ ៣) អ្វីទាំងអស់ដែលវិវត្ត គឺពីទាបទៅខ្ពស់ ពីតូចទៅធំ ពីបរិមាណទៅគុណភាព។ ៤) អ្វីទាំងអស់សុទ្ធតែមានទំនាស់។ ក្រិតក្រមទាំងបួននេះ គឺជាខ្លឹមសារជាមូលដ្ឋាននៃសម្ភារនិយមបដិច្ចសមុប្បាទក្នុងការវិភាគ ក៏ដូចជាការលើកវិធានការការងារដោយត្រូវមានជំហរក្រឹត្យក្រមទាំង៤នេះឱ្យបានរឹងប៉ឹង មានណាមួយខ្វះណាមួយមិនគ្រប់គ្រាន់ទេ។

ការរៀបរាប់ខាងលើបានបង្ហាញពីភាពជិតស្និទ្ធរបស់ នួន ជា និងជនកុម្មុយនីស្តទៅនឹងព្រះពុទ្ធសាសនាដែលត្រូវបានដឹងជាទូទៅថា ត្រូវបានលុបបំបាត់នៅក្នុងរបបដែលគាត់បានចូលរួមគ្រប់គ្រង។ តែនៅដំណាក់កាលចុងក្រោយនៃជីវិត គាត់បានងាកមកអានសៀវភៅធម៌របស់ព្រះពុទ្ធសាសនា។ នៅក្នុងបន្ទប់ឃុំឃាំងរបស់គាត់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានដាក់តាំងរូបថតឪពុកម្តាយរបស់គាត់ដើម្បីអុជធូបគោរពបូជា ដែលមានរូបពុទ្ធ

ជិមា នៅក្បែរនោះដែរ។ នៅគ្រាមួយនៅឆ្នាំ២០១៣ នៅពេលដែលគាត់មានជំងឺរលាកទងសួតធ្ងន់ធ្ងរ ដែលនឹងអាចបាត់បង់ជីវិតនោះ គាត់បានស្នើសុំគ្រួសារឱ្យដាក់រូបភាពព្រះពុទ្ធនៅលើក្បាលដំណេករបស់គាត់។ ជារឿយៗ គាត់បាននិយាយប្រាប់ខ្ញុំថា កុំជឿថា អ្នកតស៊ូមិនគោរពសាសនានោះ ដោយសារតែគាត់តែងតែគោរពខ្ជាប់ខ្ជួននៅពេលប្រយុទ្ធជាមួយសត្រូវ។

បន្ទាប់ពីការដួលរលំនៃរបបប្រល័យពូជសាសន៍ខ្មែរក្រហម ព្រះពុទ្ធសាសនាបានកកើតឡើងវិញ ហើយបានជួយដល់ការផ្សះផ្សាផ្លូវចិត្តរបស់ប្រជាជននៅក្នុងការធ្វើដំណើរកសាងប្រទេស និងការតស៊ូយកមកវិញនូវសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិដែលត្រូវបានបំផ្លាញនៅក្រោមរបបខ្មែរក្រហម។

គំនូរក្នុងបន្ទប់ឃុំឃាំង នួន ជា តាមការចងចាំរបស់លោក ព្រំ ផល្លា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# វេទិកាពិភាក្សាប្រវត្តិសាស្ត្រ ស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង

ថុន ស្រីពៅ្រ



សិស្សមកពីវិទ្យាល័យចម្រើនវិជ្ជាចូលរួមវេទិកាពិភាក្សាស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅថ្ងៃទី១៦ខែកុម្ភៈ ឆ្នាំ២០២៥ សិស្សានុសិស្សថ្នាក់ទី១១ ចំនួន៣នាក់ មកពីវិទ្យាល័យចម្រើនវិជ្ជា បានមកចូលរួមវេទិកាពិភាក្សាប្រវត្តិសាស្ត្រ ស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ មុនឈានទៅដល់ការពិភាក្សាអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម បុគ្គលិកប្រចាំមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានណែនាំផ្ទាំងពិព័រណ៌អចិន្ត្រៃយ៍ ពីប្រវត្តិ និង ឈ្មោះមេដឹកនាំខ្មែរក្រហម, ការបង្ខំការផ្តួលរលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ របស់សម្តេចតេជោ ហ៊ុនសែន, កិច្ចប្រជុំពិសេសនិមិត្តរូបរវាងឪពុក និងកូនក្នុងដំណើរដែលសម្រេចបានសន្តិភាពពេញលេញនៅកម្ពុជា, ការបញ្ចប់សង្គ្រាមដោយសារការអនុវត្តនយោបាយ ឈ្នះៗ, ការងាររមនុស្សធម៌ និងសង្គ្រោះ, ការរស់ឡើងវិញរបស់ប្រជាជនខ្មែរ និងការរស់ឡើងវិញនូវសិល្បៈវប្បធម៌ ព្រមទាំងបង្កើតឱ្យមានមជ្ឈមណ្ឌលកុលាបសម្រាប់កុមារកម្ពុជាដែលគ្មានទីជម្រក និងកំព្រា

ឪពុកម្តាយពីរបបខ្មែរក្រហម។

បន្ទាប់ពីបានទស្សនាផ្ទាំងពិព័រណ៍អចិន្ត្រៃយ៍រួច សិស្សានុសិស្សអាចឡើងទៅបន្ទប់រៀន ដើម្បីពិភាក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមបន្ថែមទៀត។ ជាដំបូងបុគ្គលិកឈ្មោះ ដារ៉ារដ្ឋ មេត្តា បានឱ្យសិស្សធ្វើការណែនាំខ្លួនជាមុន។ បន្ទាប់មក មេត្តា សួរនាំទៅកាន់សិស្សានុសិស្សវិញថា តើប្អូនៗចង់ដឹងអ្វីខ្លះពីប្រវត្តិសាស្ត្រខ្មែរក្រហម? សិស្សឈ្មោះ ចាន់ សូរិយា បាននិយាយថា៖ «ខ្ញុំចង់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមឱ្យបានច្បាស់ជាងមុន»។ ក្រោយមក សិស្សឈ្មោះ ហៃ តុ បាននិយាយថា៖ «ខ្ញុំចង់ដឹងពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងសម័យខ្មែរក្រហមឱ្យកាន់តែច្បាស់បន្ថែមទៀត ព្រោះមានការពិភាក្សា ខុសប្លែកពីគ្នាថា របបខ្មែរក្រហមបែបនេះ ឬបែបនោះជាដើម។ ខ្ញុំចង់ដឹងថា តើអ្វីដែលគាត់បាននិយាយថា របបខ្មែរក្រហមជារបបដែលឃោរឃៅ គឺជារឿងពិតឬយ៉ាងណា?» សិស្សឈ្មោះ ហឿន ស្រីរ៉ា បាននិយាយបន្តថា៖ «ខ្ញុំចង់ដឹងពីជីវិតប្រជាជនកម្ពុជាដែលរស់នៅក្នុងសម័យខ្មែរក្រហម បានជួបនូវរឿងរ៉ាវអ្វីខ្លះ? តើខ្មែរក្រហមបានធ្វើអ្វីខ្លះមកលើប្រជាជនកម្ពុជាយើង?»

ជាកិច្ចបន្ត សិស្សានុសិស្សត្រូវបំពេញកម្រងសំណួរមុនវេទិកាពិភាក្សាជាមុនសិន ដើម្បីស្ទាបស្ទង់កម្រិតចំណេះដឹងសិស្ស មុនពេលចូលដល់ការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ សិស្សានុសិស្សមានពេលវេលាចំនួន១០នាទី ក្នុងការបំពេញនូវកម្រងសំណួរ។ បន្ទាប់ពីប្រមូលកម្រងសំណួរមុនវេទិការួច មេត្តា បានបែងចែកសិស្សានុសិស្សឡើងអានមេរៀនក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) ជំពូកទី២ ដើម្បីឱ្យសិស្សានុសិស្សបានដឹងថា តាមរយៈការអានផ្ទាល់ និងចែករំលែកគ្នាពីអ្វីដែលបានអាន និងស្តាប់ តើខ្មែរក្រហមជានរណា? តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា? បន្ទាប់ពីនោះ មេត្តា គឺជាអ្នកសម្របសម្រួលក្នុងកិច្ចពិភាក្សា បានពន្យល់មេរៀននៅក្នុងជំពូកទី២ ឆ្លើយតបទៅនឹងចំណងជើង៖ តើខ្មែរក្រហមជានរណា? តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា? មុននឹងចូលដល់ការធ្វើបទបង្ហាញខាងលើ មេត្តា បានសួរសំណួរទៅកាន់សិស្សានុសិស្សវិញថា តើចំណុចដែលប្អូនៗបានអាន បានឆ្លើយតបទៅនឹងសំណួរខាងលើដែរឬទេ? សិស្សានុសិស្សឆ្លើយថា«ឆ្លើយតប»។ មេត្តា សួរសំណួរបន្តទៀតថា នៅក្នុងជំពូកដែលប្អូនៗបានអាន តើមាននិយាយពីឈ្មោះមេដឹកនាំរូបណាខ្លះ? សិស្សម្នាក់ៗក៏បានឆ្លើយថា មានមេដឹកនាំដូចជាឈ្មោះ សុន សេន, អៀង សារី, ខៀវ សំផន, នួន ជា និង ប៉ុល ពត។ មេត្តា ចាប់ផ្តើមពន្យល់ពីឈ្មោះមេដឹកនាំម្នាក់ៗ ដែលទទួលឥទ្ធិពលកុម្មុយនីស្តពីក្រៅប្រទេស។ បន្ទាប់មក មេត្តា បានពន្យល់សិស្សចាប់ពីរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០, សង្គ្រាមកើតមានឡើង មានការទម្លាក់គ្រាប់បែកដែលបានសម្លាប់មនុស្សអស់ប្រមាណជា៣សែននាក់, ប្រជាជនខឹងស្អប់ចំពោះរបប លន់ នល់ ហើយបានចូលរួមជាមួយខ្មែរក្រហមយ៉ាងច្រើនលើសលប់ក្នុងការផ្តួលរំលំរបប លន់ នល់ វិញ។ បន្ទាប់ពីអ្នកសម្របសម្រួលធ្វើបទបង្ហាញរួច សិស្សានុសិស្សចាប់ផ្តើមសួរសំណួរថា៖ ១) តើសម្តេចព្រះនរោត្តម សីហនុ បានចូលដៃជាមួយខ្មែរក្រហមពិតមែនឬទេ បន្ទាប់ពីទ្រង់ត្រូវបានសេនាប្រមុខ លន់ នល់ ធ្វើរដ្ឋប្រហារ? ២) តើការរត់ចូលព្រៃម៉ាគីនេះ គឺជាការចូលរួមជាមួយក្រុមខ្មែរក្រហមឬយ៉ាងណា? ៣) តើ លន់ នល់ បានទម្លាក់គ្រាប់បែកនៅក្នុងប្រទេសកម្ពុជាដើម្បីអ្វី? ៤) តើហេតុអ្វីបានជា លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ?

ចុងបញ្ចប់នៃវេទិកាពិភាក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម អ្នកសម្របសម្រួល ក៏មិនភ្លេចបង្ហាញពីនិយមន័យនៃអំពើប្រល័យពូជសាសន៍ និងវិធីសាស្ត្រមួយចំនួនក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍៖ «អំពើប្រល័យពូជសាសន៍ គឺជាអំពើទាំងឡាយណា

ដែលធ្វើឡើងនៅក្នុងគោលបំណងបំផ្លិចបំផ្លាញចោលទាំងស្រុង ឬដោយផ្នែកចំពោះក្រុមជនជាតិ ជាតិពន្ធុ ពូជសាសន៍ឬក្រុមសាសនា»។ ក្នុងនិយមន័យនេះ អ្នកសម្របសម្រួលបានលើកឧទាហរណ៍ ពីប្រទេសដែលមានអំពើប្រល័យពូជសាសន៍ មានដូចជាប្រទេសរវ៉ាន់ដា និង ប្រទេសអាល្លឺម៉ង់ ដែលមានអំពើប្រល័យពូជសាសន៍ សម្លាប់មនុស្ស កើតចេញពីការរើសអើងពូជសាសន៍។ វិធីសាស្ត្រមួយចំនួនក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ គឺ យើងម្នាក់ៗ ត្រូវបដិសេធចំពោះអំពើហិង្សា លើកទឹកចិត្តឱ្យមានដំណោះស្រាយដោយសន្តិវិធីចំពោះជម្លោះ និងនិយាយប្រឆាំងចំពោះអំពើហិង្សា, ការពារសិទ្ធិជាបុគ្គល ដោយមិនគិតពីពណ៌សម្បុរ និន្នាការនយោបាយ, ការអប់រំ, ទំនាក់ទំនងការទូត និងនិយាយទិតៀនជាសាធារណៈពីកាលៈទេសៈដែលនាំឱ្យកើតមានការគាំទ្រអំពើប្រល័យពូជសាសន៍។ ភ្លាមៗនោះ សិស្សានុសិស្ស បានសួរសំណួរថា តើហេតុអ្វីបានជានិយមន័យនៃអំពើប្រល័យពូជសាសន៍ គឺសង្កត់លើន័យបំផ្លាញចោលទាំងស្រុងទៅវិញ? តើគោលបំណងរបស់មេដឹកនាំ គឺចង់បំផ្លាញប្រជាជនយ៉ាងដូចម្តេច? អ្នកសម្របសម្រួល បានលើកឧទាហរណ៍ លើករណីជនជាតិចាម និង ជនជាតិវៀតណាម ត្រូវបានខ្មែរក្រហមសម្លាប់ និងធ្វើទុកបុកម្នេញទៅលើសាសនា ដោយមិនឱ្យជនជាតិចាមគោរពប្រណិប័តន៍ទៅលើសាសនា និងបង្ខំឱ្យជនជាតិចាមហូបសាច់ជ្រូក។ កិច្ចការសិស្សានុសិស្សចុងក្រោយ គឺត្រូវបំពេញកម្រងសំណួរស្ទាបស្ទង់ចំណេះដឹងក្រោយវេទិកាពិភាក្សា រយៈពេល២០នាទី ដើម្បីចង់ដឹងពីចំណេះដឹងសិស្ស មានការកើនចំណេះដឹងឡើងឬយ៉ាងណា មុនពេលត្រឡប់ទៅផ្ទះវិញ។

***ខាងក្រោមនេះជាចំណាប់អារម្មណ៍របស់សិស្សានុសិស្សពីវេទិកាពិភាក្សា៖***

ខ្ញុំឈ្មោះ **វ៉ៃហ ស្រីតុ** ភេទស្រី អាយុ១៥ឆ្នាំ រៀននៅថ្នាក់ទី១១ នៃវិទ្យាល័យចម្រើនវិជ្ជា។ បន្ទាប់ពីខ្ញុំបានសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរួចមក ខ្ញុំបានស្គាល់ នូវឈ្មោះមេដឹកនាំនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាដូចជា ទូ សាមុត, ប៉ុល ពត, នួន ជា, ខៀវ សំផន, អៀង សារី, សុន សេន ។ ខ្ញុំបានដឹងពីមូលហេតុដែលខ្មែរក្រហមឡើងកាន់អំណាចក៏ព្រោះលោកសេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ។ បន្ទាប់មករបប លន់ នល់ បានធ្វើការទម្លាក់គ្រាប់បែកនៅក្នុងប្រទេសកម្ពុជា ធ្វើឱ្យប្រជាជនមានការខឹងស្អប់ចំពោះ លន់ នល់ និងបានចូលរួមជាមួយចលនាខ្មែរក្រហម ក្នុងការផ្តួលរំលំរបប លន់ នល់ វិញ។

ខ្ញុំឈ្មោះ **ចាន់ សូរិយា** ភេទស្រី អាយុ១៦ឆ្នាំ រៀននៅថ្នាក់ទី១១នៃវិទ្យាល័យចម្រើនវិជ្ជា។ ចំពោះចំណុចថ្មីដែលខ្ញុំរៀនសូត្របាន គឺដឹងពីដើមកំណើតរបស់ខ្មែរក្រហម។ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង គឺជាទីតាំងដែលបានឆ្លើយតបទៅនឹងអ្វីដែលខ្ញុំបានឆ្ងល់ពីមុនមក។ ខ្ញុំទទួលបានបទពិសោធន៍ថ្មីៗ ទាក់ទងនឹងការរៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ នៅពេលដែលខ្ញុំអានមេរៀនដង ហើយខ្ញុំបានសង្ខេបដង កាន់តែធ្វើឱ្យខ្ញុំចាប់បានច្រើន និងយល់កាន់តែច្រើនទៀត។

ខ្ញុំឈ្មោះ **ហឿន ស្រីរ៉ា** ភេទស្រី អាយុ១៦ឆ្នាំ រៀនថ្នាក់ទី១១ នៃវិទ្យាល័យចម្រើនវិជ្ជា។ ចំពោះចំណេះដឹងដែលខ្ញុំទទួលបាននៅក្នុងថ្ងៃនេះ គឺខ្ញុំបានដឹងពីនិយមន័យនៃអំពើប្រល័យពូជសាសន៍, បានដឹងថារបបខ្មែរក្រហម បានសម្លាប់មនុស្ស, បានដឹងពីប្រវត្តិរបស់ ប៉ុល ពត ព្រមទាំងមូលហេតុដែល ប៉ុល ពត អាចឡើងកាន់អំណាច។ ពីមុនមក ខ្ញុំធ្លាប់គិតថា ប៉ុល ពត គាត់ជាមនុស្សដែលឃោរឃៅម្នាក់។ ប៉ុន្តែធាតុពិត តាំងពីដំបូងមក គឺគាត់មិនមែនជាមនុស្សដែលអាក្រក់ទេ។ គាត់ទើបតែផ្លាស់ប្តូរនៅពេលដែលគាត់បានឡើងកាន់អំណាចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទើបធ្វើឱ្យមានអំពើប្រល័យពូជសាសន៍កើតឡើង។

# ប្រវត្តិសាស្ត្រ និងសារសំខាន់នៃការសិក្សាពី ប្រវត្តិសាស្ត្រខ្មែរក្រហម

ផេង ពង្សរ៉ាស៊ី





និស្សិតចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីចុងខែតុលា ឆ្នាំ២០២៤ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលសំណើរពីសាស្ត្រាចារ្យបង្រៀននៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ស្ថិតនៅក្នុងរាជធានីភ្នំពេញ ស្នើសុំឱ្យអ្នកជំនាញខាងប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើបទបង្ហាញពីមាតិកាប្រវត្តិសាស្ត្រខ្មែរក្រហម ជាមួយនិស្សិតឆ្នាំទី៤ដែលគាត់កំពុងបង្រៀនសព្វថ្ងៃ។ អ្នកស្រីសាស្ត្រាចារ្យ បានលើកឡើងថា និស្សិតភាគច្រើនដែលកំពុងសិក្សាជាមួយគាត់លើមុខវិជ្ជា «វិទ្យាសាស្ត្រស្រាវជ្រាវ» មិនមានចំណេះដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមច្រើនឡើយ។ នៅដើមខែវិច្ឆិកាឆ្នាំដដែល មជ្ឈមណ្ឌលឯកសារកម្ពុជា បានបញ្ជូនខ្ញុំឱ្យទទួលបន្ទុកកិច្ចការនេះ។ ខ្ញុំបានធ្វើដំណើរទៅកាន់ថ្នាក់រៀនរបស់អ្នកស្រីសាស្ត្រាចារ្យ ដើម្បីផ្តល់នូវការធ្វើបទបង្ហាញពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំត្រូវបានទទួលស្វាគមន៍ពីអ្នកស្រីសាស្ត្រាចារ្យ និងនិស្សិតនៅក្នុងថ្នាក់ទាំងអស់។ បន្ទាប់ពីអ្នកស្រីសាស្ត្រាចារ្យបានណែនាំនិស្សិតឱ្យស្គាល់ខ្ញុំរួចមក អ្នកស្រីបានស្នើសុំឱ្យខ្ញុំពន្យល់បន្ថែមពីអត្ថន័យនៃពាក្យ «ប្រវត្តិសាស្ត្រ» និង «មូលហេតុចាំបាច់មួយចំនួនដែលត្រូវសិក្សាពីប្រវត្តិសាស្ត្រ»។

ខ្ញុំបានចាប់ផ្តើមការបង្រៀនរបស់ខ្ញុំ។ ដំបូង ខ្ញុំបានសួរសំណួរសាមញ្ញចំនួនពីរទៅកាន់និស្សិត ដើម្បីវាស់ស្ទង់ពីសមត្ថភាពចំណេះដឹងរបស់អ្នកទាំងនោះពីប្រវត្តិសាស្ត្រខ្មែរក្រហម។ សំណួរទីមួយរបស់ខ្ញុំគឺ «តើរបបខ្មែរក្រហមគ្រប់គ្រងប្រទេសនៅថ្ងៃខែឆ្នាំណា ហើយដួលរលំទៅវិញនៅថ្ងៃខែឆ្នាំណា?» ហើយសំណួរទីពីរ «តើមានប្រជាជនស្លាប់ប៉ុន្មាននាក់ក្នុងរបបខ្មែរក្រហម?» សំណួរសាមញ្ញទាំងពីរនេះ មិនបានផ្តល់ភាពងាយស្រួលដល់និស្សិតក្នុងការឆ្លើយតបវិញឡើយ។ និស្សិតពីរនាក់បានងើបឡើង ហើយឆ្លើយទៅនឹងសំណួរ។ ចម្លើយរបស់អ្នកទាំងពីរ គឺត្រូវបានតែពាក់កណ្តាលប៉ុណ្ណោះ។

តាមរយៈការវាស់ស្ទង់ចំណេះដឹងនេះ និងការស្នើសុំរបស់អ្នកស្រីសាស្ត្រាចារ្យ ខ្ញុំបានដឹងពីចំណេះដឹងពិតប្រាកដរបស់និស្សិតទាំងនោះ។ ខ្ញុំបានចោទសួរខ្លួនឯងថា ហេតុអ្វីក្មេងៗទាំងនោះ មានចំណេះដឹងផ្នែកប្រវត្តិសាស្ត្រខ្លួនឯងតិចយ៉ាងនេះ? ឬមួយក៏អ្នកទាំងនោះគិតថា ការសិក្សាពីប្រវត្តិ-សាស្ត្រ គឺមិនបានផ្តល់នូវសារសំខាន់សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ខ្លួនទេ? តើការសិក្សាពីមុខវិជ្ជាប្រវត្តិសាស្ត្រនៅតាមសាលារៀនក្នុងកម្រិតវិទ្យា-ល័យ គ្រាន់តែជាការសិក្សាបង្គ្រប់ម៉ោងនៅក្នុងកាលវិភាគសិក្សា ឬយ៉ាងណា? ឬមួយគ្រូបង្រៀនមិនបានបង្ហាញពីវត្ថុបំណងច្បាស់លាស់ ក្នុងការបង្រៀនម៉ោងប្រវត្តិសាស្ត្រទេ បានជាសិស្សមិនដឹងគោលដៅនៃការសិក្សារបស់ខ្លួន? ឬមួយថាក្រសួងអប់រំ យុវជន និងកីឡា ផ្តល់ម៉ោងសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ តិចពេក? សំណួរទាំងនេះ មិនមែនជាការដាក់បន្ទុកទៅលើសិស្ស គ្រូបង្រៀន និងក្រសួងអប់រំឡើយ ហើយវាក៏មិនមែនជាកំហុសរបស់អ្នកទាំងនោះដែរ។ ប៉ុន្តែសំណួរទាំងនេះ បានផ្តល់នូវការត្រិះរិះពិចារណាស៊ីជម្រៅមួយ ដើម្បីធ្វើយ៉ាងណាឱ្យការសិក្សាមុខវិជ្ជាប្រវត្តិសាស្ត្រមានភាពរីកចម្រើនទៅមុខ និងមានតម្លៃសម្រាប់ជាតិទាំងមូល។

តាមរយៈការសំយោគពីអ្វីដែលជាការស្នើសុំរបស់អ្នកស្រីសាស្ត្រាចារ្យ និងការវាស់ស្ទង់របស់ខ្ញុំចំពោះនិស្សិតដែលខ្ញុំបានជួប មានសេចក្តីសន្និដ្ឋានរួមមួយ ក្នុងចំណោមសេចក្តីសន្និដ្ឋានជាច្រើនដែលនាំឱ្យក្មេងៗជំនាន់ក្រោយមួយចំនួនមិនឱ្យតម្លៃលើការសិក្សាមុខវិជ្ជាប្រវត្តិសាស្ត្រ។ នោះគឺដោយសារអ្នកទាំងនោះពុំបានគិតគូរស៊ីជម្រៅ ឬមិនទាន់បានស្វែងយល់ឱ្យបានច្បាស់លាស់ពីអត្ថន័យប្រវត្តិសាស្ត្រ និងឫសគល់នៃការសិក្សាប្រវត្តិសាស្ត្រនៅឡើយ។

សំណេរខ្លីនេះ នឹងឆ្លើយទៅនឹងសំណួរថា «តើហេតុអ្វី យើងត្រូវសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រ?» ការបកស្រាយ ឬការឆ្លើយតបទៅនឹងសំណួរនេះ គឺជាការដកស្រង់ពីសំណេរ ឬសៀវភៅដែលអ្នកនិពន្ធ ឬអ្នកជំនាញប្រវត្តិសាស្ត្របានសរសេរទុករួមផ្សំនឹងការផ្តល់ឧទាហរណ៍ជាក់ស្តែងពីប្រវត្តិសាស្ត្រខ្មែរក្រហមជាអំណះអំណាងផងដែរ។ ការបកស្រាយនេះ ក៏មិនបានក្តោបរាល់វិធីសាស្ត្រទាំងអស់ ដែលផ្តល់ដល់អ្នកអាននូវដំណោះស្រាយក្នុងការសិក្សាប្រវត្តិ-សាស្ត្រដែរ។ ជាដំបូង ខ្ញុំនឹងពន្យល់អត្ថន័យនៃពាក្យ «ប្រវត្តិសាស្ត្រ» ហើយបន្ទាប់មកទៀត ខ្ញុំនឹងបកស្រាយខ្លះៗពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រដែលជាមុខវិជ្ជាមិនអាចខ្វះបានសម្រាប់ក្មេងៗជំនាន់ក្រោយ។

## ប្រវត្តិសាស្ត្រគឺជាអ្វី?

នៅក្នុងវចនានុក្រម សម្តេចព្រះសង្ឃរាជ ជួនណាត ពាក្យ «ប្រវត្តិសាស្ត្រ» ជាពាក្យក្លាយមកពីពាក្យបាលីសំស្រ្កឹត «ប្រវត្តិសាស្ត្រ» មានន័យថា គម្ពីរ ឬក្បួនសម្តែងអំពីពង្សាវតារ ឬសន្តតិវង្ស (វង្សត្រកូល, ពូជពង្ស, ជាតិ)។ ចំណែកវចនានុក្រមភាសាអង់គ្លេស Longman: Dictionary of Contemporary English បានពន្យល់ថា ប្រវត្តិសាស្ត្រ គឺជា



និស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រងចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងពេលអតីតកាល ដូចជា ការអភិវឌ្ឍន៍វិស័យនយោបាយ សង្គម ឬសេដ្ឋកិច្ច របស់ជាតិមួយៗ។ នៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀន បោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា បានដកស្រង់សម្តីរបស់ វិលៀម មិកវែល ជាអ្នកនិពន្ធ និងអ្នកប្រវត្តិសាស្ត្រជនជាតិអាមេរិក ដែលបានសរសេរនៅក្នុងសំណេររបស់គាត់អំពី «អារ្យធម៌នៅបស្ចិមប្រទេស» ទាក់ទងនឹងពាក្យប្រវត្តិសាស្ត្រ មកធ្វើការអធិប្បាយថា ប្រវត្តិសាស្ត្រ ត្រូវបានបែងចែកជាបីកម្រិតគឺកម្រិតបុគ្គល កម្រិតជាតិ និងកម្រិតអន្តរជាតិ។ តាមរយៈការបកស្រាយ និងពន្យល់ខាងលើប្រវត្តិសាស្ត្រ គឺជាការអធិប្បាយពីព្រឹត្តិការណ៍ ឬជាគម្ពីរក្បួនខ្នាតដែលកត់ត្រាពីព្រឹត្តិការណ៍របស់មនុស្សនយោបាយ សង្គម និងសេដ្ឋកិច្ច របស់មនុស្សប្រទេសជាតិ និងសាកលលោក។ ឧទាហរណ៍ ជីវ តាក្វាន់ បានបង្ហាញដល់ពិភពលោកនូវកំណត់ត្រាប្រវត្តិសាស្ត្រប្រទេសកម្ពុជា តាំងពីពេលដែលគាត់មកដល់ប្រទេសកម្ពុជាដំបូងកាលពីជាង៨០០ឆ្នាំមុន ហើយអ្នកប្រាជ្ញដទៃទៀតបានមកសិក្សាពីអរិយធម៌ វប្បធម៌ និងរឿងរ៉ាវនានាដែលបានកើតមាននៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីអង្គទូត ជីវ តាក្វាន់។ ជីវ តាក្វាន់ ដែលជាបេសកជនទូតចិន បានមកដល់ប្រទេសកម្ពុជានៅខែសីហា ឆ្នាំ១២៩៦ ដើម្បីពង្រីកទំនាក់ទំនងជាមួយ «ប្រទេសចេនឡា» ដែលជាប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ។ ក្នុងអំឡុងពេលនៃការស្នាក់ក្នុងប្រទេសកម្ពុជា និងរង់ចាំព្រះរាជានុញ្ញាតពីព្រះបាទស្រីន្ទ្រវម៌្ម ឬព្រះបាទឥន្ទ្រវម៌្មទី៣ឱ្យចូលក្រាបបង្គំគាល់ ជីវ តាក្វាន់ បានដើរទស្សនកិច្ចនៅក្នុងបរិវេណទីក្រុងអង្គរធំ និងបានសរសេរកំណត់ហេតុពិពណ៌នាអំពីរាជធានីអង្គរ ព្រះបរមរាជវាំង ប្រាសាទនានា ប្រពៃណីទំនៀមទម្លាប់របស់អ្នកស្រុក ក្បួនដង្ហែព្រះមហាក្សត្រ ពិធី

សាសនានានា ព្រមទាំងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជារាស្ត្រខ្មែរក្នុងសម័យអង្គរ។

## ហេតុអ្វីត្រូវសិក្សាពីប្រវត្តិសាស្ត្រ?

មនុស្សគ្រប់រូបកំពុងរស់នៅក្នុងពេលបច្ចុប្បន្ន។ អ្នកទាំងនោះក៏កំពុងរៀបចំផែនការជីវិតរបស់ខ្លួនក្នុងពេលបច្ចុប្បន្នកាល និងបង្ហាញពីក្តីបារម្ភផងដែរចំពោះរឿងហេតុដែលនឹងកើតឡើងនាពេលអនាគត។ ប៉ុន្តែក្នុងពេលជាមួយគ្នា រឿងរ៉ាវដែលបានកើតឡើងពីអតីតកាល នៅតែផ្សារភ្ជាប់ជាមួយនឹងបច្ចុប្បន្នកាល ហើយវាក៏ស្ថិតនៅមិនឆ្ងាយពីការគិតរបស់មនុស្សដែរ។ អត្ថបទខ្លីចុះផ្សាយនៅក្នុងគេហទំព័រ History Today របស់ ហ្វ្រង់សេស្កា ម៉ដាគីស បានអធិប្បាយថា «ការសិក្សាពីប្រវត្តិសាស្ត្រ គឺជាការសិក្សាពីសកម្មភាព ការសម្រេចចិត្ត ការមានឥទ្ធិពលទៅវិញទៅមក និងអាកប្បកិរិយារបស់មនុស្ស។ ចំណេះដឹងពីប្រវត្តិសាស្ត្រ គឺជាការចងចាំជារួមពីរឿងរ៉ាវដែលបានកើតឡើងពីអតីតកាលរបស់បុគ្គលម្នាក់ គ្រួសារមួយ និងសង្គមជាតិមួយ។ ការចងចាំពីប្រវត្តិសាស្ត្រជួយដល់អ្នកសិក្សាបង្កើតគំនិតច្នៃប្រឌិតថ្មីក្នុងការដោះស្រាយបញ្ហាប្រវត្តិសាស្ត្រ តាមរយៈការឱ្យអត្ថន័យថ្មីទៅលើប្រវត្តិសាស្ត្រចាស់ៗពីអតីតកាល។ សម្រង់សម្តីដ៏ល្បីល្បាញរបស់លោក ចន អូវែល (George Orwell) ចេញពីប្រលោមលោកប្រឌិតបែបវិទ្យាសាស្ត្រដ៏ល្បីល្បាញរបស់គាត់មានចំណងជើងថា «១៩៨៤» បានរៀបរាប់ថា «មនុស្សគឺជាអ្នកគ្រប់គ្រងអតីតកាល និងអនាគតកាល ហើយមនុស្សក៏ជាអ្នកគ្រប់គ្រងបច្ចុប្បន្នកាល និងអតីតកាលដែរ»។ ឃ្លានេះ មានអត្ថន័យធំធេងផ្តោតលើការសិក្សាពីអតីតកាល ដែលមានឥទ្ធិពលលើជីវិតប្រចាំថ្ងៃ និងឆ្លើយតបទៅនឹងកាលៈទេសៈនាពេលបច្ចុប្បន្នកាល។ នៅក្នុងការពន្យល់បន្ថែមលើផ្នែកនេះ អ្នកនិពន្ធសៀវភៅណែនាំសម្រាប់គ្រូបង្រៀន បានគូសបញ្ជាក់ថា ប្រសិនជាមនុស្សធ្វើការបកស្រាយខុសចំពោះប្រវត្តិសាស្ត្រពីអតីតកាល នោះការសម្រេចចិត្តនានានាពេលបច្ចុប្បន្នកាល ពិតជាមានកំហុសឆ្គងធ្ងន់ធ្ងរដែលឈានដល់ការកើតមានជម្លោះ ខ្លះខ្លាយប្រភពធនធាន និងបាត់បង់អារ្យធម៌ប្រទេស។

នៅឆ្នាំ២០២០ អ្នកនិពន្ធឈ្មោះ Peter N. Stearns បានពិនិត្យសៀវភៅដែលគាត់បានសរសេររួមគ្នាជាមួយអ្នកនិពន្ធ Marcus Collins មានចំណងជើងថា «ហេតុអ្វីត្រូវរៀនប្រវត្តិសាស្ត្រ» បោះពុម្ពឆ្នាំ១៩៩៨ ឡើងវិញ និងបានសង្ខេបចំណុចសំខាន់ៗទាក់ទងនឹងសារប្រយោជន៍ចេញមកពីការសិក្សាប្រវត្តិសាស្ត្រ។ សេចក្តីសង្ខេបនេះ ត្រូវបានចុះផ្សាយនៅក្នុងគេហទំព័រ https://www.historians.org/ ដើម្បីផ្តល់ជាជំនួយដល់អ្នកដែលចង់សិក្សាពីប្រវត្តិសាស្ត្រ។ ខាងក្រោមនេះ ជាការលើកយកចំណុចសំខាន់ៗខ្លះៗដែលបានរៀបរាប់នៅក្នុងគេហទំព័រខាងលើមកធ្វើការអធិប្បាយ អមដោយការផ្តល់ជាឧទាហរណ៍ខ្លះៗពីប្រវត្តិសាស្ត្រខ្មែរក្រហមមកបញ្ជាក់បន្ថែមផង។

ប្រវត្តិសាស្ត្រ ជួយយើងឱ្យយល់ពីមនុស្ស និងសង្គម៖ ប្រវត្តិសាស្ត្រ គឺជាបណ្តុំព័ត៌មានអំពីការប្រព្រឹត្តទៅរបស់មនុស្ស និងសង្គម។ ក្នុងអំឡុងពេលដែលប្រទេសកម្ពុជាសព្វថ្ងៃកំពុងមានសន្តិភាព យើងមិនអាចដឹងទេថា តើប្រជាជនដែលរស់នៅក្នុងសម័យកើតមានសង្គ្រាម ទទួលរងភាពលំបាកលំបិនប៉ុណ្ណាឡើយ ហើយយើងក៏មិនអាចវាយតម្លៃ ឬប៉ាន់ស្មានបានពីទំហំនៃសង្គ្រាមដែលបានកើតឡើងនៅក្នុងប្រវត្តិសាស្ត្រកាលពីអតីតកាលរបស់ប្រទេសយើងដូចម្តេចដែរ។ ការប្រើប្រាស់ និងរៀនសូត្រពីឯកសារជាប្រវត្តិសាស្ត្រដែលបានបរិយាយអំពីរឿងរ៉ាវនៃបទពិសោធន៍ និងសង្គ្រាមកាលពីអតីតកាល គឺជាមធ្យោបាយតែមួយគត់ដែលនាំឱ្យយើងយល់ដឹងពីស្ថានភាពរបស់មនុស្ស និងស្ថិរភាពសង្គមពីអតីតកាលបាន។ ឯកសារដ៏សម្បូរណ៍បែបទាំងនោះ មានតម្កល់នៅក្នុងបណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារ

កម្ពុជា។ ប្រវត្តិសាស្ត្រផ្តល់ នូវមូលដ្ឋានភស្តុតាងដ៏សម្បើម សម្រាប់ការត្រិះរិះពិចារណាស៊ីជម្រៅ និងការវិភាគអំពីរបៀបដែលសង្គមដំណើរការ ហើយមនុស្សត្រូវតែស្វែងយល់ពីរបៀបដែលសង្គមដំណើរការ ដើម្បីជួយដល់ដំណើរការនៃជីវិតរបស់ខ្លួននៅក្នុងសង្គមបច្ចុប្បន្ន។ នេះជាមូលហេតុដែលយើងមិនអាចរស់នៅឆ្ងាយពីប្រវត្តិសាស្ត្របាន។

ប្រវត្តិសាស្ត្រ ជួយយើងឱ្យយល់ពីការផ្លាស់ប្តូរ និងរបៀបដែលសង្គមយើងរស់នៅបានកើតឡើង។ អតីតកាលបង្កើតវឌ្ឍនភាពនាពេលបច្ចុប្បន្ន និងធ្វើឱ្យមានអនាគត។ មានតែតាមរយៈការសិក្សាប្រវត្តិសាស្ត្រប៉ុណ្ណោះ ដែលធ្វើឱ្យយើងអាចយល់ពីរបៀបដែលអ្វីៗត្រូវបានផ្លាស់ប្តូរ និងបណ្តាលឱ្យមានការផ្លាស់ប្តូរ ព្រមទាំងឱ្យយើងអាចយល់បានថា តើមានធាតុផ្សំអ្វីខ្លះ ដែលធ្វើឱ្យស្ថាប័នឬសង្គមមួយ នៅស្ថិតស្ថេរបាន ទោះបីជាមានការផ្លាស់ប្តូរក៏ដោយ។ យើងរស់នៅជាមួយនឹងប្រវត្តិសាស្ត្រដោយមិនអាចគេចវេះបាន ហើយយើងអាចកែច្នៃប្រវត្តិសាស្ត្រពីអតីតកាល ដើម្បីបច្ចុប្បន្នកាល និងអនាគតកាលដ៏ផូរផង់របស់យើងបាន។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើកិច្ចការនេះតាំងពីឆ្នាំ២០០៩ ដើម្បីធានាថាលោកគ្រូអ្នកគ្រូបានបង្រៀនសិស្សរបស់ខ្លួនពីធាតុផ្សំនានា ដែលនាំឱ្យកើតមានអំពើប្រល័យពូជសាសន៍ និងធ្វើយ៉ាងណា ដើម្បីឱ្យសង្គមបច្ចុប្បន្នមានការចងចាំជារួម ក្នុងន័យអភិវឌ្ឍន៍គំនិតក្មេងៗជំនាន់ក្រោយឱ្យមានការផ្លាស់ប្តូរ ការគិតពីការប្រព្រឹត្តអំពើឃោរឃៅ ទៅជាការធ្វើឱ្យប្រសើរឡើងនូវការគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ដើម្បីឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រទេសជាតិ។



និស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រងចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រវត្តិសាស្ត្ររួមចំណែកដល់ការយល់ដឹងខាងសីលធម៌៖ គន្លឹះសំខាន់នៅក្នុងផ្នែកនេះ ផ្តោតលើការឆ្លើយតបផ្លូវអារម្មណ៍ចំពោះរឿងរ៉ាវដែលបានកើតឡើងរវាងមនុស្សរស់នៅក្នុងពេលបច្ចុប្បន្ន និងរឿងរ៉ាវពីអតីតកាល។ របបខ្មែរក្រហមបានបន្តមហន្តរាយយ៉ាងសម្បើមដល់មនុស្ស និងសង្គមកម្ពុជាទាំងមូល។ មនុស្សប្រមាណពី១លាន៧សែននាក់ ទៅ ២លាន២សែននាក់ បានស្លាប់យ៉ាងអាណោចអធ័មបំផុត ក្នុងរជ្ជកាលគ្រប់គ្រងដោយខ្មែរក្រហម។ ការបាត់បង់នេះ ត្រូវបានយកចិត្តទុកដាក់ ថែរក្សា និងចងចាំពីសំណាក់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងក្មេងៗជំនាន់ក្រោយ។ កិច្ចការងារនេះបានធ្វើឱ្យមនុស្សជំនាន់ក្រោយ ទាំងឡាយ បង្ហាញនូវភាពសោកស្តាយ អាណិតអាសូរ និងព្រួយបារម្ភពីការកកើតឡើងម្តងទៀតចំពោះជំនាន់របស់ខ្លួន។ ការព្រួយបារម្ភនេះ នាំឱ្យមនុស្សជំនាន់ក្រោយរិះរកមធ្យោបាយនានា ឬបង្កើតគំនិតថ្មីៗដើម្បីរារាំងនូវរាល់ភាពស្រដៀង និងដូចគ្នាទៅនឹងអំពើឃោរឃៅដែលបានកើតមានឡើងក្នុងរបបខ្មែរក្រហម។

ប្រវត្តិសាស្ត្រ ជួយលើកតម្កើងភាពជាអ្នកដឹកនាំល្អ ឬពលរដ្ឋល្អ៖ ប្រវត្តិសាស្ត្រ គឺជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងខ្លួនឯង ដើម្បីកែខៃនូវអ្វីដែលមិនល្អឱ្យល្អសម្រាប់ខ្លួនឯង។ ទស្សនវិទូជនជាតិក្រិចដ៏ល្បីល្បាញលើពិភពលោក អារីស្តូត បានប្រាប់យើងថា «ការស្គាល់ខ្លួនឯង គឺជាការចាប់ផ្តើមនៃការស្គាល់ឧត្តមគតិទាំងអស់របស់យើង»។ ទស្សនៈនេះ ត្រូវបានវែកញែកពីអ្នកជំនាញ អ្នកស្រាវជ្រាវ និងមនុស្សមួយចំនួនតាមមុខជំនាញ និងប្រធានបទរបស់ខ្លួន។ ទោះបីជាយ៉ាងនេះក៏ដោយ ទស្សនៈនេះ ត្រូវបានវិភាគផ្តោតលើភាពជាអ្នកដឹកនាំដែលមានលក្ខណៈសម្បត្តិល្អរបស់មេដឹកនាំក្នុងពិភពលោក។ បណ្ឌិត ស្តេហ្វិន ប្រូកឃេស ជានាយកប្រតិបត្តិ និងស្ថាបនិកក្រុមហ៊ុន Compass Leadership Limited បានសរសេរនៅក្នុងអត្ថបទមានចំណងជើង «រៀនពីភាពដឹកនាំចេញមកពីប្រវត្តិសាស្ត្រពីអតីតកាល» ថា៖ «ភាពជាអ្នកដឹកនាំរបស់យើង គឺតម្រូវឱ្យដើរតាមដំណើរជីវិតរបស់យើងពីអតីតកាល។ បទពិសោធន៍ជីវិតរបស់យើង នឹងកំណត់ថាយើងជានរណា និងរបៀបដែលយើងដឹកនាំយ៉ាងដូចម្តេច។ ប្រវត្តិសាស្ត្រ គឺជាការឆ្លុះបញ្ចាំងពីដំណើររបស់យើង»។ ការបង្រៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមសាលារៀនទាំងរដ្ឋ និងឯកជន គឺបង្ហាញពីភាពជាអ្នកដឹកនាំដ៏មានឥទ្ធិពលរបស់ស្ថាប័នឯកជន និងរដ្ឋ ក្នុងការរារាំងអំពើប្រល័យពូជសាសន៍វិលត្រឡប់មកវិញជាលើកទីពីរ។ មនុស្សគ្រប់រូបដែលបានរៀនសូត្រពីប្រវត្តិសាស្ត្រនេះ បានដឹងពិតប្រាកដថា ខ្លួនឯងជានរណា ហើយគួរធ្វើយ៉ាងណាសម្រាប់ការអភិវឌ្ឍន៍ប្រទេសកម្ពុជានាពេលអនាគត។

ជារួម ការសិក្សាប្រវត្តិសាស្ត្រ មានប្រយោជន៍ដ៏មហិមារនៅក្នុងពិភពនៃការងារប្រចាំថ្ងៃ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងស្ថាបនិកនៃព្រះរាជបណ្ណាល័យ ហ្វូងម៉ែ បានមានប្រសាសន៍ទៅកាន់យុវជនជំនាន់ក្រោយថា មនុស្សភាគច្រើនដែលសិក្សាមុខវិជ្ជាប្រវត្តិសាស្ត្រ មិនបានក្លាយជាអ្នកប្រវត្តិវិទូអាជីពទាំងអស់គ្នាទេ។ ប៉ុន្តែអ្នកទាំងនោះអាចធ្វើជាគ្រូបង្រៀន ធ្វើការនៅក្នុងសារមន្ទីរ នៅមជ្ឈមណ្ឌលប្រព័ន្ធផ្សព្វផ្សាយ នៅស្ថាប័នស្រាវជ្រាវប្រវត្តិសាស្ត្រសម្រាប់អាជីវកម្ម ឬទីភ្នាក់ងារសាធារណៈ ឬចូលរួមក្នុងការប្រឹក្សាផ្នែកប្រវត្តិសាស្ត្រ។ ថ្វីត្បិតតែមនុស្សមួយចំនួន មិនបានបម្រើការងារក្នុងផ្នែកប្រវត្តិសាស្ត្រ អ្នកទាំងនោះក៏អាចបម្រើការងារ ទាក់ទងនឹងកិច្ចការងារក្នុងប្រវត្តិសាស្ត្របានដែរ ដូចជាការធ្វើឱ្យប្រសើរឡើងនូវជំនាញសរសេរ និងមូលដ្ឋាននៃការនិយាយ ព្រមទាំងអាចឆ្លើយតបបានត្រឹមត្រូវទៅនឹងតម្រូវការវិភាគជាច្រើននៅក្នុងវិស័យសាធារណៈ និងឯកជន។

# ការិយាល័យព័ត៌មានសាធារណៈ













«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នាមដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់បតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖00 ដល់ម៉ោង ១២៖00 និងពេលរសៀលពីម៉ោង ២៖00 ដល់ ម៉ោង ៥៖00។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!














# ទូច វ៉ាន់ ៖ នៅតែមានសង្ឃឹមថាកូនប្រុសនៅរស់រានមានជីវិតពីរបបខ្មែរក្រហម

ភា រស្មី

ឈ្មោះ ទូច វ៉ាន់ ភេទប្រុស អាយុ៧៣ឆ្នាំ (២០០៣)។ វ៉ាន់ រស់នៅភូមិត្រពាំងឈូក ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ។ វ៉ាន់ មានប្រពន្ធឈ្មោះ ប្រាក់ ណឹម អាយុ ៦៩ឆ្នាំ។ វ៉ាន់បានផ្តល់បទសម្ភាសន៍ឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជានៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣។ នៅក្នុងបទសម្ភាសន៍វ៉ាន់បានរៀបរាប់ពីការបាត់ខ្លួនកូនប្រុសម្នាក់ឈ្មោះ ទូច ចាន់នី ហៅ គ្រេន ដូចខាងក្រោម៖

ទូច ចាន់នី ហៅ គ្រេន ភេទប្រុស អាយុ១៩ឆ្នាំ កើតនៅភូមិត្រពាំងឈូក ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ។ តាមការជួបសម្ភាសន៍ជាមួយ ទូច វ៉ាន់ ដែលជាឪពុក បានរៀបរាប់ថា៖ ចាន់នី រៀនបានត្រឹមថ្នាក់ទី១០សង្គមចាស់។ នៅឆ្នាំ១៩៧២ ឈ្មោះ អ៊ូច ជាគណៈស្រុកគិរីវង់ ខេត្តតាកែវ និងត្រូវជាប្អូនថ្លៃរបស់តាម៉ុក បានមកសុំ ចាន់នី ឱ្យទៅធ្វើជានីរសាររបស់ខ្លួន។ វ៉ាន់ មិនបានបដិសេធជាមួយសំណើនេះទេ ហើយគាត់ថែមទាំងសប្បាយចិត្តដែលកូនបានចូលធ្វើការងារ។ ចាប់តាំងពី ចាន់នី ចេញទៅធ្វើជានីរសាររបស់ អ៊ូច, វ៉ាន់មិនដែលបានជួបកូនម្តងទៀតនោះទេ។ ចំណែកប្រពន្ធរបស់ វ៉ាន់ បានជួបកូនម្តងនៅក្នុងវត្ត នៅពេលដែល ចាន់នី យកសំបុត្ររបស់ អ៊ូច មកឱ្យឃុំត្រពាំងធំ។



ទូច វ៉ាន់ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិត្រពាំងឈូក ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅឆ្នាំ១៩៧៥ អ៊ូច បានមកប្រាប់វ៉ាន់វិញថា ចាន់នី លែងស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ទៀតហើយ។ ចាន់នីបានរៀបចំប្រវត្តិរូប និងសុំ អ៊ូច ទៅធ្វើការងារទទួលភ្ញៀវនៅភ្នំពេញ។ ក្រោយមកទៀតឈ្មោះ ចេង ដែលជាអ្នកភូមិជាមួយគ្នា និងជាអ្នកបានជួបជាមួយ ចាន់នី នៅឯភ្នំពេញ បានមកប្រាប់វ៉ាន់អំពីការរស់នៅរបស់ចាន់នីក្នុងក្រុងភ្នំពេញគឺសុខសប្បាយជាធម្មតា។ នៅពេលឮដូច្នេះ វ៉ាន់បានសុំប្រធានកងឈ្មោះ ធឹម ទៅលេងកូននៅភ្នំពេញប៉ុន្តែត្រូវបានបដិសេធ។ បើតាមសម្តីរបស់វ៉ាន់កន្លែងដែល ចាន់នី ធ្វើការងារគឺដូចកងសិល្បៈ មាននារី និងយុវជន សម្រាប់ចាំទទួលភ្ញៀវបរទេស។ កាល ចាន់នី នៅភ្នំពេញ ក៏ធ្លាប់ផ្ញើរូបថត និងសំបុត្រ មកឱ្យ វ៉ាន់ បានម្តង។ ចាន់នីបានផ្ញើសំបុត្រ និងរូបថតមកតាមរយៈថ្នាក់ខេត្ត ហើយខេត្តក៏ទម្លាក់មកខាងស្រុក។ ខាងស្រុកបានចាត់តាំងឱ្យឈ្មោះណុប យកមកប្រគល់ឱ្យ វ៉ាន់ នៅផ្ទះបន្តទៀត។

វ៉ាន់ នៅតែជឿជាក់ថា ចាន់នី កូនរបស់គាត់នៅរស់រានមានជីវិត ពីព្រោះគាត់បានសុបិនឃើញកូនប្រុសរបស់គាត់រត់ទៅតាមគ្រួសារ

នៅទិសខាងជើង។ មួយវិញទៀត ការសុបិនរបស់ វ៉ាន់ ដូចគ្នាទៅនឹងសម្ដីរបស់ លី ដែលជាអ្នកធ្លាប់ជួប ចាន់នី នៅពេលជម្លៀស។ លី បានប្រាប់ វ៉ាន់ ថាកូនរបស់គាត់ធ្វើការងារនៅកំពង់សោម។ វ៉ាន់ មានបំណងទៅសួរដំណឹង ចាន់នី បន្ថែមទៀត តាមរយៈនារី ខេន នៅម៉ាឡៃ ដែលជាអ្នកធ្លាប់ធ្វើការជាមួយគ្នា។

វ៉ាន់ បានបន្ថែមឱ្យដឹងទៀតថា គាត់គឺជាអ្នកភូមិជាមួយ តាម៉ុក លេខាភូមិភាគនិរតី។ តាម៉ុក មានឈ្មោះពិតប្រាកដ ជឿន។ ឪពុករបស់តាម៉ុកឈ្មោះ ព្រៀក និង ម្ដាយឈ្មោះ សុច។ តាម៉ុក មានបងប្អូនប្រុស៣នាក់ និង ស្រី៤នាក់។ ជីតាខាងឪពុករបស់តាម៉ុក ឈ្មោះ អ៊ុង។ កាលពីក្មេង តាម៉ុករស់នៅជាមួយជីដូនខាងម្ដាយម្នាក់ឈ្មោះ ញឹប ស្ថិតនៅភូមិប្រគាប។ តាម៉ុកបានរៀនត្រឹមថ្នាក់ឌីប្លូម បន្ទាប់មកគាត់ចូលបួសជាសង្ឃ។ នៅក្នុងសម័យឥស្សរៈ តាម៉ុក បានលាចាកសិក្ខាបទ ហើយមករៀបការជាមួយប្រពន្ធនៅក្នុងភូមិ និងរកស៊ីដឹកឈើជាមួយ វ៉ាន់។ វ៉ាន់ បាននិយាយថា តាម៉ុក គឺជាមនុស្សស្លូតបូត មិនចេះខូចខិល និងនិយាយម៉ាត់ៗ។ តាម៉ុក គឺជាមនុស្សចិត្តល្អ ប្រសិនបើមានបងប្អូនសុំនាឡិការបស់គាត់ គឺគាត់ឱ្យភ្លាម ប៉ុន្តែប្រសិនបើមានអ្នកក្រោយមកសុំបន្តទៀត គាត់នឹងយកពីអ្នកមុនឱ្យទៅអ្នកក្រោយវិញ។

បន្ទាប់មកទៀត នៅក្នុងភូមិមានមនុស្សខិលខូច ចាក់រុកឱ្យចាប់ខ្លួនតាម៉ុក។ មូលហេតុនេះហើយបានជាតាម៉ុក រត់ចូលព្រៃ។ នៅក្នុងសម័យលន់ នល់ វ៉ាន់ បានជួបតាម៉ុក ម្ដងនៅពេលដែលគាត់មកលេងឪពុកនៅស្រុកកំណើត។ ក្រោយពីនោះ វ៉ាន់ មិនដែលបានជួប តាម៉ុក បន្តទៀតទេ។ នៅក្នុងសម័យខ្មែរក្រហម វ៉ាន់មិនដឹងថា តាម៉ុក ធ្វើការងារអ្វីនោះទេ។ នៅរបបខ្មែរក្រហម ជីវភាពរស់នៅរបស់ប្រជាជនក្នុងស្រុកកំណើតរបស់តាម៉ុក គឺមានអាហារហូបគ្រប់គ្រាន់ ខុសពីកន្លែងផ្សេងៗ។ ខ្មែរក្រហមចាត់ទុកប្រជាជននៅក្នុងឃុំត្រពាំងធំ គឺជាប្រជាជនស្មោះត្រង់ ស្អាតស្អំ ហើយបានបញ្ជូនប្រជាជននៅក្នុងឃុំនេះទៅគ្រប់គ្រងប្រជាជននៅតាមតំបន់ផ្សេងៗ។ ជាក់ស្ដែងនៅឆ្នាំ១៩៧៧ អង្គការបានរំសាយសហករណ៍ ហើយបញ្ជូន វ៉ាន់ ឱ្យទៅដឹកនាំប្រជាជនធ្វើស្រែនៅតានី តំបន់១០៦ ខេត្តតាកែវ (បច្ចុប្បន្នស្ថិតនៅក្នុងខេត្តកំពត)។

វ៉ាន់បានឱ្យដឹងថា មុនពេលគាត់ទៅដល់ ប្រជាជននៅ តានី ជួបទុក្ខលំបាកយ៉ាងខ្លាំង។ ប្រជាជនស្លៀកសម្លៀកបំពាក់រហែក និងត្រូវធ្វើការងារលើសកម្លាំង។ មិនតែប៉ុណ្ណោះ ប្រជាជនមិនបានទទួលអាហារហូបគ្រប់គ្រាន់។ នៅក្នុងសហករណ៍ វ៉ាន់ ត្រូវដឹកនាំប្រជាជនប្រមាណ៤០នាក់ឱ្យធ្វើស្រែ។ ទិន្នផលស្រូវ និងដំណាំដែលទទួលបានវ៉ាន់បានផ្ដល់ឱ្យប្រជាជនហូបយ៉ាងគ្រប់គ្រាន់ ហើយសម្លៀកបំពាក់ដែលរហែក គាត់បើកឱ្យថ្មី។ វ៉ាន់ ធ្វើការនៅតានីរហូតដល់រដូវប្រមូលផល ក៏មានកងទ័ពវៀតណាមវាយចូលមក ហេតុនេះវ៉ាន់ត្រូវជម្លៀសចេញពសហករណ៍មួយរយៈ។

ក្រោយមកទៀត វ៉ាន់ ស្នើសុំអង្គការត្រឡប់មកផ្ទះវិញ ព្រោះប្រពន្ធជិតគ្រប់ខែឆ្លងទន្លេ។ នៅពេលដែល វ៉ាន់ សុំត្រឡប់មកវិញ មេឃុំនៅទីនោះបានឃាត់គាត់ និងចាត់តាំង វ៉ាន់ ទៅគ្រប់គ្រងខាងពាណិជ្ជកម្ម។ ប៉ុន្តែ វ៉ាន់ ធ្វើការបដិសេធ។ វ៉ាន់ បានបន្តថា នៅពេលដែលគាត់ចេញពីសហករណ៍ មានប្រជាជនយំសោកស្ដាយគាត់។ វ៉ាន់ បានត្រឡប់មកនៅជាមួយប្រពន្ធវិញ រហូតដល់កងទ័ពវៀតណាមវាយចូលមកឆ្នាំ១៩៧៩។



ប្រជាជនកម្ពុជាវិលត្រឡប់មកស្រុកកំណើតវិញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របមុខ ៖
ខៀវ សំផន និងគណៈប្រតិភូភូមា នៅពេលានយន្តហោះពោធិ៍ចិនតុង។
(បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ ៖
មេដឹកនាំខ្មែរក្រហមជិះលើរទេះភ្លើង។
(បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣*

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 302, February 2025 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.